របាយការណ៍នៃការជួញដូរមនុស្ស

ចេញផ្សាយដោយការិយាល័យត្រួតពិនិត្យ និង ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស
៥ មិថុនា ២០០៦

លិខិតពីរដ្ឋមន្ត្រីក្រសួងការបរទេស Condoleezza Rice

ជូនចំពោះលោកអ្នកអាន :

ចលនាបញ្ចប់ការជួញដូរមនុស្សគឺលើសពីគោលបំណងនៃសិទ្ធិមនុស្ស ដែលវាគឺជាបញ្ហាសន្តិសុខរបស់ពិភពលោក ។

យុទ្ធសាស្ត្រសន្តិសុខជាតិរបស់លោកប្រធានាធិបតី Bush បានបញ្ជាក់សារជាថ្មីអំពីជំនឿរបស់យើងដែលថាការលើកកម្ពស់ប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស គឺជាយុទ្ធសាស្ត្ររយៈពេលវែងដែលមានប្រសិទ្ធិភាពបំផុតសម្រាប់ការធានាស្ថេរភាព ។ ដោយមានរួមបញ្ចូលនៅក្នុងគោលដៅរបស់យុទ្ធសាស្ត្រនេះចំពោះការបញ្ចប់អំណាចផ្តាច់ការ ការផ្សព្វផ្សាយសេរីភាព និង ការគាំទ្រការពារសេចក្តីថ្លៃថ្នូររបស់មនុស្សលោក គឺជាការប្តេជ្ញារបស់យើងដើម្បីបញ្ចប់ការជួញដូរមនុស្ស : "ការជួញដូរមនុស្សគឺជាទម្រង់នៃទាសភាពសម័យទំនើបបច្ចុប្បន្ន ហើយយើងខិតខំប្រឹងប្រែងដើម្បីលុបបំបាត់វាចោលទាំងស្រុង ។ មនុស្សជំនាន់ក្រោយនាពេលអនាគតនឹងមិនអត់ឱនចំពោះអ្នកទាំងឡាយណាដែលត្រឡប់ទៅប្រព្រឹត្តិអំពើនោះឡើយ" ។

អ្នកជួញដូរមនុស្សធ្វើឱ្យរងគ្រោះដល់ជនទន់ខ្សោយបំផុត និង ទទួលបានផលចំណេញពីការជួញដូរដោយសារការចំណាយជីវិតរបស់មនុស្សស្លូតត្រង់ ។ កិច្ចខំប្រឹងប្រែងរបស់ក្រសួងការបរទេសដើម្បីបញ្ចប់ការជួញដូរដ៏អាក្រក់ឃោឃៅគ្មានសីលធម៌នេះ មានតួយ៉ាងដូចជាការធ្វើការទូតដែលមានលក្ខណៈខុសប្លែកប្រកបដោយតម្លៃ ។ យើងធ្វើការជាមួយដៃគូអន្តរជាតិ ដើម្បីធានាសេរីភាពនៃអ្នកដែលត្រូវបានគេកេងប្រវ័ញ្ច និង អំពាវនាវឱ្យរដ្ឋាភិបាលធ្វើការដោយមានប្រសិទ្ធិភាព និង ការទទួលខុសត្រូវលើការផ្តន្ទាទោសអ្នកដែលបានកេងប្រវ័ញ្ច ។

សូមអរគុណចំពោះភាពដឹកនាំរបស់លោកប្រធានាធិបតី, ការប្តេជ្ញារបស់សភា និង ការគាំទ្រពីក្រុមជំនឿសាសនា, សហគមន៍, ក្រុមសិទ្ធិមនុស្ស និង ក្រុមស្ត្រី ជាច្រើនរាប់មិនអស់ ក៏ដូចជាប្រជាពលរដ្ឋគ្រប់រូបដែលបានធ្វើឱ្យចលនាបញ្ចប់ការជួញដូរមនុស្សបន្តទទួលការអភិវឌ្ឍន៍ជាបន្តបន្ទាប់ ។ សូមអរគុណលោកអ្នកចំពោះការចូលរួមនៅក្នុងចលនាលុបបំបាត់នេះ ក្នុងនាមជាប្រជាពលរដ្ឋទន់ខ្សោយបំផុតរបស់ពិភពលោក ។

ដោយសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់

Condoleezza Rice

របាយការណ៍នៃការជួញដូរមនុស្ស

ចេញផ្សាយដោយការិយាល័យត្រួតពិនិត្យ និង ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស
៥ មិថុនា ២០០៦

I. សេចក្តីផ្តើម

នេប៉ាល/ឥណ្ឌា : រីណា ត្រូវបាននាំមកប្រទេសឥណ្ឌា ពីប្រទេសនេប៉ាលដោយមីងខាងម្តាយរបស់នាង ដែលបានបង្ខំក្មេងស្រីអាយុ ១២ ឆ្នាំនេះ ឱ្យទៅនៅផ្ទះបនទៅ ញូវដេលី ក្នុងពេលមិនយូរប៉ុន្មានបន្ទាប់ពីការមកដល់ទីក្រុងនេះ ។ ម្ចាស់ផ្ទះបនបានឱ្យនាងរួមភេទជាមួយភ្ញៀវជាច្រើននាក់ជារៀងរាល់ថ្ងៃ ។ រីណាមិនអាចចាកចេញពីកន្លែងនេះទេ ពីព្រោះនាងមិនចេះនិយាយភាសា ហ៊ិនឌី ហើយគ្មាននរណាម្នាក់ដែលនាងអាចទៅរកបាន ។ ជាញឹកញាប់ នាងបានឃើញមន្ត្រីនគបាលប្រមូលប្រាក់ពីម្ចាស់ផ្ទះបន សម្រាប់ក្មេងស្រីថ្មីៗដែលបាននាំមក ។ ម្ចាស់ផ្ទះបនបានបង្គាត់រីណា និង ក្មេងស្រីទាំងអស់ឱ្យប្រាប់អ្នកដែលបានសួរ ថាពួកគេមានអាយុ ២៥ ឆ្នាំ និង បានមកនៅផ្ទះបននេះដោយស្ម័គ្រចិត្ត ។ រីណាបានរត់គេច បន្ទាប់ពីរយៈពេលពីរឆ្នាំ ហើយឥឡូវនាងបូជាជីវិតរបស់នាងដើម្បីជួយជនរងគ្រោះដែលបានជួញដូរផ្សេងទៀតឱ្យរត់គេច ។

របាយការណ៍នៃការជួញដូរមនុស្ស (TIP) ២០០៦ : គោលបំណងនៃរបាយការណ៍

ច្បាប់តម្រូវឱ្យក្រសួងការបទេសប្រគល់របាយការណ៍មួយជារៀងរាល់ឆ្នាំទៅសភាសហរដ្ឋអាមេរិកដែលស្តីអំពីកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលបរទេសដើម្បីលុបបំបាត់ទម្រង់នៃការជួញដូរមនុស្សដ៏ធ្ងន់ធ្ងរ ។ របាយការណ៍នេះគឺជារបាយការណ៍ TIP ប្រចាំឆ្នាំ លើកទី ៦ ។ វាមានគោលបំណងលើកតម្កើនការយល់ដឹងទូទាំងពិភពលោក, លើកយកកិច្ចខំប្រឹងប្រែងដែលមានភាពរីកចម្រើនសំខាន់ៗរបស់សហគមន៍អន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និង ជម្រុញរដ្ឋាភិបាលបរទេសឱ្យធ្វើសកម្មភាពដ៏មានប្រសិទ្ធិភាព ដើម្បីប្រឆាំងតទល់នឹងទម្រង់នៃការជួញដូរមនុស្សទាំងអស់ ។ របាយការណ៍នេះបានផ្តោតបន្ថែមទៅលើកិច្ចខំប្រឹងប្រែងរបស់សហគមន៍នៃប្រជាជាតិនានាដែលបានរីកលូតលាស់ លើការចែករំលែកព័ត៌មាន និង ការចាប់ដៃគូរនៅក្នុងមធ្យោបាយថ្មីៗ និង សំខាន់ៗ ។ បើយោងតាមច្បាប់សហរដ្ឋអាមេរិក ប្រទេសមួយដែលបានខកខានក្នុងការធ្វើកិច្ចខំប្រឹងប្រែងសំខាន់ៗ ដើម្បីនាំប្រទេសរបស់ខ្លួនឱ្យអនុលោមតាមបទដ្ឋានអប្បបរមានៃការលុបបំបាត់ការជួញដូរមនុស្ស ទទួលបាននូវការវាយតម្លៃ "ថ្នាក់ទី ៣" នៅក្នុងរបាយការណ៍នេះ ។ ការវាយតម្លៃដូច្នោះអាចធ្វើឱ្យមានការព្យួរជំនួយមិនទាក់ទងនឹងមនុស្សជាតិ និង ដែលមិនទាក់ទងនឹងជំនួញ ពីសហរដ្ឋអាមេរិកទៅប្រទេសនោះ ។

ក្នុងការវាយតម្លៃកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលបរទេស របាយការណ៍ TIP លើកយកដ៏សំខាន់នៃ "P's បី" គឺ ការផ្តន្ទាទោស (Prosecution), ការការពារ (Protection) និង ការបង្ការ (Prevention) ។ ប៉ុន្តែវិធីសាស្រ្តផ្តោតលើជនរងគ្រោះនៃការជួញដូរ តម្រូវឱ្យយើងបង្ហាញផងដែរនូវសមភាពរបស់វា "R's បី" គឺ ការសង្គ្រោះ (Rescue), ការស្តារ

នីតិសម្បទាឡើងវិញ (Rehabilitation) និង ការចូលរួមឡើងវិញ (Reintergration)។ ច្បាប់សហរដ្ឋអាមេរិកដែលបង្ហាញផ្លូវដល់កិច្ចខំប្រឹងប្រែងនេះគឺ ច្បាប់ការពារជនរងគ្រោះនៃការជួញដូរ (TVPA) ឆ្នាំ ២០០២ ដែលបានកែប្រែ មានភាពច្បាស់លាស់តាំងពីចំណុចផ្តើមដែលថា គោលបំណងនៃការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស គឺដើម្បីធានាឱ្យបាននូវការដាក់ទណ្ឌកម្មដ៏យុត្តិធម៌ និង មានប្រសិទ្ធិភាពចំពោះអ្នកជួញដូរ, ដើម្បីការពារជនរងគ្រោះ និង ដើម្បីបង្កាការជួញដូរកុំឱ្យកើតមានឡើង។

ជាង ១៥០ ឆ្នាំមុន សហរដ្ឋអាមេរិកបានវាយគ្នានៅក្នុងសង្គ្រាមបំផ្លិតបំផ្លាញមួយដែលបានបញ្ចប់ដោយការលុបបំបាត់ទាសភាពនៅក្នុងប្រទេសនេះ។ ទោះបីជាប្រទេសភាគច្រើនបានលុបបំបាត់សេរីគតិភាពដែលជាការប្រតិបត្តិទទួលទណ្ឌកម្មពីរដ្ឋ ទម្រង់សម័យទំនើបនៃទាសភាពមនុស្សជាតិបានលេចឡើង។ នេះគឺជាការគម្រាមកំហែងដល់ជីវិត និង សេរីភាពរបស់បុរស, ស្ត្រី និង ក្មេងរាប់លាននាក់នៅលើពិភពលោកដែលកំពុងរីកលូតលាស់ឡើង។ បច្ចុប្បន្ននេះ មានតែនៅក្នុងរបបឃោរឃៅ និង និគ្រោះ ដូចជា ភូមា និង កូរ៉េខាងជើងទេ ដែលទាសភាពនៅតែទទួលការគាំទ្រដោយរដ្ឋ។ ប៉ុន្តែការជួញដូរមនុស្ស ជាញឹកញាប់ទាក់ទងនឹងក្រុមបណ្តាញឧក្រិដ្ឋកម្មដែលរកប្រាក់បានយ៉ាងច្រើន នៅពេលដែលវាជាការចំណាយរបស់ជនរងគ្រោះនៃការជួញដូរ និង សង្គមរបស់យើង។

អារ៉ាប៊ីសាអូឌី : សេរេនាបានមកពីហ្វីលីពីនដើម្បីធ្វើការជាអ្នកបម្រើតាមគ្រួសារនៅអារ៉ាប៊ីសាអូឌី។ ចាប់តាំងពីនាងបានមកដល់ អ្នកជួលនាងបានដកទុកលិខិតឆ្លងដែនរបស់នាង ហើយគាត់ និង ប្រពន្ធរបស់គាត់បានចាប់ផ្តើមវាយ និង ជេរប្រទេចនាង។ នៅពេលមួយនោះ ម្ចាស់ស្រីរបស់នាងបានច្រាននាងធ្លាក់ពីលើជណ្តើរ។ មានពេលមួយទៀត ម្ចាស់ប្រុសរបស់នាងបានប្របាច់កនាងរហូតទាល់តែនាងសន្លប់។ នាងមិនត្រូវបានអនុញ្ញាតឱ្យចេញពីផ្ទះឡើយ។ ដោយសារតែលិខិតឆ្លងដែនរបស់នាងត្រូវបានដកទុក នាងមិនអាចលួចរត់បានឡើយ។ សេរេនាមិនសប្បាយចិត្តទេ ធ្វើឱ្យនាងមានបំណងចង់សម្លាប់ខ្លួន។ មានពេលមួយនៅមន្ទីរពេទ្យ នាងអាចរត់គេចពីអ្នកឃ្លាំនាង។ នាងបានស្វែងរកយុត្តិធម៌ពីប្រព័ន្ធតុលាការសាអូឌី និង កំពុងរងចាំយុត្តិធម៌នៅក្នុងទីជម្រកមួយ។

ការយកចិត្តទុកដាក់ទៅលើពលកម្មទាសករ និង ទាសភាពផ្លូវភេទ

ជារៀងរាល់ឆ្នាំ យើងបានបន្ថែមទៅលើចំណេះដឹងរបស់យើងនូវបាតុភូតនៃការជួញដូរ។ នៅក្នុងរបាយការណ៍ឆ្នាំ ២០០៤ យើងបានប្រើប្រាស់ទិន្នន័យរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលបានបំបែកការជួញដូរមនុស្សឆ្លងប្រទេស ទៅតាមអាយុ និង ភេទ ជាលើកទីមួយ។ ទិន្នន័យនេះបង្ហាញថា បុរស, ស្ត្រី និង កុមារ ប្រហែល ៦០០.០០០ ទៅ ៨០០.០០០ នាក់ ត្រូវបានជួញដូរឆ្លងកាត់ព្រំដែនអន្តរជាតិ ជារៀងរាល់ឆ្នាំ ហើយ ប្រហែលជា ៨០ ភាគរយនៃចំនួននោះ គឺជាស្ត្រី និង ក្មេងស្រី និង ចំនួនដល់ទៅ ៥០ ភាគរយគឺជាអនីតិជន។ ប៉ុន្តែ ជាមួយនឹងការយកចិត្តទុកដាក់ទៅលើការជួញដូរមនុស្សឆ្លងប្រទេស ចំនួនទាំងនេះមិនរួមបញ្ចូលជនរងគ្រោះរាប់លាននាក់នៅជុំវិញពិភពលោកដែលត្រូវបានជួញដូរនៅក្នុងប្រទេស

ផ្ទាល់ខ្លួនរបស់ពួកគេឡើយ។ របាយការណ៍ ២០០៦ បង្ហាញនូវពន្លឺថ្មីដែលដាស់អារម្មណ៍លើការជួញដូរមនុស្សក្នុងគោលបំណងនៃពលកម្មទាសករ ជាញឹកញាប់នៅក្នុងប្រទេសផ្ទាល់ខ្លួនរបស់ពួកគេ។ នេះគឺជាទម្រង់នៃការជួញដូរមនុស្សថ្មីដែលអាចនឹងពិបាកក្នុងការកំណត់ និង វាយតម្លៃ ជាងការជួញដូរផ្លូវភេទ ប៉ុន្តែវាអាចមានទំហំធំជាងច្រើន នៅពេលដែលយើងប៉ាន់លើការជួញដូរនៅក្នុងតំបន់។ វាមិនទាក់ទងយ៉ាងសំខាន់នឹងបណ្តាញឧក្រិដ្ឋកម្មតែមួយ ដែលទទួលបានផលចំណេញពីការជួញដូរឆ្លងប្រទេសសម្រាប់ការធ្វើអាជីវកម្មផ្លូវភេទនោះទេ។ ជាញឹកញាប់បំផុត បុគ្គលទាំងនោះគឺមានកំហុស ឧទាហរណ៍ដោយការយកអ្នកបម្រើតាមគ្រួសារម្នាក់ ឬ កម្មកររោងចក្ររាប់រយនាក់ដែលបានបង្ខំឱ្យធ្វើការដោយមិនទទួលប្រាក់កម្រៃមកធ្វើជាទាសករ។

វិសាលភាពដ៏ធំនៃការប៉ាន់ស្មានកើតមានលើដែន និង ទំហំនៃទាសភាពទំនើបសម័យបច្ចុប្បន្ន ទាំងនៅក្នុងប្រទេស និង ឆ្លងប្រទេស។ អង្គការពលកម្មអន្តរជាតិ (ILO) ដែលជាភ្នាក់ងាររបស់អង្គការសហប្រជាជាតិ (UN) ទទួលបន្ទុកលើការបង្ហាញបញ្ហាបទដ្ឋានពលកម្ម, ការជួលមនុស្ស និង ការការពារសង្គម ប៉ាន់ស្មានថាមានមនុស្ស ១២,៣ លាននាក់ កំពុងស្ថិតនៅក្នុងពលកម្មបង្ខំ, ពលកម្មជាប់បំណុល, ពលកម្មកុមារបង្ខំ និង សេវគតិភាពផ្លូវភេទ នៅក្នុងពេលផ្តល់ឱ្យណាមួយ។ ការប៉ាន់ស្មានផ្សេងទៀតមានវិសាលភាពពី ៤ លាន ទៅ ២៧ លាន។

ការខិតខំអស់ពីលទ្ធភាព : ក្នុងការស្វែងរកកម្មករទេសន្តរប្រវេសន៍ដែលអាចកេងប្រវ័ញ្ចបាន

សកលភាវូបនីយកម្មសេដ្ឋកិច្ចបានជម្រុញភាពចល័តដែលមិនធ្លាប់មានពីមុននៃពលកម្មគ្មានជំនាញ និង មានជំនាញទាប ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារដែលមានឱនភាពពលកម្មសម្រាប់ការសាងសង់, ការផលិត, កសិកម្ម និង ការងារតាមគ្រួសារ។ កម្មករទេសន្តរប្រវេសន៍មកពីប្រទេសនៅអាស៊ីខាងត្បូង និង ខាងកើតដែលអភិវឌ្ឍន៍តិចតួច បានធ្វើកិច្ចសន្យាពលកម្មរយៈពេលខ្លី នៅក្នុងប្រទេសនៅអាស៊ី, អ៊ឺរ៉ុប និង មជ្ឈិមបូព៌ាដែលអភិវឌ្ឍន៍ច្រើន នៅក្នុងអត្រាមួយកើនឡើងដែលមិនធ្លាប់មាន។ ILO ប៉ាន់ស្មានពលករទេសន្តរប្រវេសន៍មានចំនួន ១២០ លាន នាក់។ អារ៉ាប៊ីសាអូឌី (៧,៥ លាន), សហព័ន្ធអារ៉ាប់អ៊ីមីរ៉ែត (២,៣ លាន), ម៉ាឡេស៊ី (២,៣ លាន) និង គុយវ៉ែត (១,៣ លាន) នាំមុខនៅលើទីផ្សារតម្រូវការកម្មករទេសន្តរប្រវេសន៍បរទេស។ ហ្វីលីពីន (៧ លាន), ឥណ្ឌូនេស៊ី (៣ លាន), បង់ក្លាដេស (៣ លាន) និង ស្រីលង្កា (១,៥ លាន) គឺជាប្រទេសផ្គត់ផ្គង់នាំមុខនៃកម្មករទាំងនេះ។ គ្មានអ្វីដែលខុសចំពោះខ្លួនពួកគេជាមួយនឹងពលកម្មទេសន្តរប្រវេសន៍ នៅក្នុងសម័យនៃសកលភាវូបនីយកម្មនេះទេ ប៉ុន្តែ ដូចដែលបានបង្ហាញខាងក្រោម ការរំលោភបំពានអាចនាំទៅដល់ទាសភាពសម័យទំនើបបច្ចុប្បន្ន។ ការរៀបចំរចនាសម្ព័ន្ធសម្រាប់ការផ្លាស់ទីនៃពលកម្មដ៏ធំនេះ ពីប្រទេសផ្គត់ផ្គង់ទៅប្រទេសដែលមានតម្រូវការ គឺការធ្វើកិច្ចសន្យាដែលផ្តល់ដោយអ្នកជ្រើសរើស តំណាងដោយទីភ្នាក់ងារពលកម្ម និង និយោជក, កិច្ចសន្យារវាងទីភ្នាក់ងារពលកម្ម និង និយោជក ដែលយល់ព្រមដោយរដ្ឋជា "អ្នកឧបត្ថម្ភ" និង រួមទាំងអនុស្សរណៈយោគយល់រវាងរដ្ឋាភិបាលដើម និង រដ្ឋាភិបាលនៃប្រទេសដែលមានតម្រូវការ។ កិច្ចសន្យាដែលផ្តល់ដោយ

អ្នកជ្រើសរើសទៅកម្មករ មានលក្ខខ័ណ្ឌមូលដ្ឋាននៃការជួល រួមបញ្ចូលទាំងប្រាក់បៀវត្សរ៍, ម៉ោងការងារ និង រយៈពេល ព្រមទាំងបញ្ជាក់ពីកន្លែង និង អត្តសញ្ញាណរបស់និយោជក។ កម្រិតនៃបទបញ្ញត្តិ និង ការគ្រប់គ្រងកិច្ចសន្យាទាំងនេះខុសគ្នាយ៉ាងខ្លាំង។ កម្មករងាយនឹងទទួលរងការរំលោភបំពាន និង ហានិភ័យនៃសេវគតិភាពបង្ខិតបង្ខំ នៅពេលកិច្ចសន្យានោះមិនត្រូវបានគោរព ឬ ត្រូវបានជំនួសជាមួយនឹងកិច្ចសន្យាថ្មីដែលមានលក្ខខ័ណ្ឌអនុគ្រោះតិច បន្ទាប់ពីមកដល់ប្រទេសគោលដៅ។ រដ្ឋាភិបាលនៃប្រទេសដើមមានបំណងបង្ការការកេងប្រវ័ញ្ចដូចនោះ ដោយការចរចារជាកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលប្រទេសដែលមានតម្រូវការ។ រដ្ឋាភិបាលហ្វីលីពីន រួមជាមួយទីភ្នាក់ងារការងារក្រៅប្រទេសដ៏ខ្លាំងក្លារបស់ខ្លួនលេចធ្លោជាអ្នកនាំមុខគេនៅក្នុងទេសន្តរប្រវេសន៍ពលកម្មដែលមានការគ្រប់គ្រង ដោយការការពារកម្មករនៅក្រៅប្រទេសរបស់ខ្លួន។ រដ្ឋាភិបាលដើមនៃកម្លាំងពលកម្មផ្សេងទៀតមិនសូវស្វាហាប់ក្នុងការការពារកម្មកររបស់ពួកគេនៅក្រៅប្រទេសទេ។

និយោជកនៅប្រទេសដែលមានតម្រូវការ និង ទីភ្នាក់ងារពលកម្មរបស់ពួកគេស្វែងរកប្រសិទ្ធិភាពអតិបរមាពីពលករបរទេសដែលជាប់កិច្ចសន្យា។ នៅពេលដែលការការពារ និង បទបញ្ញត្តិមិនសូវគ្រប់គ្រាន់ក្នុងការទប់ស្កាត់ការរំលោភបំពាននិយោជកដែលគ្មានសីលធម៌ស្វែងរកក្រុមទន់ខ្សោយបំផុតនៃកម្មករបរទេសដើម្បីធ្វើឱ្យពួកគេរងគ្រោះ និង កេងប្រវ័ញ្ចលើពួកគេ។ រដ្ឋាភិបាលមួយចំនួនបណ្តោយនូវអាកប្បកិរិយាជញ្ជក់ឈាមអ្នកដទៃនេះដោយការនៅស្ងៀម។ រឹតតែច្បាស់នោះ "ការខិតខំអស់ពីលទ្ធភាព" កំពុងដំណើរការនៅក្នុងប្រទេសដែលមានតម្រូវការពលកម្មសំខាន់ៗមួយចំនួន ដូចដែលគេបានស្វែងរកកម្មករដែលទទួលការការពារតិចបំផុត រួមបញ្ចូលទាំងប្រជាជនវៀតណាម, បង់ក្លាដេស និង នេប៉ាល់ នៅពេលដែលគេបង្កើនការគេចចេញចំពោះកម្មករ "រុកគួន" ដែលទាមទារសិទ្ធិ និង មានរដ្ឋាភិបាលជួយពួកគេ។ ការជ្រើសរើសដូចនោះគឺអាចកើតឡើង នៅពេលដែលបទដ្ឋានសកលប្រឆាំងនឹងសេវគតិភាពបង្ខិតបង្ខំមិនត្រូវបានពង្រឹង។ នៅក្នុងកិច្ចព្រមព្រៀងទ្វេភាគី រដ្ឋាភិបាលដើមគួរតែទាមទារឱ្យមានការផ្តន្ទាទោសបែបបទឧក្រិដ្ឋនៅក្នុងតុលាការប្រទេសដែលមានតម្រូវការចំពោះករណីនៃសេវគតិភាពបង្ខិតបង្ខំ។ ដូចគ្នាផងដែរ កិច្ចព្រមព្រៀងទាំងនេះគួរតែ : ទាមទារការចុះបញ្ជីនៃកិច្ចសន្យាជាមួយភាគីទាំងអស់, ទុកឱ្យទីភ្នាក់ងារពលកម្មទទួលខុសត្រូវលើសុខមាលភាពរបស់កម្មករ និង ទាមទារការធានារ៉ាប់រង ដែលផ្តល់មូលនិធិដោយភ្នាក់ងារពលកម្ម ដើម្បីការពារកម្មករនៅក្នុងព្រឹត្តិការណ៍នៃបញ្ហាដែលអាចកើតឡើងដោយមិនបានបម្រុងទុកជាមុនដូចជាការក្ស័យធនរបស់និយោជក។

ទីភ្នាក់ងារពលកម្មជាប់កិច្ចសន្យានៅប្រទេសបង់ក្លាដេស ថ្មីៗនេះបានផ្សាយពាណិជ្ជកម្មការងារនៅរោងចក្រកាត់ដេរនៅ ហ្សកដង់។ ការផ្សាយពាណិជ្ជកម្មនោះសន្យាលើកិច្ចសន្យារយៈពេល ៣ ឆ្នាំ, ១២៥ ដុល្លា ក្នុងមួយខែ, ការងារប្រចាំថ្ងៃ ៨ ម៉ោង, ការងារ ៦ ថ្ងៃ ក្នុងមួយសប្តាហ៍, បង់ប្រាក់ចំពោះការងារលើសម៉ោង, ការស្នាក់នៅដោយឥតបង់ប្រាក់, សេវាថែទាំសុខភាពដោយឥតបង់ប្រាក់, ចំណីអាហារដោយឥតបង់ប្រាក់ និង គ្មានយកប្រាក់មុន។ ប៉ុន្តែ នៅពេលមកដល់ កម្មករ (ដែលត្រូវបានតម្រូវឱ្យបង់ប្រាក់មុនហួសប្រមាណ) ត្រូវបានគេដកហូតលិខិតឆ្លងដែនទុក, ត្រូវបានបង្ខាំងនៅក្នុងស្ថានភាពមួយដ៏លំបាក និង ត្រូវបានបង្ការពីការចាកចេញពីរោងចក្រ។ ជាច្រើនខែបានកន្លងទៅដោយមិនបានប្រាក់បៀវត្សរ៍, ចំណី

អាហារមិនគ្រប់គ្រាន់ ហើយកម្មករដែលឈឺត្រូវបានធ្វើទណ្ឌកម្ម។ ដោយសារកម្មករភាគច្រើនបានខ្ចីប្រាក់ ក្នុងអត្រាការប្រាក់ខ្ពស់ខ្លាំង ដើម្បីទទួលបានកិច្ចសន្យាការងារ តាមរយៈបំណុលនេះ ពួកគេមានកាតព្វកិច្ចត្រូវនៅតទៅទៀត។

សញ្ជាតិរបស់ជនរងគ្រោះនៃការជួញដូរគឺផ្សេងៗគ្នាទៅតាមវប្បធម៌របស់ពិភពលោក។ ជនមួយចំនួនចាកចេញពីប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីស្វែងរកការធ្វើឱ្យជីវិតរបស់ពួកគេប្រសើរឡើងតាមរយៈការងារដែលមានជំនាញទាបនៅក្នុងប្រទេសរីកចម្រើនជាង។ អ្នកមួយចំនួនទៀតក្លាយជាជនរងគ្រោះនៃពលកម្មបង្ខំ ឬ ជាប់បំណុលនៅក្នុងប្រទេសផ្ទាល់ខ្លួនរបស់ពួកគេ។ គ្រួសារមួយចំនួនបានឱ្យកូនរបស់គេទៅមនុស្សពេញវ័យដែលជាសាច់ញាតិ ឬ មិនមែនសាច់ញាតិ ដែលសន្យាផ្តល់ការអប់រំ និង ឱកាស ប៉ុន្តែបែរជាប្រគល់កូនឱ្យធ្លាក់ទៅក្នុងទាសភាពដើម្បីប្រាក់។ វិធីសាស្ត្រអនុសញ្ញាដើម្បីដោះស្រាយជាមួយពលកម្មបង្ខំ ឬ ជាប់បំណុល ជាធម្មតាផ្តោតលើការអនុលោមតាម ដែលស្ថិតនៅជាប់ជាមួយនឹងអនុសញ្ញាអន្តរជាតិ (គឺ អនុសញ្ញា ILO ២៩, ៣៩, ១០៥ និង ១៨២)។ វិធីសាស្ត្រទាំងនេះមានគោលបំណងឱ្យឧស្សាហកម្មដែលកេងប្រវ័ញ្ចនានាប្រព្រឹត្តិតាមច្បាប់ ដោយការដោះលែងជនរងគ្រោះ ឬ ការផ្តល់សំណងហិរញ្ញវត្ថុ។

វិធីសាស្ត្រនានាក្នុងការប្រយុទ្ធប្រឆាំងនឹងពលកម្មបង្ខំដែលផ្អែកលើបទដ្ឋានពលកម្ម អាចនឹងទន់ខ្សោយក្នុងការដាក់ទណ្ឌកម្មនិយោជកដែលទទួលខុសត្រូវចំពោះទម្រង់នៃការជួញដូរនេះ។ ពលកម្មបង្ខំត្រូវតែទទួលទណ្ឌកម្មជាបទឧក្រិដ្ឋតាមរយៈការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ។ នៅពេលដែលប្រទេសភាគច្រើននៅលើពិភពលោកបានដាក់ពលកម្មបង្ខំ ជាបទឧក្រិដ្ឋ ពួកគេធ្វើការតិចតួចក្នុងការផ្តន្ទាទោសអ្នកប្រព្រឹត្តិល្មើស មួយផ្នែកគឺដោយសារកង្វះការយល់ដឹងពីបញ្ហាពលកម្មបង្ខំ ក្នុងចំណោមមន្ត្រីពង្រឹងច្បាប់។ ដូចគ្នាផងដែរ ជនរងគ្រោះជានារីភេទនៃពលកម្មបង្ខំ ឬ ជាប់បំណុល ជាពិសេសគឺស្ត្រី និង ក្មេងស្រីនៅក្នុងសេវគតិភាពតាមគ្រួសារ ជាញឹកញាប់ត្រូវបានរំលោភបំពានខាងផ្លូវភេទ។

នៅរយៈពេលប៉ុន្មានឆ្នាំបន្ទាប់ ដោយទទួលការបង្គាប់ពីសភា ក្រសួងការបរទេសមានបំណងបន្តការយកចិត្តទុកដាក់បន្ថែមលើពលកម្មបង្ខំ និង ជាប់បំណុល នៅពេលដែលយើងកំពុងរក្សាយុទ្ធនាការរបស់យើងផងដែរ ប្រឆាំងនឹងការជួញដូរផ្លូវភេទ។

ប្រាក់ជ្រើសរើស និង បំណុលសម្រាប់កម្មករទេសន្តរប្រវេសន៍ : អ្នកនាំមុខចំពោះសេវគតិភាព

កម្មករបរទេសជាប់កិច្ចសន្យាជាច្រើនបានឃើញពីស្ថានភាពនៃសេវគតិភាពបង្ខិតបង្ខំនានានៅក្នុងប្រទេស "តម្រូវការ" ពលកម្មដែលត្រូវបានតម្រូវឱ្យបង់ថ្លៃមួយច្រើនគួរសម មុនពេលពួកគេទទួលបានការងារ។ ប្រាក់ទាំងនេះត្រូវបានបង់ទៅឱ្យអ្នកជ្រើសរើសពលកម្មនៅក្នុងប្រទេសដើម ឬ ក្រុមហ៊ុនពលកម្មនៅក្នុងប្រទេសតម្រូវការ ឬ វាត្រូវបានចែកឱ្យអ្នកទាំងពីរនោះ។ ប្រាក់ដែលកម្មករបរទេសត្រូវបង់ជាធម្មតាមានចាប់ពី ៤០០០ ដុល្លា ទៅ ១១០០០ ដុល្លា ហើយត្រូវបានពិពណ៌នាថាជា "ថ្លៃរកការងារឱ្យធ្វើ" ឬ "ថ្លៃការងារ"។ ប្រាក់ទាំងនេះ ជាធម្មតាខុសច្បាប់ ក្រោមច្បាប់របស់ប្រទេស

ដើម ហើយត្រូវបានហាមឃាត់ដោយកិច្ចព្រមព្រៀងអន្តរជាតិ។ គ្មានមូលដ្ឋានសមហេតុផលណាមួយដែលតម្រូវឱ្យកម្មករមានជំនាញទាបបង់ប្រាក់នោះទេ។ ទីភ្នាក់ងារជ្រើសរើសកម្មករនៅក្នុងប្រទេសដើម និង ទីភ្នាក់ងារពលកម្មនៅក្នុងប្រទេសតម្រូវការត្រូវបាននិយោជកដែលមានតម្រូវការសេវាកម្មនៃកម្មករបរទេសដែលមានជំនាញទាប ផ្តល់ប្រាក់កម្រៃជើងផ្សារឱ្យ។ ដោយមានបំណងដកប្រាក់ពីកម្មករដោយខ្លួនពួកគេផ្ទាល់ ក្រុមហ៊ុនពលកម្មគឺ "ចំណេញពីរដង" ហើយបានដាក់បន្ទុកបំណុលដ៏ធ្ងន់ធ្ងរដែលនាំឱ្យមានពលកម្មជាប់បំណុល ឬ សេរីភាពបង្ខិតបង្ខំ។ ការស្រាវជ្រាវលើសេរីភាពបង្ខិតបង្ខំក្នុងចំណោមកម្មករទេសន្តរប្រវេសន៍ជាប់កិច្ចសន្យា រកឃើញពីទំនាក់ទំនងយ៉ាងខ្លាំងរវាងលក្ខខ័ណ្ឌពលកម្មបង្ខំ និង ប្រាក់ ឬ បំណុលដ៏ធ្ងន់ធ្ងរដែលបានដាក់ឱ្យកម្មករដោយទីភ្នាក់ងារជ្រើសរើសពលកម្មនៅក្នុងប្រទេសដើម។

ទីភ្នាក់ងារការងារឯកជនមិនគួរគិតថ្លៃណាមួយ ឬ ការចំណាយណាមួយ ផ្ទាល់ ឬ មិនផ្ទាល់ ចំពោះកម្មករនោះទេ។ នេះគឺជាគោលការណ៍ដែលកំពុងទទួលបានការទទួលយក និង ការយកចិត្តទុកដាក់យ៉ាងច្រើននៅជុំវិញពិភពលោក ដូចដែលប្រទេសដើមនៃពលកម្មមួយចំនួនបានដាក់ជាបទឧក្រិដ្ឋចំពោះការដាក់ថ្លៃមិនសមហេតុផលចំពោះកម្មករ។ នេះគឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលប្រទេសដើមនៃពលកម្មក្នុងការដាក់បញ្ជាគ្រប់គ្រាន់ដល់ទីភ្នាក់ងារជ្រើសរើសពលកម្ម ដើម្បីធានាថាពលករដែលទៅបរទេសដើម្បីធ្វើការងារជាប់កិច្ចសន្យា មិនត្រូវបានទទួលបន្ទុកជាមួយនឹងការចំណាយមិនសមស្របដែលជាញឹកញាប់បំផុត នាំទៅដល់សេរីភាពបំណុលនៅពេលក្រោយ។ ក្រុមហ៊ុនជ្រើសរើសពលកម្មដែលជាប់ទាក់ទងនៅក្នុងការកេងប្រវ័ញ្ចដ៏ខ្ពស់នោះ គួរតែទទួលទណ្ឌកម្មជាបទឧក្រិដ្ឋ។ ការដាក់ទណ្ឌកម្មរដ្ឋបាលដូចជា ការពិន័យ និង ការបិទអាជីវកម្មគឺមិនគ្រប់គ្រាន់ទេ ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មនេះ។ វាគឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលដែលទទួល ឬ "តម្រូវការ" ក្នុងការការពារដោយធ្វើសកម្មជាមុនទៅលើកម្មករ ដើម្បីធានាថាពួកគេមិនទទួលរងគ្រោះដោយសារសេរីភាពបំណុល ឬ ពលកម្មបង្ខំ ហើយនៅពេលដែលបានដឹង ការស៊ើបអង្កេតឧក្រិដ្ឋកម្មដែលអាចនាំឱ្យមានការផ្តន្ទាទោសនោះ គួរតែត្រូវបានយកមកប្រើប្រាស់។

ដូចនឹងរបាយការណ៍ ២០០៥ របាយការណ៍នេះដាក់ប្រទេសជាច្រើននៅក្នុងថ្នាក់ទី ៣ ជាចំបង ដោយសារតែការខកខានរបស់ប្រទេសទាំងនោះ ក្នុងការបង្ហាញអំពីការជួញដូរនៃពលកម្មបង្ខំ ក្នុងចំណោមកម្មករទេសន្តរប្រវេសន៍បរទេស។ កិច្ចខំប្រឹងប្រែងរបស់ពិភពលោកក្នុងការលុបបំបាត់ការជួញដូរមនុស្សគឺការបង្កើតចលនាអភិវឌ្ឍន៍។ ជាលទ្ធផលនៃ TVPA ដែលផ្តោតលើជនរងគ្រោះ និង ក្រោមការដឹកនាំដែលមានសហរដ្ឋអាមេរិកជាទេ្វភាគីដ៏ខ្លាំងក្លា របាយការណ៍ប្រចាំឆ្នាំនេះបានបង្កើនចំណាប់អារម្មណ៍ពីអង្គការអន្តរជាតិ, NGOs ដែលមានភក្តីភាព និង ការយកចិត្តទុកដាក់របស់ព័ត៌មានដែលប្រកបដោយការច្នៃប្រឌិត។ ប្រទេសនានាបានធ្វើការជាមួយគ្នាច្រើនឡើង ដើម្បីបិទផ្លូវជួញដូរ, ផ្តន្ទាទោស និង កាត់ទោសអ្នកជួញដូរ ព្រមទាំង ការពារ និង ធ្វើឱ្យជនរងគ្រោះនៃការជួញដូរអាចទៅចូលរួមជាមួយសហគមន៍របស់ពួកគេឡើងវិញ។ យើងសង្ឃឹមថារបាយការណ៍ឆ្នាំនេះជម្រុញឱ្យមនុស្សគ្រប់រូបធ្វើការបានរីកចម្រើនកាន់តែប្រសើរឡើង។

ណោយជី/ម៉ាលី : ឪពុកម្ដាយរបស់ម៉ាលីក ដែលមានអាយុ ១២ ឆ្នាំ ត្រូវបានបញ្ចុះបញ្ចូលដោយគ្រូគម្ពីគូរ៉ាន ដែលជាគ្រូម្នាក់នៃក្រុមគោរពសាសនាមួយនៅណោយជី ថាគាត់នឹងនាំក្មេងប្រុសនេះទៅម៉ាលី ដើម្បីទទួលការអប់រំបន្ថែម ។ ប៉ុន្តែនៅពេលដែលម៉ាលីក និង ក្មេងប្រុសជនជាតិណោយជីផ្សេងទៀតបានចេញពីណោយជី មកដល់ម៉ាលី ពួកគេត្រូវបានបដិសេធមិនឱ្យទៅសិក្សានៅសាលា ហើយត្រូវបានបង្ខំដោយគ្រូនោះឱ្យទៅសុំទាននៅតាមដងផ្លូវក្នុងពេលជាច្រើនម៉ោង ដើម្បីរកប្រាក់ឱ្យគាត់ ។ ទីបំផុត ម៉ាលីកបានរត់គេច ។ ជនមិនស្គាល់បានជួយវាឱ្យត្រឡប់ទៅភូមិរបស់វានៅណោយជីដែលជាកន្លែងគ្រួសាររបស់វាបានទទួលវាដោយក្ដីរីករាយ បន្ទាប់ពីបានឮបទពិសោធន៍ដ៏អាក្រក់របស់វា ។

ការជួញដូរពលកម្មតាមរយៈការជ្រើសរើសស្របច្បាប់

របាយការណ៍នេះបង្ហាញពន្លឺរឹតតែច្បាស់លើបាតុភូតនៃការជួញដូរដែលឃើញមានច្រើនឡើងៗនៅអាស៊ី និង មជ្ឈិមបូព៌ា ក្នុងនោះសេវគតិភាពបានដាក់លើពលករទេសន្តរប្រវេសន៍ជាច្រើនដែលទទួលកិច្ចសន្យានៅប្រទេសផ្សេងទៀត សម្រាប់ការងារដែលមានជំនាញទាបនៅក្នុងការសាងសង់, ការផលិត, កសិកម្ម និង ជាកម្មករនៅតាមគ្រួសារ ។ មិនដូចនឹងជនទេសន្តរប្រវេសន៍គ្មានឯកសារដែលមានបំណងរត់ឆ្លងទៅក្នុងប្រទេសមួយដោយខុសច្បាប់ កម្មករទេសន្តរប្រវេសន៍ទាំងនេះត្រូវបានជ្រើសរើសដោយស្របច្បាប់នៅក្នុងប្រទេសដើមរបស់ពួកគេ ជាធម្មតានៅក្នុងប្រទេសអភិវឌ្ឍន៍តិច ហើយធ្វើដំណើរទៅប្រទេសអ្នកមានដែលមានតម្រូវការពលកម្មបរទេសតម្លៃទាប ។ បន្ទាប់ពីបានមកដល់ មួយភាគនៃកម្មករទេសន្តរប្រវេសន៍ទាំងនេះប្រឈមមុខនឹងទីភ្នាក់ពលកម្ម ឬ និយោជកអសីលធម៌ ដែលបានដាក់ពួកគេឱ្យស្ថិតនៅក្នុងស្ថានភាពនៃសេវគតិភាពបង្ខិតបង្ខំ ។ នេះអាចក្លាយជាពលកម្មបង្ខំ ឬ ពលកម្មជាប់បំណុល អាស្រ័យលើវិធីនៃការបង្ខិតបង្ខំដែលបានប្រើប្រាស់ដើម្បីបង្ខំកម្មករឱ្យចូលទៅក្នុង ឬ បន្តស្ថិតនៅក្នុងស្ថានភាពនៃសេវគតិភាព ។ កលល្បិចមួយចំនួនដែលបានប្រើប្រាស់ដោយទីភ្នាក់ងារពលកម្ម ឬ និយោជកដែលរំលោភបំពាន រួមមាន: ការផ្លាស់ប្ដូរលក្ខខ័ណ្ឌនៃការងារខុសពីអ្វីដែលបានចុះនៅលើកិច្ចសន្យាដែលបានចុះហត្ថលេខាមុនពេលកម្មករចាកចេញពីប្រទេសដើមរបស់ខ្លួន, ការដកហូត និង ការរក្សាទុកឯកសារធ្វើដំណើរ (លិខិតឆ្លងដែន, សំបុត្រយន្តហោះ និង អត្តសញ្ញាណប័ណ្ណស្នាក់នៅរបស់ជនបរទេស), ការឃុំឃាំង, ការគម្រាមកំហែងលើរាងកាយ និង ព្យួរទុកប្រាក់បៀវត្សរ៍ ។

បុព្វហេតុនៃទម្រង់នៃការជួញដូរពលកម្មនេះស្ថិតនៅក្នុងប្រភេទទូទៅពីរ : (១) ការរំលោភបំពានលើកិច្ចសន្យា និង ច្បាប់ក្នុងស្រុកដែលអភិបាលលើការជ្រើសរើស និង ការងាររបស់ពលករទេសន្តរប្រវេសន៍ និង (២) ការដាក់ថ្លៃ និង បំណុលដែលមានការរៀបចំដ៏ធ្ងន់ធ្ងរលើពលករទាំងនេះនៅក្នុងប្រទេស ឬ រដ្ឋដើម ដែលជាញឹកញាប់ជាមួយនឹងការចូលដៃ ឬ ការគាំទ្រពីទីភ្នាក់ងារពលកម្ម និង និយោជកនៅក្នុងប្រទេស ឬ រដ្ឋគោលដៅ ។ ការរំលោភបំពានលើកិច្ចសន្យាមួយចំនួន និង លក្ខខ័ណ្ឌការងារដ៏ពិបាកៗ មិនរួមដោយផ្ទាល់នៅក្នុងសេវគតិភាពបង្ខិតបង្ខំនោះទេ ប៉ុន្តែ ការប្រើប្រាស់ ឬ ការគម្រាមកំហែងកម្លាំងរាងកាយ ឬ ការបង្ខាំងដើម្បីបង្ខំកម្មករឱ្យចូលទៅក្នុង ឬ បន្តនូវពលកម្ម ឬ សេវាកម្មបែបនេះ គឺ

ជាការបង្ហាញពលកម្មបង្ខំ។ ថ្លៃដែលបានដាក់លើពលករសម្រាប់ "ឯកសិទ្ធិ" នៃការទៅធ្វើការក្រៅប្រទេសគឺប្រឆាំងនឹងបទដ្ឋានអន្តរជាតិ ហើយបានដាក់ពលករឱ្យស្ថិតនៅក្នុងស្ថានភាពមួយដែលងាយនឹងទទួលរងខ្លាំងចំពោះសេវភាពបំណុល។ ទោះជាយ៉ាងនេះក្តី ថ្លៃទាំងនេះតែឯងមិនបង្កើតឱ្យមានសេវភាពបំណុល ឬ សេវគតិភាពបង្ខិតបង្ខំនោះទេ។ នៅពេលរួមផ្សំជាមួយការអនុវត្តនីការកេងប្រវ័ញ្ចដែលធ្វើឡើងដោយទីភ្នាក់ងារពលកម្ម ឬ និយោជកដែលគ្មានសីលធមិនៅក្នុងប្រទេសគោលដៅ នៅពេលដែលវាច្រើនហួសហេតុ ថ្លៃ ឬ បំណុលទាំងនេះធ្វើឱ្យក្លាយជាទម្រង់នៃសេវភាពបំណុល។

អភូតកថានៃការផ្លាស់ទី

មនុស្សម្នាក់អាចសម្រេចធ្វើដំណើរទៅកន្លែងមួយផ្សេងទៀតដើម្បីការងារ ទាំងនៅក្នុងប្រទេសផ្ទាល់ខ្លួនរបស់គាត់ ឬ បរទេស ហើយជាផលវិបាក នៅតែធ្លាក់ចូលនៅក្នុងសេវគតិភាពបង្ខិតបង្ខំ។ រដ្ឋាភិបាល និង ទីភ្នាក់ងារពង្រឹងច្បាប់មួយចំនួនយកចិត្តទុកដាក់ដោយមិនត្រឹមត្រូវលើធម្មជាតិនៃការផ្លាស់ទីឆ្លងប្រទេសរបស់មនុស្សម្នាក់ដោយស្ម័គ្រចិត្ត ហើយខកខានមិនបានកំណត់នូវសមាសធាតុដ៏សំខាន់ជាងនេះនៃសេវាកម្មបង្ខិតបង្ខិត ឬ ពលកម្មបង្ខំដែលអាចកើតឡើងបន្ទាប់ពីនណាម្នាក់ផ្លាស់ទីដើម្បីការងារ។ ការផ្លាស់ទីទៅកន្លែងថ្មីមួយគឺជាឧប្បត្តិហេតុ។ ការបោកបញ្ឆោត ឬ ការបង្ខិតបង្ខំ ដែលអនុវត្តលើមនុស្សនោះដើម្បីឱ្យគេធ្វើការឱ្យ ឬ នៅបម្រើ "ចៅហ្វាយ" គឺជាសមាសធាតុរឹតតែច្បាស់នៃការជួញដូរនៅក្នុងទម្លាប់សម័យទំនើប។ មនុស្សដែលបានជាប់នៅក្នុងសេវាកម្មបង្ខិតបង្ខំបន្ទាប់ពីការធ្វើទេសន្តរប្រវេសន៍ដោយស្ម័គ្រចិត្តជាដំបូង ឬ ទទួលយកការងារដោយសុខចិត្ត ត្រូវបានចាត់ទុកថាជាជនរងគ្រោះពីការជួញដូរ។ ក្មេងប្រុសដែលបានបង្ខំឱ្យធ្វើការនៅក្នុងជំនួញនេសាទពាណិជ្ជកម្មលើបឹង វ៉ុលតា នៅប្រទេស ហ្គាណា គឺដូចជាជនរងគ្រោះនៃការជួញដូរមនុស្ស ជាកម្មករជនជាតិថៃដែលត្រូវបាននាំទៅសហរដ្ឋអាមេរិក ដោយមានទិដ្ឋការការងារចំការតាមរដូវស្របច្បាប់ ហើយត្រូវបានបង្ខំឱ្យធ្វើការនៅក្នុងលក្ខខ័ណ្ឌដែលមិនបានពិពណ៌នានៅលើកិច្ចសន្យាដើម ជាមួយនឹងការគម្រាមកំហែងនៃការនិរទេសដោយមិនបើកបៀវត្សរ៍ ប្រសិនបើគាត់មិនប្រព្រឹត្តិតាម "បទបញ្ញត្តិថ្មី"។

ស្ត្រីជនជាតិអ៊ុយក្រែនដែលត្រូវបានលួងលោមឱ្យទៅទីក្រុងឡុងដុង ដោយការបោកបញ្ឆោតថាផ្តល់ការងារបង្ហាញម៉ូត និង ក្រោយមកបានបង្ខំឱ្យធ្វើស្រីពេស្យា គឺដូចជាជនរងគ្រោះនៃការជួញដូរមនុស្ស ជាក្មេងស្រីជំទង់ជនជាតិប្រេស៊ីលដែលត្រូវបានជម្រុញឱ្យធ្វើជាស្រីពេស្យាចារនៅទីក្រុងកំសាន្តតាមមាត់សមុទ្រ ដោយគ្រួសាររបស់នាង។ ទម្រង់នៃសេវគតិភាព និង ការប្រឈមរបស់អ្នកទទួលរងគ្រោះបែបនេះ គឺច្រើនអនេក។

រដ្ឋាភិបាលសហរដ្ឋអាមេរិកបន្តសិក្សាអំពីដែនកំណត់ និង ធម្មជាតិនៃការជួញដូរមនុស្ស។ នៅក្នុងរបាយការណ៍នេះ យើងបានព្យាយាមចង្អុលបង្ហាញកន្លែងដែលព័តិមានត្រូវចែកចាយ និង លើកបញ្ហាដែលគួរនឹងធ្វើការស៊ើបអង្កេតបន្ថែម។ នៅក្នុងករណីមួយចំនួន កង្វះខាតព័តិមាន ឬ ព័តិមានមិនត្រឹមត្រូវពីរដ្ឋាភិបាលមិនប្រជាធិបតេយ្យអាចកម្រិតដែនកំណត់នៃរបាយការណ៍នេះ។ តាមលក្ខណៈសម្បត្តិទាំងនេះ របាយការណ៍ TIP 2006 បង្ហាញទិដ្ឋភាពថ្មីៗ និង ទូទាំងពិភពលោក

តាមធម្មជាតិ និង ដែនកំណត់នៃទាសភាពសម័យទំនើបបច្ចុប្បន្ន និង វិសាលភាពដ៏ទូលំទូលាយនៃសកម្មភាពនានាដែលធ្វើឡើងដោយរដ្ឋាភិបាលនៅជុំវិញពិភពលោក ក្នុងការប្រឈម និង លុបបំបាត់វា។

អ៊ូហ្គានដា : ម៉ាឃើលមានអាយុ ១៥ ឆ្នាំ នៅពេលដែលគាត់ត្រូវបានចាប់ដោយកងទ័ពតស៊ូរបស់ព្រះ (LRA) ដើម្បីបម្រើជាអ្នកប្រយុទ្ធនៅក្នុងកងកម្លាំងបះបោរអ៊ូហ្គានដា។ ក្នុងអំឡុងនៃការបម្រើដោយបង្ខំរបស់គាត់នៅក្នុង LRA គាត់ត្រូវបានគេឱ្យសម្លាប់ក្មេងប្រុសដែលបានព្យាយាមរត់គេច។ គាត់ក៏បានមើលឃើញក្មេងប្រុសម្នាក់ទៀតដែលត្រូវបានកាប់រហូតទាល់តែស្លាប់ ដោយសារវាមិនបានឱ្យដំណឹងទៅអ្នកយាមនៅពេលមិត្តភ័ក្ត្ររបស់វាបានរត់គេចដោយជោគជ័យ។

ផលប៉ះពាល់នៃការជួញដូរផ្លូវភេទលើសុខភាពសាធារណៈ

ទោះបីជាជនរងគ្រោះនៃការជួញដូរផ្លូវភេទមានបទពិសោធន៍លើបញ្ហាសុខភាពដ៏អាក្រក់ជាច្រើនក៏ដោយ ក៏ផលប៉ះពាល់នៃការជួញដូរផ្លូវភេទលើសុខភាពសាធារណៈមិនទាន់មានការកម្រិតចំនួននៅឡើយ។ ការត្រួតពិនិត្យលើការសិក្សាតាមតំបន់ផ្តល់នូវចំណាប់អារម្មណ៍លើរបៀបដែលការជួញដូរផ្លូវភេទធ្វើឱ្យមានគ្រោះថ្នាក់ដល់រាងកាយ និង ផ្លូវចិត្ត។ ឧទាហរណ៍ការសិក្សាលើស្ត្រី និង ក្មេងស្រីដែលត្រូវបានជួញដូរដើម្បីពេស្យាចារនៅអាហ្វ្រិកខាងកើត បានរាយការណ៍អំពីការរំលោភទូទៅ, ការរំលោភបំពានលើរាងកាយ, ការឆ្លងរោគតាមការរួមភេទ (STIs) និង HIV/AIDs [១]។ ការវាយតម្លៃនៅនេប៉ាល់នៃការជួញដូរក្មេងស្រី រកឃើញថា ៣៨% នៃជនរងគ្រោះដែលបានសង្គ្រោះ ទទួលរង HIV/AIDs ក៏ដូចជា STIs និង ជម្ងឺរបេង (TB) [២]។ ក្នុងការសិក្សាលើស្ត្រីដែលបានជួញដូរទៅសហគមន៍ អឺរ៉ុប ផលប៉ះពាល់ដល់សុខភាពរួមបញ្ចូលអំពើហឹង្សាហួសប្រមាណដែលធ្វើឱ្យបាក់ឆ្អឹង, បាត់បង់ស្មារតី និង ការរំលោភជាក្រុម។ ភាពលំបាកទាក់ទងនឹងការពន្លូតកូន, ជម្ងឺក្រពះ ពោះវៀន, ការស្រកទម្ងន់ដោយគ្មានសុខភាពល្អ, ពហុចៃ, ការបាក់ទឹកចិត្តចង់សម្លាប់ខ្លួន, ញៀនជាតិស្រវឹង និង ការប្រើប្រាស់ថ្នាំញៀនក៏ត្រូវបានរាយការណ៍ផងដែរ [៣]។ ការសិក្សាផ្សេងទៀតលើស្ត្រីដែលបានជួញដូរទៅសហគមន៍ អឺរ៉ុប បានរកឃើញថា ៩៥%នៃជនរងគ្រោះត្រូវបានចាប់បង្ខំ ឬ បង្ខិតបង្ខំដោយហឹង្សាឱ្យប្រព្រឹត្តិសកម្មភាពផ្លូវភេទ ហើយ ជនរងគ្រោះជាង ៦០% បានរាយការណ៍ថាមានភាពខ្សោយ, រោគសញ្ញាប្រព័ន្ធប្រសាទ, ជម្ងឺក្រពះ ពោះវៀន, ឈឺខ្នង, ហូរទឹករំអិលចេញពីយោនីច្រើនខុសប្រក្រតី និង រោគឆ្លងស្ត្រី [៤]។ ផលវិបាកសុខភាពជាក់ស្តែងតិចនៃការជួញដូរផ្លូវភេទអាចរួមបញ្ចូលមហារីកកស្បូនដែលបង្កឡើងដោយវីរុសសាច់ដុះក្នុងខ្លួនមនុស្ស។ នេះមានលក្ខណៈសាមញ្ញច្រើនក្នុងចំណោមស្ត្រីដែលជួបប្រទះការរួមភេទជាមួយបុរសជាច្រើន។

---

[1] Pearson, E. "Study on Trafficking in Women in East Africa." GTZ. December 2003

[2] Bal Kumar KC, Subedi G, Gurung YB, Adhikari KP. "Nepal Trafficking in Girls With Special Reference to Prostitution: A Rapid Assessment." International Labor Organization. November 2001

[3] Zimmerman, Cathy. The Health Risks and Consequences of Trafficking in Women and Adolescents: Findings from a European study. London School of Hygiene and Tropical Medicine. 2003. http://www.lshtm.ac.uk/hpu/docs/trafficking final.pdf

[4] Zimmerman, Cathy. Stolen Smiles: A Summery Report on the Physical and Psychological Consequences of Women and Adolescents Trafficked in Europe. London School of Hygiene and Tropical Medicine. 2006

នៅពេលដែលមានការសិក្សាពីរបីអំពីសុខភាពធំៗលើជនរងគ្រោះនៃការជួញដូរ ការសិក្សាដែលមានការរៀបចំល្អៗជាច្រើនអំពីផលវិបាកនៃពេស្យាចារចំពោះសុខភាព គឺមានប្រយោជន៍ក្នុងការយល់ពីឥទ្ធិពលនៃការជួញដូរផ្លូវភេទមកលើសុខភាព។ ឧទាហរណ៍ ការសិក្សាចំនួនពីរពីប្រទេសឥណ្ឌាបានរកឃើញថាអត្រា HIV គឺខ្ពស់ក្នុងចំណោមក្មេងស្រីពេស្យាជាងក្នុងចំណោមស្ត្រីពេស្យាចារ (12.5% vs. 5.4% និង 27.7% vs. 8.4%) [៥]។

អនុសាសន៍ :

ដើម្បីយល់កាន់តែច្បាស់អំពីវិសាលភាព និង ទំនាក់ទំនងទៅវិញទៅមកនៃបញ្ហាសុខភាពដែលទាក់ទងនឹងការជួញដូរផ្លូវភេទ, បញ្ហាសុខភាពទាំងនោះអាចត្រូវបានដាក់ទៅជាក្រុម ៦ រួមមាន :

១. ជម្ងឺឆ្លង : HIV, STIs និង TB

២. ជម្ងឺមិនឆ្លង : អាហារូបត្ថម្ភមិនគ្រប់គ្រាន់, បញ្ហាសុខភាពធ្មេញ, និង ជម្ងឺស្បែក

៣. បញ្ហាសុខភាពបន្តពូជ : ការពន្លូតកូនដោយបង្ខំ, មានគតិ និង ប្រសូតបុត្រមានគ្រោះថ្នាក់ខ្ពស់

៤. ការប្រើបំពានលើសារធាតុគីមី : ជាតិស្រវឹង, ថ្នាំហិត, ថ្នាំញៀនសរសៃ

៥. បញ្ហាសុខភាពផ្លូវចិត្ត : ការបាក់ទឹកចិត្ត, ជម្ងឺក្រោយពីភាពតប់ប្រមល់ធ្ងន់ធ្ងរ, អត្តឃាត

៦. អំពើហិង្សា : ការបង្ខំលើរាងកាយ និង ផ្លូវភេទ, ឃាតកម្ម

ការប្រមូលទិន្នន័យផ្អែកលើប្រភេទសុខភាពទាំងនេះនឹងអាចឱ្យ NGOs និង ភ្នាក់ងាររដ្ឋាភិបាលបង្កើតការអន្តរាគមន៍ដែលផ្អែកលើភស្តុតាងសម្រាប់ការបង្ការ និង ថែទាំជនរងគ្រោះ ក៏ដូចជាការយកចិត្តទុកដាក់លើធនធាន ដោយយោងទៅតាមតម្រូវការដែលបានរកឃើញរបស់ជនរងគ្រោះ។ នៅលើកម្រិតធំជាងនេះ ទិន្នន័យនឹងសម្របសម្រួលការបង្កើតគោលការណ៍ណែនាំលើការព្យាបាល ក៏ដូចជាអនុសាសន៍លើសុខភាពសាធារណៈក្នុងការបង្ហាញអំពីការជួញដូរផ្លូវភេទ។ វិធីសាស្ត្រនេះទាមទារ ភាពដឹកនាំពីអ្នកជំនាញសុខភាពសាធារណៈ និង ការប្រើប្រាស់វិធីសាស្ត្រ និង យុទ្ធសាស្ត្រសុខភាពសាធារណៈបែបបុរាណ។

អារ៉ាប៊ីបាយហ្សាន/ UAE : បន្ទាប់ពីឪពុករបស់ណាយឡាស្លាប់នៅពេលនាងមានអាយុ ៩ ឆ្នាំ នាងត្រូវបានប្រគល់ឱ្យមជ្ឈមណ្ឌលក្មេងកំព្រា។ ប៉ុន្តែម្តាយរបស់នាងបានយកនាងពីមជ្ឈមណ្ឌលក្មេងកំព្រា ហើយបានលក់ទៅឱ្យអ្នកជួញដូរដែលបាននាំនាងទៅ ឌូបាយ។ នាងត្រូវបានបង្ខំឱ្យធ្វើជាស្រីពេស្យាក្នុងក្លិបមួយ នៅឌូបាយ រហូតដល់នាងមានអាយុ ១៣ ឆ្នាំ។ បន្ទាប់ពីនគរបាលឌូបាយបានរកឃើញពីស្ថានភាពខុសច្បាប់របស់នាង ណាយឡាត្រូវបានគេនិរទេសត្រឡប់ទៅអារ៉ាប៊ីបាយហ្សានវិញ។ នៅពេលដែលនាងបានត្រឡប់មកអារ៉ាប៊ីបាយហ្សានវិញ នាងត្រូវបានបង្ខំឱ្យធ្វើស្រីពេស្យាបីឆ្នាំ

[5] Sarkar K, Bal B, Mukherjee R, Saha MK, Chakraborty S, Niyogi SK, Bhattachary SK. "Young age is a risk factor for HIV among female sex workers-An experience from India." Journal of Infection, 2005, (vol):1-5. and Sarkar K, Bal B, Mukherjee R, Niyogi SK, Saha MK, Bhattacharya SK. "Epidemiology of HIV Infection among Brothel-based Sex Workers in Kolkata, India." Journal of Health, Population, and Nutrition. 2005;23(3):231-235.

ទៀតមុនពេលនាងមានគតិ ។ នាងមានជម្ងឺអេដស៍មិនដឹងជានៅឪពុកបាយ ឬ បាគូ ហើយ នាងបានប្រសូតទារកម្នាក់ដែលមានមេរោគអេដស៍កាលពីឆ្នាំមុន ។

ការកំណត់អត្តសញ្ញាណជនរងគ្រោះនៃការជួញដូរ

ច្បាប់ការពារជនគ្រោះនៃការជួញដូរ (TVPA) និង ពិធីសារអង្គការសហប្រជាជាតិដើម្បីបង្ការ, បង្ក្រាប និង ដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេស ស្ត្រី និង កុមារ អំពាវនាវឱ្យរដ្ឋាភិបាលអនុវត្តជំហាននានាឱ្យបានគ្រប់គ្រាន់ ដើម្បីការពារជនរងគ្រោះនៃការជួញដូរ ។ ការការពារនោះអាចមាន លុះត្រាតែមានអត្តសញ្ញាណគ្រប់គ្រាន់របស់ជនរងគ្រោះនៃការជួញដូរ ។ របាយការណ៍ ២០០៥ បានបញ្ជាក់ពីតម្រូវការក្នុងការពិនិត្យក្រុមមនុស្សទន់ខ្សោយ ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះនៃការជួញដូរ ។ ការវាយតម្លៃមាននៅក្នុងរបាយការណ៍ឆ្នាំនេះបង្ហាញថា នៅមានសល់ការងារជាច្រើនទៀតដែលត្រូវធ្វើ ។ ការកំណត់អត្តសញ្ញាណដោយខ្លួនឯង : អភូតកថា ។ រដ្ឋាភិបាលមួយចំនួនបន្តពឹងផ្អែកលើប្រព័ន្ធ "អាស្រ័យលើការតវ៉ា" ក្នុងការកំណត់អត្តសញ្ញាណនៃឧក្រិដ្ឋកម្មជួញដូរ និង ជនរងគ្រោះនៃការជួញដូរ ។ ដោយសន្មត់ថាជនរងគ្រោះនៃការជួញដូរជាបុគ្គលម្នាក់នឹងរាយការណ៍ពីឧក្រិដ្ឋកម្មទៅអាជ្ញាធរសមស្រប ឬ នឹងកំណត់អត្តសញ្ញាណស្ថានភាពរបស់គាត់ជាជនរងគ្រោះនៃការជួញដូរនៅឱកាសដំបូង រដ្ឋាភិបាលទាំងនេះតបតតែលើករណីដែលបានរាយការណ៍ប៉ុណ្ណោះ ។ វិធីសាស្ត្រប្រតិកម្មចំពោះការជួញដូរនេះគឺមិនគ្រប់គ្រាន់ និង មិនបំពេញតាមបទដ្ឋានរបស់ TVPA ចំពោះការការពារជនរងគ្រោះនៅឡើយ ។

ភាពពិតប្រាកដ. ជនរងគ្រោះតិចតួចមានឆន្ទៈនឹងកំណត់អត្តសញ្ញាណខ្លួនពួកគេនៅពេលទាក់ទងជាដំបូងជាមួយនឹងអាជ្ញាធរពង្រឹងច្បាប់ ។ ពួកគេមានអារម្មណ៍ភ័យខ្លាចចំពោះការពិត ឬ ការសងសឹកដែលគេគិតឃើញ និង នៅតែទទួលរងរបួសផ្លូវចិត្តពីបទពិសោធន៍សេវគតិភាព ។ ពួកគេមិនអាច និង មិនត្រូវបានរំពឹងថានឹងរាយការណ៍ភ្លាម១ដោយមានគោលបំណង ចំពោះទំហំនៃការកេងប្រវ័ញ្ចលើពួកគេឡើយ ។

ការពិនិត្យដោយធ្វើសកម្មភាពជាមុន : បទដ្ឋាន ។ ការការពារជនរងគ្រោះឱ្យបានគ្រប់គ្រាន់តម្រូវឱ្យមានការវាស់ស្ទង់របស់រដ្ឋាភិបាលដោយធ្វើសកម្មភាពជាមុន ដើម្បីកំណត់អត្តសញ្ញាណនៃការជួញដូរតាមរយៈការសម្ភាសន៍ និង ការប្រឹក្សាដោយប្រុងប្រយ័ត្ន និង ហ្មត់ចត់ ។ អាជ្ញាធរពង្រឹងច្បាប់គួរតែទទួលការហ្វឹកហ្វឺនលើរបៀបកំណត់អត្តសញ្ញាណនៃការជួញដូរ ។ ការផ្តល់ទីជម្រកបណ្តោះអាសន្នដល់ជនរងគ្រោះនៅក្នុងបរិដ្ឋានមួយសុខស្រួលអាចធ្វើឱ្យជនដែលសង្ស័យថាជារងគ្រោះនៃការជួញដូរទទួលការប្រឹក្សា និង វាយតម្លៃលើជម្រើសផ្សេង១ រួមបញ្ចូលទាំងជំនួយរបស់ពួកគេលើការផ្តន្ទាទោសដល់អ្នកជួញដូរ ។

ការចំណាយរបស់មនុស្ស និង សង្គមលើការជួញដូរ

ជនរងគ្រោះនៃការជួញដូរមនុស្សចំណាយថ្លៃមួយដ៏ហួសប្រមាណ។ ផលប៉ះពាល់លើផ្លូវចិត្ត និង រាងកាយ រួមបញ្ចូលទាំងជម្ងឺ និង ការរីកលូតលាស់នៃជម្ងឺ ជាញឹកញាប់មានផលវិបាករៀងរហូត។ នៅក្នុងករណីជាច្រើន ការកេងប្រវ័ញ្ចលើជនរងគ្រោះនៃការជួញដូរគឺកើនឡើងជាលំដាប់ : ក្មេងម្នាក់ដែលបានជួញដូរក្នុងទម្រង់នៃពលកម្មមួយអាចត្រូវបានរំលោភបំពាននៅក្នុងទម្រង់មួយទៀត។ វាគឺជាការពិតដ៏ឃោឃៅនៃការជួញដូរទាសករសម័យទំនើបបច្ចុប្បន្នដែលជនរងគ្រោះជារឿយៗត្រូវបាននាំទៅ និង លក់ជាច្រើនដង ដោយញឹកញាប់ ត្រូវបានលក់ជាដំបូងដោយសមាជិកគ្រួសារ។ ជនរងគ្រោះដែលត្រូវបានបង្ខំឱ្យចូលទៅក្នុងទាសភាពផ្លូវភេទគឺជាញឹកញាប់បង្ខំដោយការប្រើថ្នាំញៀន និង ទទួលរងនូវអំពើហឹង្សាហួសហេតុ។ ជនរងគ្រោះដែលត្រូវបានជួញដូរសម្រាប់អាជីវកម្មផ្លូវភេទ ប្រឈមមុខនឹងគ្រោះថ្នាក់លើរាងកាយ និង អារម្មណ៍ពីសកម្មភាពផ្លូវភេទហឹង្សា, ការប្រើប្រាស់សារធាតុញៀនដោយបង្ខំ, ទទួលរងដោយចំហរចំពោះជម្ងឺឆ្លងតាមការរួមភេទ រួមបញ្ចូលទាំង HIV/AIDS, ការបង្អត់អាហារ និង ទារុណកម្មលើផ្លូវចិត្ត។ ជនរងគ្រោះមួយចំនួនទទួលរងគ្រោះថ្នាក់ជារៀងរហូតលើសរីរាង្គបន្តពូជរបស់ពួកគេ។ ជនរងគ្រោះជាច្រើនស្លាប់ដោយសារតែត្រូវបានគេជួញដូរ។ នៅពេលជនរងគ្រោះត្រូវបានជួញដូរទៅកន្លែងមួយដែលគាត់មិនអាចនិយាយ ឬ យល់ភាសា វាជាបន្សំនៃគ្រោះថ្នាក់ខាងផ្លូវចិត្តដែលបង្កឡើងដោយការនៅឯកោរ និង ការគាបសង្កត់ដោយអ្នកជួញដូរ។

ទំហំសិទ្ធិមនុស្ស. ជាមូលដ្ឋាន ការជួញដូរមនុស្សរំលោភលើសិទ្ធិមនុស្សជាសកលលើជីវិត និង សេរីភាព។ ការជួញដូរកុមារ រំលោភលើសិទ្ធិជាមូលដ្ឋានរបស់កុមារក្នុងការរីកលូតលាស់នៅក្នុងបរិដ្ឋានការពារមួយ និង សិទ្ធិទទួលសេរីភាពពីទម្រង់ទាំងអស់នៃការរំលោភបំពាន និង ការកេងប្រវ័ញ្ច។

ការនាំឱ្យមានការបែកបាក់សង្គម. ការបាត់បង់គ្រួសារ និង បណ្តាញគាំទ្ររបស់សហគមន៍ធ្វើឱ្យជនរងគ្រោះនៃការជួញដូរងាយនឹងទទួលរងពីតម្រូវការ និង ការគម្រាមកំហែងរបស់អ្នកជួញដូរ ព្រមទាំង ចូលរួមនៅក្នុងមធ្យោបាយជាច្រើននៃការបែកបាក់រចនាសម្ព័ន្ធសង្គម។ ការជួញដូរបំបែកកូនពីឪពុកម្តាយ និង គ្រួសារដ៏ធំរបស់ពួកគេ។ ផលចំណេញពីការជួញដូរជាញឹកញាប់ធ្វើឱ្យការអនុវត្តន៍នោះចាក់ឬសនៅក្នុងសហគមន៍ពិសេសមួយ ដែលក្រោយមកត្រូវបានកេងប្រវ័ញ្ចដដែលៗ ព្រោះវាជាប្រភពនៃជនរងគ្រោះដែលមានរួចមកហើយ។ គ្រោះថ្នាក់នៃការក្លាយជាជនរងគ្រោះនៃការជួញដូរអាចនាំឱ្យក្រុមទន់ខ្សោយដូចជាកុមារ និង ស្ត្រីវ័យក្មេងរត់លាក់ខ្លួន ជាមួយនឹងផលប៉ះពាល់មិនល្អលើការសិក្សា ឬ រចនាសម្ព័ន្ធគ្រួសាររបស់ពួកគេ។ ការបាត់បង់ការអប់រំកាត់បន្ថយឱកាសសេដ្ឋកិច្ចនាពេលអនាគតរបស់ជនរងគ្រោះ និង បង្កើនភាពទន់ខ្សោយចំពោះការជួញដូរឡើងវិញនៅពេលអនាគត។ ជនរងគ្រោះដែលអាចត្រឡប់ទៅសហគមន៍របស់ពួកគេ ជាញឹកញាប់ឃើញខ្លួនគេថាទទួលរងស្លាកស្នាមពីអតីត ឬ ត្រូវបាននិរទេស។ មានពេលខ្លះ ការជាពីរបួសផ្លូវចិត្ត អាចចំណាយពេលមួយជីវិត។

ការបណ្ដុះបណ្ដាញឧក្រិដ្ឋកម្ម. ផលចំណេញពីការជួញដូរមនុស្សបណ្ដុះនូវសកម្មភាពឧក្រិដ្ឋផ្សេងទៀត។ យោងទៅតាមការិយាល័យស៊ើបអង្កេតរបស់សហព័ន្ធ សហរដ្ឋអាមេរិក ការជួញដូរមនុស្សបង្កើតប្រាក់ចំណូលប្រចាំឆ្នាំប្រហែល ៩,៥ ពាន់លានដុល្លា។ វាជាប់ទាក់ទងយ៉ាងជិតស្និទជាមួយនឹងការលាងលុយកខ្វក់, ការជួញដូរថ្នាំញៀន, ការក្លែងបន្លំឯកសារ និង ការលួចលាក់ជួញដូរមនុស្សឆ្លងដែន។ កន្លែងដែលបណ្ដាញឧក្រិដ្ឋកម្មលូតលាស់ រដ្ឋាភិបាល និង បទបញ្ញត្តិនៃច្បាប់នៅទីនោះ ទទួលរងការរុករាន និង ចុះខ្សោយ។

ការបង្ខូចធនធានមនុស្សរបស់ប្រទេសនានា និង ការបង្ខាំងការអភិវឌ្ឍន៍. ការជួញដូរមានផលប៉ះពាល់យ៉ាងអន្តរាយលើទីផ្សារពលកម្ម ដែលរួមចំណែកចំពោះការបាត់បង់សក្ដានុពលមនុស្សដែលមិនអាចទារត្រឡប់មកវិញបាន។ ផលវិបាកនៃការជួញដូរមួយចំនួនរួមបញ្ចូលទាំងប្រៀវត្សរ៍ទាប, ផលិតភាពកម្លាំងការងារដែលទទួលការបង្អន់, ការបាត់បង់ប្រាក់ និង តំណមនុស្សដែលទទួលការអប់រំទាប។ ផលវិបាកទាំងនេះនាំទៅដល់ការបាត់បង់ផលិតភាព និង អំណាចរកចំណូលនាពេលអនាគត។ ការបង្ខំក្មេងឱ្យធ្វើការ និង ការបដិសេធមិនឱ្យពួកគេទៅទទួលការអប់រំ ពង្រឹងឡើងវិញនូវវដ្ដនៃភាពក្រីក្រ និង អនក្ខរកម្មដែលបង្អាក់ដល់ការអភិវឌ្ឍន៍របស់ប្រទេសជាតិ។ នៅពេលពលកម្មបង្ខំ ឬ ជាប់បំណុល ទាក់ទងនឹងផ្នែកដ៏សំខាន់នៃប្រជាជនរបស់ប្រទេសមួយ ទម្រង់នៃការជួញដូរនេះពន្យឺតភាពជឿនលឿនរបស់ប្រទេសនោះ ពីព្រោះជនរងគ្រោះមួយជំនាន់ ទៅមួយជំនាន់ នៅតែផុងនៅក្នុងភាពក្រីក្រ។

តម្លៃនៃសុខភាពសាធារណៈ. ជនរងគ្រោះនៃការជួញដូរជាញឹកញាប់ស៊ូទ្រាំនឹងស្ថានភាពឃោរឃៅដែលធ្វើឱ្យមានរបួសលើរាងកាយ, ផ្លូវភេទ និង ផ្លូវចិត្ត។ វីរុស និង រោគឆ្លងតាមការរួមភេទ, ជម្ងឺរលាកត្រគាក និង HIV/AIDS ជាញឹកញាប់កើតឡើងពីការទទួលរងនៅក្នុងពេស្យាចារ។ ការថប់អារម្មណ៍, ការអត់ងងុយ, ការបាក់ទឹកចិត្ត និង ជម្ងឺក្រោយពីភាពតប់ប្រមល់ធ្ងន់ធ្ងរ ជាទូទៅកើតឡើងលើផ្លូវចិត្តក្នុងចំណោមជនរងគ្រោះដែលបានជួញដូរ។ ស្ថានភាពរស់នៅគ្មានអនាម័យ និង កុះករ រួមជាមួយនឹងអាហារូបត្ថម្ភមិនគ្រប់គ្រាន់ ធ្វើឱ្យមានស្ថានភាពសុខភាពមិនល្អ ដូចជាមានជម្ងឺឆ្លងលើស្បែក, របេង និង ជម្ងឺឆ្លងផ្សេងទៀត។ ការរំលោភបំពានដ៏ធ្ងន់ធ្ងរបំផុត ជាញឹកញាប់កើតឡើងចំពោះកុមារដែលជាអ្នកងាយនឹងទទួលការត្រួតត្រា និង បង្ខំឱ្យបម្រើនៅតាមគ្រួសារ, ជម្លោះប្រដាប់អាវុធ និង ទម្រង់ការងារប្រថុយគ្រោះថ្នាក់ផ្សេងទៀត។

ការពុករលួយនៃអំណាចរបស់រដ្ឋាភិបាល. រដ្ឋាភិបាលជាច្រើនខិតខំអនុវត្តនូវអំណាចពង្រឹងច្បាប់ពេញលេញលើដែនដីប្រទេសរបស់ពួកគេ ជាពិសេសកន្លែងដែលអំពើពុករលួយគឺមានភាពទូទៅ។ ជម្លោះប្រដាប់អាវុធ, គ្រោះមហន្តរាយធម្មជាតិ និង ការតស៊ូនយោបាយ ឬ របស់ជនជាតិ អាចធ្វើឱ្យមានប្រជាជនមួយចំនួនធំផ្លាស់ទីកន្លែងនៅក្នុងប្រទេស ដែលធ្វើឱ្យពួកគេងាយទទួលរងនឹងការជួញដូរ។ ប្រតិបត្តិការជួញដូរមនុស្សធ្វើឱ្យកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលចុះខ្សោយបន្ថែមទៀត ក្នុងការប្រើប្រាស់អំណាច ដែលគម្រាមកំហែងដល់សុវត្ថិភាពរបស់ប្រជាជនទន់ខ្សោយ។ រដ្ឋាភិបាលជាច្រើនមិនអាចការពារស្ត្រី និង កុមារដែលត្រូវបានចាប់ពីផ្ទះ និង សាលារបស់ពួកគេ ឬ ពីជំរុំជនភាសខ្លួន។ លើសពីនេះទៅទៀត

សំណូកដែលបានសូកឱ្យស្ថាប័នពង្រឹងច្បាប់, មន្ត្រីអន្តោប្រវេសន៍ និង សមាជិកនៃស្ថាប័នតុលាការ បង្អាក់ដល់សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការប្រឆាំងនឹងអំពើពុករលួយ ។

រូម៉ានី : ម៉ារៀ អាយុ ១៦ ត្រូវចាញ់កលល្បិចមិត្តភ័ក្ត្រនៅពីក្មេង ឱ្យធ្វើដំណើរទៅ ប៉ូចារិស ដើម្បីស្វែងរកការងារ ។ ដោយម៉ារៀមិនដឹង មិត្តនោះបានផ្សាយពាណិជ្ជកម្មនៅទីក្រុងកំពង់ផែរូម៉ាឡេនថាមាន "ក្មេងស្រីសម្រាប់លក់" ។ ម៉ារៀត្រូវបានលក់ទៅឱ្យបុរសម្នាក់ដែលបានប្រើប្រាស់នាងជាស្រីពេស្យា ជាមួយនឹងក្មេងស្រីអាយុ ១១ ឆ្នាំម្នាក់ទៀត ។ ក្នុងពេល ៤ ខែ នាងត្រូវបានបង្ខំឱ្យធ្វើការជាស្រីពេស្យាតាមផ្លូវក្រោមការគម្រាមកំហែងនៃការវាយដំ ។ នាងត្រូវបានពិន័យ, ចាប់ខ្លួន និង សួរចម្លើយជាច្រើនដងដោយនគរបាល ប៉ុន្តែ "អ្នកការពារ" របស់នាង បានសូកនគរបាលឱ្យដោះលែងនាង ហើយបង្ខំនាងឱ្យធ្វើស្រីពេស្យាម្តងទៀត ។

វិធីសាស្ត្ររបស់អ្នកជួញដូរ

អ្នកជួញដូរទាសករធ្វើឱ្យរងគ្រោះដល់ជនទន់ខ្សោយ ។ គោលដៅរបស់ពួកគេជាញឹកញាប់គឺកុមារ និង ស្ត្រីវ័យក្មេង ហើយកលល្បិចរបស់ពួកគេគឺមានលក្ខណៈច្នៃប្រឌិត, គ្មានមេត្តា, រៀបចំឡើងដើម្បីបោកបញ្ឆោត, បង្ខំ និង ជម្នះលើទំនុកចិត្តរបស់ជនរងគ្រោះសក្តានុពល ។ ជាញឹកញាប់បំផុត ឧបាយកលទាំងនេះទាក់ទងនឹងការសន្យារៀបការ, ការងារ, ឱកាសអប់រំ ឬ ជីវិតដ៏ប្រសើរមួយ ។ ស្ថានភាពអាចកើតឡើងដែលបានប្រឌិតខាងក្រោមគឺផ្អែកលើករណីជួញដូរពិត និង តំណាងស្ថានភាពទូទៅដែលការជួញដូរកើតឡើង :

នៅកន្លែងគោលដៅមួយនៃកន្លែងគោលដៅរបស់ភ្ញៀវទេសចរនៅ ម៉ាដាកាស្កា ឪពុកម្តាយរបស់ក្មេងស្រីអាយុ ១៥ ម្នាក់ បានជម្រុញនាងឱ្យជាប់ទាក់ទងនៅក្នុងអំពើពេស្យាចារជាមួយនឹងភ្ញៀវទេសចរបុរសចំណាស់ម្នាក់ ដើម្បីជាប្រភពនៃចំណូល សម្រាប់គ្រួសាររបស់នាង ហើយក៏សង្ឃឹមផងដែរថានាងនឹងអាចរកបាននូវអាពាហ៍ពិពាហ៍, ការអប់រំ ឬ ការងារមួយនៅបរទេស ។ ប្រជាជនក្នុងតំបន់អង្កេតឃើញភ្ញៀវទេសចរមករកនាងជារឿយៗនៅ "កន្លែងកំសាន្ត" ដោយនាងស្លៀកពាក់សម្លៀកបំពាក៏របាង, បរិភោគ និង ពិសារភេជ្ជសៈជាមួយបុរសបរទេសដល់យប់ជ្រៅ ។ ផ្អែកលើព័ត៌មានដែលបានមកពីម្ចាស់សណ្ឋាគារ មន្ត្រីក្នុងស្រុកបានចាប់ចងភ្ញៀវទេសចរម្នាក់ពីការសង្ស័យនៃការធ្វើឱ្យរងគ្រោះដល់ក្មេងស្រីនេះក្នុងគោលបំណងទេសចរណ៍ផ្លូវភេទលើកុមារ ។ ប៉ុន្តែ បុរសនោះបានឱ្យប្រាក់ទៅគ្រួសាររបស់នាងមួយចំនួនតូចដើម្បីឱ្យនៅស្ងៀម និង មិនធ្វើការចោទប្រកាន់ ។

នៅរដ្ឋ សាន ភាគខាងជើងប្រទេសភូមា ស្ត្រីវ័យក្មេងម្នាក់ធ្វើដំណើរទៅខេត្ត យូណាន ប្រទេសចិន ដើម្បីស្វែងរកការងារ និង ដើម្បីរត់គេចពីស្ថានភាពសេដ្ឋកិច្ចដ៏លំបាក់ ដែលបង្ករឡើងដោយការគ្រប់គ្រងមិនត្រឹមត្រូវរបស់យោធា ។ នៅពេលទៅដល់ទីក្រុងព្រំដែនចិន នាងត្រូវបានគេផ្តល់ការងារឱ្យនៅបារ និង ភោជនីយដ្ឋានក្នុងតំបន់មួយ ។ ប៉ុន្តែ ម្ចាស់នោះ

ដឹងថានាងគឺជាជនបរទេសដែលគ្មានឯកសារនៅក្នុងប្រទេសចិន ហើយឃុំឃាំងនាងនៅក្នុងសណ្ឋាគារតូចមួយដែលនាងត្រូវបានបង្ខំឱ្យធ្វើស្រីពេស្យា នៃអាជីវកម្មផ្លូវភេទជាមួយបុរសភ្ញៀវទេសចរ និង អ្នកជួញដូរជនជាតិចិន។

នៅអាហ្វហ្គានីស្ថាន ក្មេងស្រីម្នាក់ត្រូវបានជាប់សន្យានឹងបុរសនៅក្នុងភូមិជិតគ្នាដើម្បីដោះស្រាយជម្លោះចាស់ជាយូរមកហើយរវាងគ្រួសាររបស់ពួកគេ។ ទោះបីជានៅវ័យក្មេង នាងត្រូវបានគេយកពីសាលាឱ្យទៅរៀបការជាមួយបុរសដែលនាងមិនដែលបានជួបទាល់តែសោះ។ នៅពេលនាងមកដល់ នាងត្រូវបានគេបង្ខំឱ្យចម្អិនអាហារ, បោសសម្អាត និង បម្រើគ្រួសាររបស់ប្តីនាង ក្នុងពេល ១៨-២០ ម៉ោងក្នុងមួយថ្ងៃ។ ប្រសិនបើនាងធ្វើអ្វីខុស នាងទទួលការវាយដំ ហើយ "គ្រួសារ" ថ្មីរបស់នាងគម្រាមសម្លាប់នាងប្រសិនបើនាងព្យាយាមរត់គេច។ ថ្ងៃមួយ ប្តីរបស់នាងសម្រេចចិត្តរៀបការ ជាមួយមនុស្សថ្មីម្នាក់ទៀត ដូច្នេះគាត់លក់ប្រពន្ធទីមួយរបស់គាត់ទៅឱ្យបុរសម្នាក់ទៀតដែលបង្ខំនាងឱ្យបម្រើទៅតាមតម្រូវការរបស់គាត់ និង គ្រួសារគាត់ផងដែរ។

នៅហូឡង់ ក្មេងស្រីជនជាតិនីហ្សេរីយ៉ាអាយុ ១៨ ឆ្នាំម្នាក់បានចេញពីផ្ទះ នៅ រដ្ឋ អេឌូ ដើម្បីសន្សំប្រាក់ ដូច្នេះ នាងអាចផ្ញើប្រាក់នោះទៅផ្ទះដើម្បីជួយគ្រួសាររបស់នាង។ នាងត្រូវបានណែនាំឱ្យ "មីង" របស់នាង ដែលគ្រប់គ្រងយ៉ាងតឹងរឹងចំពោះក្មេងស្រីនោះ និង បង្ខំនាងឱ្យធ្វើជាស្រីពេស្យាតាមដងផ្លូវ។ នគរបាលចាប់នាង ពីព្រោះនាងគ្មានឯកសារស្នាក់នៅស្របច្បាប់។ ពួកគេបានទុកនាងនៅក្នុងមជ្ឈមណ្ឌលឃុំឃាំង។ នាងបានទទួលឱកាសក្នុងការ "ប្តឹង" មីងរបស់នាងថាជាអ្នកជួញដូរ ប៉ុន្តែនាងបដិសេធ ដោយភ័យខ្លាចការចងព្យេរពីមិត្តភ័ក្ត្ររបស់មីងនោះនៅនីហ្សេរីយ៉ា។ នាងត្រូវបានគេនិរទេសត្រឡប់ទៅរដ្ឋ អេឌូ វិញ ដែលជាកន្លែងនាងជួបប្រទះនឹងភាពអាម៉ាសសម្រាប់ការវិលត្រឡប់វិញដោយគ្មានបានប្រាក់កាសអ្វីទាំងអស់។

វណ្ណៈ និង ទាសភាពនៅអាស៊ីខាងត្បូង

រ៉ូមេនកើតនៅកន្លែងឡឥដ្ឋតែមួយដែលឪពុក និង ជីតារបស់វាបានធ្វើការពេញមួយជីវិតរបស់ពួកគេដើម្បីសងបំណុលដែលជីតារបស់វាជំពាក់។ ក្នុងពេល ១៥ ឆ្នាំ រ៉ូមេន និង គ្រួសាររបស់វារកចំណូលបាន បី រូពី (២ សេន) ក្នុងឥដ្ឋមួយបាវដែលមានទម្ងន់ ៨០ គីឡូក្រាម ដើម្បីសងប្រាក់ ៤៥០ ដុល្លា ដែលបានឱ្យខ្ចីមុនពីអ្នកគ្រប់គ្រងឡឥដ្ឋ។ ពួកគេត្រូវបានវាយជាមួយនឹងដំបង និង វាយដោយម្ចាស់ ប្រសិនបើពួកគេមិនខំប្រឹងធ្វើការ ឬ ធ្វើឥដ្ឋបានគ្រប់គ្រាន់។ ពួកគេមិនអាចចាកចេញបានទេ ពីព្រោះម្ចាស់ឡឥដ្ឋបានគម្រាមថានឹងបាញ់ពួកគេ និង វាយពួកគេ ឬ សូកនគរបាលឱ្យចាប់ពួកគេ។ គួរឱ្យសោកស្តាយ រឿងរបស់រ៉ូមេនគឺវាជារឿងធម្មតាសម្រាប់ពលករវណ្ណៈទាបរាប់លាននាក់ ដែលត្រូវបានជឿថាជាប់នៅក្នុងសេវភាពបំណុលនៅអាស៊ីខាងត្បូង។ ពលកម្មជាប់បំណុល គឺជាទម្រង់មួយនៃការជួញដូរដែលជនរងគ្រោះខ្ចីបុលពីបុគ្គលដែលអសលីធមិ ជាញឹកញាប់មានចំនួនតិចស្មើ ១៦ ដុល្លា ហើយ ត្រូវបានបង្ខំឱ្យសងបំណុលទាំងនេះដោយការធ្វើការនៅក្នុងរោងចក្រ, ឡឥដ្ឋ និង រោងម៉ាស៊ីនកិនស្រូវដែលមានម្ចាស់ជាអ្នកឱ្យប្រាក់ពួកគេខ្ចី។ ប៉ុន្តែ បុរស, ស្ត្រី និង កុមារជាច្រើន

នៃពួកគេទាំងនេះមិនដែលបញ្ចប់ការសងបំណុលរបស់ពួកគេឡើយ ពីព្រោះថ្លៃការប្រាក់ដ៏អាក្រក់ និង ថ្លៃរស់នៅដែលបានដាក់ដោយម្ចាស់ ធ្វើឱ្យបំណុលកាន់តែកើនឡើង។ ជាញឹកញាប់ គ្រួសារទាំងមូលធ្វើការ ១៤-១៦ ម៉ោងក្នុងមួយថ្ងៃ ហើយបំណុលបានបន្តទៅអ្នកជំនាន់ក្រោយរហូតទាល់តែសងអស់។ ការរំលោភបំពានលើរាងកាយគឺមានលក្ខណៈទូទៅ ហើយពលករជាប់បំណុលភេទស្រីមួយចំនួនត្រូវបានរំលោភបំពានខាងផ្លូវភេទដោយម្ចាស់របស់ពួកគេទៀតផង។ ជាទូទៅ កុមារមិនត្រូវបានអនុញ្ញាតឱ្យចូលរៀននៅសាលា ហើយមួយចំនួនទៀតអត់ធន់នឹងរបួសដែលកើតឡើងពីការធ្វើការ។ ប្រព័ន្ធវណ្ណៈនេះគឺជាឋានានុក្រមសង្គមដែលនៅឋិតថេរនៅក្នុងវប្បធម៌ជនជាតិនៅអាស៊ីខាងត្បូងអស់រយៈពេលជាច្រើនសតវត្សមកហើយ។ ដោយការដាក់ដែនកំណត់យ៉ាងធំចំពោះជម្រើសសេដ្ឋកិច្ច និង ឱកាសសម្រាប់ភាពរីកចំរើនរបស់សមាជិកនៃប្រព័ន្ធវណ្ណៈនេះ វាធ្វើឱ្យសមាជិកភាគច្រើនទទួលការបង្ខាំងនៅក្នុងការងារទាបថោកយ៉ាងតឹងរ៉ឹង។ វាក៏បើកឱកាសឱ្យមនុស្សរាប់លានចូលទៅក្នុងទាសភាពតាមរយៈពលកម្មជាប់បំណុលផងដែរ។

យោងទៅតាមរបាយការណ៍របស់ ILO ២០០៥ ភាគច្រើនលើសលុបនៃពលករជាប់បំណុលនៅឥណ្ឌាគឺមកពីវណ្ណៈទាប។ គេបានឃើញពួកគេនោះមានចំនួនជាច្រើននៅក្នុងឧស្សាហកម្មបង្ខំពលកម្មពាសពេញឥណ្ឌា គឺរោងម៉ាស៊ីនកិនស្រូវ, ឡឥដ្ឋ, ការដ្ឋានវាយថ្ម និង ឧស្សាហកម្មកីតម្បាញវាយនភ័ណ្ឌ។ ការរើសអើងរបស់សង្គមធ្វើឱ្យពួកគេទទួលបៀវត្សរ៍ទាប ហើយសមាជិកនៃវណ្ណៈទាំងនេះ ជាញឹកញាប់ត្រូវតែខ្ចីប្រាក់ដើម្បីបំពេញតម្រូវការប្រចាំថ្ងៃរបស់ពួកគេ ដែលហេតុធ្វើឱ្យមានវដ្តនៃការកេងប្រវ័ញ្ចដ៏សាហាវពីមួយជំនាន់ទៅមួយជំនាន់។ គ្រួសារជាច្រើនជំនាន់ត្រូវបានប្រើប្រាស់នៅក្នុងទាសភាពដោយផ្អែកលើវណ្ណៈនេះ ដែលនាំឱ្យគាំងដល់ការអភិវឌ្ឍន៍នៃសហគមន៍នៅអាស៊ីខាងត្បូង។

នីហ្សេរីយ៉ា/អ៊ីតាលី ៖ ក្លូវៀបានជាប់សន្យាធ្វើការនៅទីក្រុងរ៉ូម នៅក្នុងរោងចក្រកំណាត់។ មុនពេលចាកចេញពីនីហ្សេរីយ៉ាដែលជាស្រុកកំណើតរបស់នាង នាងបានទទួលនូវពិធីវូឌូ ក្នុងបំណងរក្សាសុវត្ថិភាពរបស់នាងនៅ អ៊ីតាលី និង ធានាភាពស្មោះត្រង់របស់នាងចំពោះអ្នកឧបត្ថម្ភនាង ឬ "លោកស្រី"។ នៅពេលនាងទៅដល់ទីក្រុងរ៉ូម ក្លូវៀត្រូវបានវាយដំដោយលោកស្រីរបស់នាង ដែលជាអ្នកបានប្រាប់នាងថានាងនឹងត្រូវសងបំណុលនៃការជួញដូរដ៏ច្រើន តាមរយៈសកម្មភាពនៃពេស្យាចារប្រហែល ៤០០០ ដុង។ ក្លូវៀបានទទួលការវាយដំកាន់តែច្រើននៅពេលនាងបានបដិសេធតម្រូវការរបស់លោកស្រី។ ទីបំផុត នាងបានសុខចិត្តធ្វើតាម ទោះបីជាក្រោយមកនាងទទួលការវាយដំដោយការមិនអាចរកប្រាក់បានគ្រប់គ្រាន់ក៏ដោយ។ នៅពេលនាងមានគភ៌ ក្លូវៀត្រូវបានបង្ខំឱ្យពន្លូតកូនចេញ។ ទីបំផុត នាងមានសេចក្តីក្លាហាន ដើម្បីជំនះការគម្រាមកំហែងនៃផលកម្មវូឌូ ហើយបានរត់គេចដើម្បីទាមទារជីវិតរបស់នាងមកវិញ។ ឥឡូវនាងកំពុងបានជាស្ម័គ្រចិត្តបួលវិញនៅក្នុងទីជម្រកមួយនៅទីក្រុងរ៉ូម។

បុព្វហេតុជាច្រើននៃការជួញដូរ

បុព្វហេតុនៃការជួញដូរមនុស្សគឺស្មុគស្មាញ និង ញឹកញាប់ទាក់ទងគ្នាយ៉ាងរឹងមាំ។ តាមរយៈការមើលលើការជួញដូរមនុស្ស ជាទីផ្សារពិភពលោក ជនរងគ្រោះបង្កើតការផ្គត់ផ្គង់ ហើយ និយោជកដែលរំលោភបំពាន ឬ អ្នកកេងប្រវ័ញ្ចលើផ្លូវភេទ (គេក៏ហៅថាជាអ្នកទិញផ្លូវភេទ) តំណាងតម្រូវការ។ ទោះបីជាអតិថិជននៃផលិតផលពលកម្មបង្ខំអាចត្រូវបានចាត់ទុកផងដែរថាជាសមាសភាពនៃតម្រូវការ អតិថិជនទាំងនេះជាញឹកញាប់គឺមិនដឹងពីការទាក់ទងរបស់ពួកគេជាមួយនឹងទាសភាពទេ។ អ្នកទិញផ្លូវភេទគឺមានការចូលដៃយ៉ាងច្រើននៅក្នុងការធ្វើឱ្យរងគ្រោះដល់ជនរងគ្រោះនៃការជួញដូរផ្លូវភេទ ដូច្នេះហើយ វាគឺជាគោលដៅសមហេតុផលសម្រាប់ការអប់រំលើទំនាក់ទំនងរវាងពេស្យាចារ និង ការជួញដូរមនុស្ស។

ការផ្គត់ផ្គង់ជនរងគ្រោះត្រូវបានជម្រុញដោយកត្តាជាច្រើន រួមបញ្ចូលទាំងភាពក្រីក្រ, ការទាក់ទាញពីបទដ្ឋានរស់នៅខ្ពស់ជាងនៅកន្លែងផ្សេង, កង្វះខាតឱកាសការងារ, បណ្តាញឧក្រិដ្ឋកម្ម, អំពើហឹង្សាលើស្ត្រី និង កុមារ, ការរើសអើងចំពោះស្ត្រី, អំពើពុករលួយរបស់រដ្ឋាភិបាល, អស្ថេរភាពនយោបាយ និង ជម្លោះប្រដាប់អាវុធ។ នៅក្នុងសង្គមមួយចំនួនប្រពៃណីនៃការចិញ្ចឹមផ្គត់ផ្គង់ ធ្វើឱ្យកូនទីបី ឬ ទីបួន ត្រូវបញ្ជូនឱ្យទៅរស់នៅ និង ធ្វើការនៅទីក្រុងជាមួយនឹងសមាជិកនៃគ្រួសារធំ (ជាញឹកញាប់ គឺ "ពូ") ដោយប្តូរមកវិញនូវការសន្យាលើការអប់រំ និង ការណែនាំក្នុងការធ្វើជំនួញ។ ដោយទាញគុណសម្បត្តិពីប្រពៃណីនេះ អ្នកជួញដូរ ជាញឹកញាប់ តម្កើនខ្លួនជាទីភ្នាក់ងារការងារ ដោយបញ្ចុះបញ្ចូលឪពុកម្តាយឱ្យបែកពីកូន ប៉ុន្តែក្រោយមកជួញដូរក្មេងនេះឱ្យទៅក្នុងពេស្យាចារ, សេវគតិភាពតាមគ្រួសារ ឬ សហគ្រាសពាណិជ្ជកម្ម។ នៅចុងបញ្ចប់ គ្រួសារទទួលបានផលតិចតួច ប្រសិនបើទទួលបានប្រាក់បៀវត្សរ៍មួយចំនួន ប៉ុន្តែ កូននោះនៅតែមិនអាចទៅសាលា, ទទួលការហ្វឹកហ្វឺន និង ត្រូវបានបំបែកពីគ្រួសាររបស់គេ ហើយក្តីសង្ឃឹមលើឱកាសអប់រំ និង សេដ្ឋកិច្ច មិនដែលកើតមានជារូបរាងឡើយ។

នៅខាងផ្នែកតម្រូវការ កត្តាដែលនាំឱ្យមានការជួញដូរមនុស្សរួមបញ្ចូលទាំងឧស្សាហកម្មផ្លូវភេទ និង ការកើនឡើងនៃតម្រូវការសម្រាប់ពលកម្មកេងប្រវ័ញ្ច។ ទេសចរណ៍ផ្លូវភេទ និង រូបអាសអាភាសរបស់កុមារបានក្លាយជាឧស្សាហកម្មទូទាំងពិភពលោក ដោយមានការជួយសម្រួលពីបច្ចេកវិទ្យាដូចជា អ៊ិនធឺណិត ដែលពង្រីកជម្រើសដែលមានយ៉ាងទូលាយចំពោះ "អតិថិជន" ហើយធ្វើឱ្យមានប្រតិបត្តិការជំនួញភ្លាមៗ និង ស្ទើតែមិនអាចរកឃើញ។ ការជួញដូរក៏កើតឡើងពីតម្រូវការពិភពលោកចំពោះពលកម្មថោក, ទន់ខ្សោយ និង ខុសច្បាប់។ ឧទាហរណ៍ មានតម្រូវការយ៉ាងធំនៅក្នុងប្រទេសរីកចម្រើនមួយចំនួននៅអាស៊ី និង ឈូងសមុទ្រ សម្រាប់អ្នកបម្រើតាមគ្រួសារ ដែលមានពេលខ្លះ ពួកគេក្លាយជាជនរងគ្រោះនៃការកេងប្រវ័ញ្ច ឬ សេវគតិភាពបង្ខិតបង្ខំ។

ការជួញដូរ និង ភាពដឹកនាំរបស់មូស្លីមដែលបានលេចឡើង

នៅផ្នែកខ្លះនៃពិភពលោក អ្នកជួញដូរកំពុងប្រែក្លាយទំនាមទម្លាប់របស់ឥស្លាមបុរាណដើម្បីសម្រួលដល់ការជួញដូរមនុស្ស។ នៅប្រទេសនៃទ្វីបអាហ្វ្រិកខាងលិចជាច្រើន ឧទាហរណ៍ បុរសដែលតាំងខ្លួនជាងអ្នកប្រាជ្ញម៉ូស្លីមជ្រើសរើសក្មេងតូចៗ ពីឪពុកម្ដាយ ដោយសន្យាថាបង្រៀនក្មេងនោះនូវគម្ពីកូរ៉ាន់។ ប៉ុន្ដែ នៅពេលដែលពួកគេមានសិទ្ធិព្យាបាលលើក្មេងប្រុសទាំងនោះ បុរសទាំងនេះបានបង្ខំឱ្យក្មេងទាំងនេះដើរសុំទាន និង រំលោភបំពាន។ នៅផ្នែកខ្លះនៃអាហ្វ្រិកខាងកើត និង អាស៊ីខាងត្បូង អ្នកជួញដូរជ្រើសរើសក្មេងប្រុស, ក្មេងស្រី និង ស្ដ្រីដើម្បីការធ្វើដំណើរទៅអារ៉ាប៊ីសាអូឌី ដែលជាកន្លែងពួកគេត្រូវបានបង្ខំឱ្យធ្វើអាជីវកម្មផ្លូវភេទ, ដើរសុំទាន ឬ ធ្វើការជាអ្នកបរអូដ។

មេដឹកនាំមូស្លីមបានតបតទៅនឹងបញ្ហានេះដោយការធ្វើការជាមួយនឹងរដ្ឋាភិបាល, អង្គការក្រៅរដ្ឋាភិបាល (NGOs) និង អង្គការអន្ដរជាតិដើម្បីបង្កើនចំណេះដឹងអំពីការជួញដូរនៅក្នុងសហគមន៍របស់ពួកគេ។ មេដឹកនាំមួយចំនួនក៏បានប្រើប្រាស់សេចក្ដីសម្ដាងដែលផ្អែកលើវិជ្ជាដ៏ជ្រៅជ្រះរបស់ឥស្លាមដើម្បីការពារសិទ្ធិរបស់ស្ដ្រី និង កុមារប្រឆាំងនឹងការជួញដូរ។ នៅប្រទេសសេណេហ្គាល់ និង ណាយជឺ មេដឹកនាំមូស្លីមបានសហប្រតិបត្តិការជាមួយក្រសួងនានារបស់រដ្ឋាភិបាល និង UNICEF ដើម្បីប្រឆាំងនឹងការជួញដូរ។ នៅប្រទេសឥណ្ឌូនេស៊ី NGO មួយឈ្មោះ ស្ថាប័ន ហ្វាមីណា (Fahmina Institute) ដែលបង្កើតឡើងដោយ Kyai Husein Muhammad (សូមមើលផ្នែក TIP Heroes នៃរបាយការណ៍នេះ ដើម្បីទទួលព័ត៌មានបន្ថែម) ចែកចាយខិត្តប័ណ្ណផ្សព្វផ្សាយ ២២.000 សន្លឹក ប្រឆាំងនឹងការជួញដូរមនុស្សជារៀងរាល់សប្ដាហ៍ នៅព្រះវិហារឥស្លាមនានា បន្ទាប់ពីការបួងសួងនៅថ្ងៃសុក្រ។ Kyai Husein ក៏បានសរសេរយ៉ាងទូលំទូលាយលើការប្រើប្រាស់ច្បាប់ឥស្លាម និង ការបង្រៀនដើម្បីប្រឆាំងនឹងការជួញដូរ។

នៅបង់ក្លាដេស NGO ក្នុងស្រុកមួយបានឱ្យលោកសង្ឃមូស្លីម ២១00 អង្គ រំលឹកចំពោះគ្រោះថ្នាក់, ការគម្រាមកំហែង និង បែបបទនៃការជួញដូរ និង បានធ្វើការហ្វឹកហ្វឺនដល់អ្នកហ្វឹកហ្វឺនសម្រាប់លោកសង្ឃមូស្លីម ១00 អង្គ។ ជាលទ្ធផល លោកសង្ឃមូស្លីមជាង ២៥00 អង្គបានថ្លែងសារប្រឆាំងនឹងការជួញដូរមួយចំនួន ក្នុងអំឡុងពេលផ្ដល់ការបួងសួងនៅថ្ងៃសុក្រ ដែលបានផ្សព្វផ្សាយដល់ជនជាតិបង់ក្លាដេសរាប់លាននាក់។ ការរួមចំណែករបស់សហគមន៍មូស្លីមក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ បង្កើនក្ដីសង្ឃឹមថាសារប្រឆាំងនឹងការជួញដូរនឹងបានព្រាសពេញពិភពលោក។

អនីតិជនដែលគ្មានអ្នកមកតាម, ការជួញដូរ និង ការកេងប្រវ័ញ្ច

ចាប់តាំងពីឆ្នាំ ២០០៤ កុមារជាតិចិន ១២០ នាក់ត្រូវបានរាយការណ៍ថាបាត់ខ្លួនពីមជ្ឈមណ្ឌលអន្តោប្រវេសន៍ស៊ុយអែត។ នៅគ្រប់ករណីទាំងអស់ កុមារទាំងនោះបានមកដល់ប្រទេសស៊ុយអែតតាមយន្តហោះពីទីក្រុងប៉េកាំង ឬ មូស្គូ ហើយភ្លាមៗនោះបានស្នើសុំសិទ្ធិជ្រកកោននយោបាយ។ ក្នុងរយៈពេលប៉ុន្មានថ្ងៃ ពួកគេបានបាត់ខ្លួននៅពេលដែលករណីរបស់គេមិនទាន់បានសម្រេចនៅឡើយ។ ព័ត៌មានគន្លឹះនៃការស៊ើបអង្កេតបញ្ជាក់ពីទីកន្លែងដែលគេឆ្ពោះទៅរួមមាន ប្រទេសដាណាម៉ាក់, អាល្លឺម៉ង់, អ៊ីតាលី, បារាំង និង ហូឡង់។ អាជ្ញាធរពង្រឹងច្បាប់របស់ស៊ុយអែតជឿជាក់ថាបណ្ដាញរបស់អ្នកជួញដូរ គឺនៅពីក្រោយការបាត់ខ្លួននេះ។

អនីតិជនដែលគ្មានអ្នកមកតាម (UAMs) អាចត្រូវបានបញ្ឆោតពីប្រទេសដើមរបស់ពួកគេក្រោមការធ្វើពុតមិនត្រឹមត្រូវ ឬ អាចធ្លាក់ខ្លួនជាជនរងគ្រោះនៃការជួញដូរកេងប្រវ័ញ្ច បន្ទាប់ពីពួកគេមកដល់បរទេស។ ការធ្វើឱ្យរងគ្រោះដល់ពួកគេគឺជាព័ត៌មានដ៏សំខាន់ជារូបភាពនៃការជួញដូររបស់ពិភពលោក។ ទោះបីជាពួកគេមានភាគរយតិច ប្រៀបធៀបទៅនឹងប្រជាជនសរុបនៃជនទេសន្តរប្រវេសន៍បរទេសនៅអ៊ឺរ៉ុប UAMs គឺមានភាពទន់ខ្សោយយ៉ាងខ្លាំងចំពោះការជួញដូរទាំងក្នុងគោលបំណងនៃការជួញដូរផ្លូវភេទ និង ពលកម្មបង្ខំ។

ពួកគេជាទូទៅមកពីប្រទេសនៅអ៊ឺរ៉ុបកណ្ដាល និង ខាងកើត, អាហ្វ្រិក និង អាស៊ី។ ពួកគេត្រូវបានកេងប្រវ័ញ្ចតាមមធ្យោបាយជាច្រើនរួមបញ្ចូលទាំងពេស្យាចារ, ជាអ្នកនាំថ្នាំញៀន, ជាអ្នកបម្រើតាមគ្រួសារ, ធ្វើការនៅកន្លែងការងារដែលលំបាកខ្លាំង ឬ ភោជនីយដ្ឋាន, តាមបណ្ដាញក្រុមសុំទាន និង ក្រុមចោរឆក់ ហើយ ក្រោយមកទទួលលទ្ធផលជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

អង្គការក្រៅរដ្ឋាភិបាល (NGOs) ដែលគួរឱ្យទុកចិត្តមួយចំនួន បានសម្គាល់នូវលំនាំអាថ៌កំបាំងរបស់អនីតិជនជាតិចិនដែលគ្មានអ្នកមកតាម ដឹងថាពួកគេមកដល់អ៊ឺរ៉ុបដោយមានទូរស័ព្ទចល័ត, សាច់ប្រាក់ និង គ្មានផែនការធ្វើដំណើរច្បាស់លាស់ ដែលភ្លាមៗក្រោយមកបាត់ខ្លួនពីកន្លែងអាជ្ញាធរ និង មជ្ឈមណ្ឌលទទួល។ វាអាចដែលថា UAMs ទាំងនេះបានបាត់ខ្លួន នៅពេលពួកគេបានទាក់ទងជាមួយបណ្ដាញឧក្រិដ្ឋកម្ម។ អនីតិជនដែលគ្មានអ្នកមកតាម ដែលត្រូវបានកេងប្រវ័ញ្ចពីឧក្រិដ្ឋជន ជាញឹកញាប់មិនត្រូវបានស្គាល់ថាជាជនរងគ្រោះ ឬ ត្រូវបានស៊ើបអង្កេតជាករណីនៃការជួញដូរឡើយ។ កុមារដែលបានជួញដូរទាមទារការការពារជាមូលដ្ឋាន និង ការធ្វើឱ្យមាននីតិសម្បទាឡើងវិញ។ ការទាក់ទងជាដំបូងរបស់កុមារជាមួយអាជ្ញាធរ នៅប្រទេសគោលដៅ អាចជាឱកាសដ៏ល្អបំផុតដើម្បីបញ្ឈប់ចង្វាក់នៃការជួញដូរ។

អាហ្វហ្គានីស្ថាន : ណាស៊ីមាត្រូវបានបង្ខំដោយម្ដាយរបស់នាងឱ្យរៀបការនៅអាយុ ៤ឆ្នាំ ជាមួយនឹងអ្នកជិតខាងអាយុ ៣០ ឆ្នាំ នៅភូមិអាហ្វហ្គាន។ នៅផ្ទះរបស់ប្ដីនាង ឪពុកក្មេករបស់នាង និង សមាជិក ១២ នាក់ផ្សេងទៀតនៅក្នុង

គ្រួសារបានចាប់ផ្តើមធ្វើទារុណកម្មនាង។ ការព្យាបាទរួមមានការវាយដំ និង បង្អត់អាហារ ហើយនាងត្រូវបានបង្ខំឱ្យដេក នៅខាងក្រៅផ្ទះដែលត្រជាក់ខ្លាំងដោយមានតែកម្រាលមួយដើម្បីការពារនាង។ អ្នករំលោភបំពានលើនាង ជាញឹកញាប់ បានប្រើប្រាស់នាងជាតុមនុស្ស បង្ខំនាងឱ្យនាងដេកផ្កាប់ ដូច្នេះពួកគេអាចកាត់ចំណីអាហាររបស់ពួកគេលើខ្នងទទេរបស់នាង។ មានពេលមួយនោះ ឪពុកក្មេករបស់នាងបានចាក់សោរនាងនៅក្នុងរោងតូចមួយក្នុងរយៈពេល ២ ខែ ហើយនាងត្រូវបាន អនុញ្ញាតឱ្យចាកចេញម្តងក្នុងមួយថ្ងៃ។ នៅយប់មួយមុនពេលនាងបានរត់គេចនៅអាយុ ១២ ឆ្នាំ ក្នុងឆ្នាំ ២០០៥ ឪពុកក្មេក របស់នាងបានចងដៃរបស់នាង ហើយបានចាក់ទឹកក្តៅលើក្បាលរបស់នាង។ នាងបានរត់គេចខ្លួននៅថ្ងៃបន្ទាប់ ដោយភ័យ ខ្លាចការស្លាប់នៅក្នុងដៃរបស់គ្រួសារប្តីរបស់នាង ហើយត្រូវបានរកឃើញដោយអ្នកបររទេះរុញសដែលបានយកនាងទៅកាន់ មន្ទីរពេទ្យដើម្បីព្យាបាល។ នាងបានចំណាយពេលលើសពីមួយខែដើម្បីជាសះពីរបួសផ្សេងៗដែលមានលើខ្លួននាង។ ឥឡូវ នាងស្ថិតនៅក្នុងទីជម្រកមួយ និង បានទៅសាលារៀន។

ក្រសួងការពារជាតិ (DOD) តបតទៅនឹងការជួញដូរពលកម្មនៅអ៊ីរ៉ាក់

ការស៊ើបអង្កេតរបស់ DOD ថ្មីៗ ដែលធ្វើឡើងភ្លាមៗបន្ទាប់ពីការនិយាយរបស់ព័ត៌មាននៅចុងឆ្នាំ ២០០៥ អំពី ការជួញដូរពលកម្មនៅអ៊ីរ៉ាក់ បានកំណត់អត្តសញ្ញាណនៃការរំលោភបំពានមួយចំនួន ដែលចំនួនខ្លះនៃការរលោភនោះត្រូវ បានចាត់ទុកថាទូទៅ ដែលបានធ្វើឡើងដោយក្រុមហ៊ុនជាប់កិច្ចសន្យា ឬ អនុក្រុមហ៊ុនជាប់កិច្ចសន្យារបស់ DOD នៃកម្មករ ប្រទេសទីបី (TCN) នៅអ៊ីរ៉ាក់។ ការរំលោភបំពានទាំងនេះមួយចំនួនត្រូវបានគូសបញ្ជាក់ពីការជួញដូរមនុស្ស និង រួមបញ្ចូល ទាំង : ការរឹបទុកលិខិតឆ្លងដែនរបស់ TCN ខុសច្បាប់, ការអនុវត្តន៍ការជួលដោយមិនសុខចិត្ត និង ប្រាក់ជ្រើសរើសខ្ពស់ ហួសប្រមាណ, ស្ថានភាពរស់នៅក្រោមបទដ្ឋាន និង ការគេចវៀងពីនីតិវិធីអន្តោប្រវេសន៍របស់អ៊ីរ៉ាក់។ TCN ជាច្រើនគឺ ជាកម្មករដែលមានជំនាញទាបពីនេប៉ាល់, ឥណ្ឌា, ប៉ាគីស្ថាន, បង់ក្លាដែស, ស្រីលង្កា និង ហ្វីលីពីន។

ក្រសួងការពារជាតិបានតបតយ៉ាងឆាប់រហ័សជាមួយនឹងសកម្មភាពមួយចំនួន ដើម្បីត្រួតពិនិត្យយ៉ាងជិតដិតចំពោះ ការជួល និង ការងាររបស់ពលករបរទេស។ នៅខែមេសាឆ្នាំ ២០០៦ ឧត្តមសេនីយ George W. Casey ជាអគ្គមេបញ្ជាការ នៃកងកម្លាំងពហុជាតិនៅអ៊ីរ៉ាក់ បានចេញនូវសេចក្តីណែនាំលើពលកម្មមួយចំនួនទៅឱ្យក្រុមហ៊ុនជាប់កិច្ចសន្យា ជាមួយ ក្រសួងការពារជាតិ នៅអ៊ីរ៉ាក់ និង អាហ្វហ្គានីស្ថាន។ សកម្មភាពដ៏សំខាន់ក្នុងចំណោមសកម្មភាពទាំងនោះគឺ ការបញ្ជាដោយ អាជ្ញាឱ្យក្រុមហ៊ុនជាប់កិច្ចសន្យាទាំងអស់បញ្ឈប់ការអនុវត្តន៍លើការរក្សាទុក ឬ ដកលិខិតឆ្លងដែនរបស់និយោជិក។ លើស ពីនោះទៅទៀត កិច្ចសន្យារបស់ DOD នឹងរួមបញ្ចូលនូវសេចក្តីណែនាំខាងក្រោមដើម្បីបង្ការការជួញដូរមនុស្ស :

- និយោជិកទាំងអស់របស់ក្រុមហ៊ុនជាប់កិច្ចសន្យា ឬ អនុក្រុមហ៊ុនជាប់កិច្ចសន្យាជាមួយក្រសួងការពារជាតិ នឹង ទទួលឯកសារកិច្ចសន្យាការងាររបស់ពួកគេដែលបានចុះហត្ថលេខារួចមួយច្បាប់ ដែលកំណត់ពីលក្ខខ័ណ្ឌនៃការងារ និង តម្លៃរបស់ពួកគេ។

- ក្រុមហ៊ុនជាប់កិច្ចសន្យា និង អនុក្រុមហ៊ុនជាប់កិច្ចសន្យាត្រូវតែជាក្រុមហ៊ុនជ្រើសរើសដែលមានអាជ្ញាប័ណ្ណ។
- ក្រុមហ៊ុនជ្រើសរើសមិនត្រូវយកថ្លៃជ្រើសរើសខុសច្បាប់ពីនិយោជិក។

ក្រោមគោលការណ៍នេះ ក្រុមហ៊ុនជាប់កិច្ចសន្យា និង អនុក្រុមហ៊ុនជាប់កិច្ចសន្យា ត្រូវបានតម្រូវឱ្យប្រព្រឹត្តិតាមបទដ្ឋានកន្លែងរស់នៅផ្ទាល់ខ្លួន, ច្បាប់អន្តរជាតិ និង របស់ប្រទេសម្ចាស់ផ្ទះសម្រាប់ទិដ្ឋការការងារ និង និតិវិធីឆ្លងកាត់ និង ចូលប្រទេស។ ការតបតនេះធ្វើឡើងដើម្បីធានាថាសហរដ្ឋអាមេរិកប្រើប្រាស់គោលការណ៍ "គ្មានការអត់ឱន" ប្រឆាំងនឹងការជួញដូរមនុស្សទាំងក្នុងស្រុក និង បរទេស។

ការលក់កូនក្រមុំ

អតុល្យភាពភេទដែលកំពុងកើនឡើងនៅតំបន់នៃអាស៊ីខាងត្បូង និង ខាងកើត កំពុងនាំឱ្យមានតម្រូវការកើនឡើងចំពោះជនរងគ្រោះនៃការជួញដូរ។ នៅប្រទេសចិន ទោះបីជាការពេញចិត្តកូនប្រុសគឺជាកត្តាចំបងនៅពីក្រោយអត្រាភេទដែលខុសគ្នា គោលការណ៍កូនមួយ និង ភាពក្រីក្ររបស់ប្រទេស ក៏បានធ្វើឱ្យកើនឡើងចំពោះការផ្គត់ផ្គង់ និង តម្រូវការសម្រាប់ការជួញដូរកូនក្រមុំ។ គតិភេទស្រី ជាញឹកញាប់ត្រូវបានពន្លូតចេញ ហើយមានរបាយការណ៍ថា នៅក្នុងករណីជាច្រើន ទារកភេទស្រីត្រូវបានសម្លាប់នៅពេលកើត ជាហេតុធ្វើឱ្យបុរសមានចំនួនច្រើនជាងស្ត្រីនៅផ្នែកខ្លះនៃប្រទេសដោយក្មេងប្រុស ១១៧ លើ ក្មេងស្រី ១០០ នាក់។

ប៉ុន្តែ បុរសនៅតែមានអារម្មណ៍ពីសម្ពាធសង្គមចំពោះការរៀបការ ធ្វើឱ្យអ្នកមួយចំនួនដែលមិនអាចស្វែងរកស្ត្រីដែលអាចរៀបការបាន ព្យាយាមទិញកូនក្រមុំពីតំបន់ផ្សេងទៀតនៅក្នុងប្រទេស ឬ ពីតំបន់ព្រំដែនជាមួយប្រទេសជិតខាងដូចជាកូរ៉េខាងជើង។ ស្ត្រីទាំងនេះ ដែលជាញឹកញាប់ត្រូវបានលក់ដោយឪពុកម្តាយរបស់ពួកគេ ឬ ត្រូវបានចាប់ពីភូមិរបស់ពួកគេ ត្រូវបានបង្ខំឱ្យរៀបការ, ធ្វើពេស្យាចារ ឬ សហាយ។ កន្លែងដែលពេញនិយមចំពោះការជួញដូរកូនក្រមុំក្នុងស្រុកគឺកន្លែងដែលក្រនៃខេត្តរបស់ប្រទេសចិនដីគោក ដែលភាពក្រីក្រធ្វើឱ្យស្ត្រីកាន់តែមានភាពទន់ខ្សោយចំពោះការជួញដូរ។ ជាទូទៅ អ្នកជួញដូរលក់ក្មេងស្រី និង ស្ត្រីទាំងនេះ នៅក្នុងខេត្តដែលមានឱនភាពភេទស្រីយ៉ាងធំ។ ការពិត អ្នកជំនាញមួយចំនួនជឿជាក់ថា ការចាប់ និង ការលក់ស្ត្រីបានកើនឡើង នៅពេលដែលការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ចិនបានពន្លឿន ហើយការជួញដូរទាំងនោះមានចំនួន ៣០-៩០ ភាគរយនៃការរៀបការនៅក្នុងភូមិមួយចំនួន។

ប្រទេសឥណ្ឌាក៏ជួបប្រទះបញ្ហាស្រដៀងគ្នានៃអតុល្យភាពនៃភេទនេះដែរនៅក្នុងតំបន់មួយចំនួន ទោះបីជាវាត្រូវបានបង្ហាញឡើងជាចំបងដោយឥរិយាបទវប្បធម៌ដែលមើលឃើញក្មេងស្រីជាបំណុលសេដ្ឋកិច្ច ដោយសារតម្រូវការចំណងដៃពីកូនកំលោះដែលមានសក្តានុពល។ ស្ថិតិរបស់រដ្ឋបង្ហាញពីអតុល្យភាពភេទគួរឱ្យកត់សម្គាល់នៅក្នុងតំបន់សំខាន់មួយចំនួន: នៅ ចាមមូ និង កាស្មៀរ មានក្មេងប្រុស ១១១ លើក្មេងស្រី ១០០ នាក់, អុតតា ប្រាដេស មាន ១១១, ស៊ីគគី មាន

១១៤, ពុនចាប មាន ១១៤ (រដ្ឋធានី ចាន់ឌីហ្គា ១២៩) និង ហារាយ៉ានា ១១៦ តាមជំរឿន ២០០១។ គម្លាតភេទនេះបាន ធ្វើឱ្យមានបុរសជាច្រើនលានលើសស្ត្រីនៅក្នុងទីផ្សាររៀបអាពាហ៍ពិពាហ៍ ដែលបង្កើតឱ្យមាន "ការរឹតបន្តឹងអាពាហ៍ពិពាហ៍" និង ដាក់សម្ពាធឱ្យបុរសស្វែងរកស្ត្រីដើម្បីរៀបអាពាហ៍ពិពាហ៍។ ជាផលវិបាក មានករណីមួយចំនួនដែលស្ត្រីពីប្រទេស នេប៉ាល, បង់ក្លាដេស និង តំបន់ផ្សេងទៀតនៃឥណ្ឌាត្រូវបាននាំមក ឬ ចាប់ជាកូនក្រមុំសម្រាប់ "ភូមិបុរសនៅលីវ"។ កង្វះ ខាតស្ត្រីក៏រួមចំណែកដល់តម្រូវការដ៏ធំសម្រាប់ស្ត្រី និង ក្មេងស្រីពេស្យា ដែលបង្កើននូវតម្រូវការ សម្រាប់ជនរងគ្រោះនៃ ការជួញដូរ។ កូនក្រមុំដែលបានជួញដូរ ជាញឹកញាប់ត្រូវបានបង្អួចទឹកចិត្តពីការរាយការណ៍ស្ថានភាពរបស់ពួកគេ ឬ ការរត់ គេច ដោយសារតែសម្ពាធសង្គម និង សេដ្ឋកិច្ច ដែលតម្រូវឱ្យស្ថិតនៅក្នុងជីវិតអាពាហ៍ពិពាហ៍, កង្វះខាតភាពស្គាល់ច្បាស់ តំបន់ដែលពួកគេត្រូវបានជួញដូរទៅ, ការចូលដៃជើងរបស់នគរបាល ឬ មន្ត្រីដែលបង្ខិតបង្ខំឱ្យត្រឡប់មកវិញ នៅពេលកូន ក្រមុំរត់គេច, ច្បាប់ដែលធ្វើឱ្យស្ត្រីដែលបានជួញដូររងគ្រោះម្តងទៀតដោយការចាត់ថ្នាក់ និង ការផ្តន្ទាទោសពួកគេជាជន បរទេសខុសច្បាប់ និង ការរើសអើងរបស់សង្គមដែលពួកគេទំនងនឹងជួបប្រទះប្រសិនបើពួកគេត្រឡប់ទៅផ្ទះរបស់ពួកគេ វិញ។

លីបេរីៈ អតីតទាហានកុមារអាយុ ១៣ ឆ្នាំ មកពីលីបេរីរ៉ាយរ៉ាប់ថាៈ "ពួកគេបានឱ្យថ្នាំគ្រាប់ដែលធ្វើឱ្យខ្ញុំឆ្កួត។ នៅពេលដែលភាពឆ្កួតមាននៅក្នុងក្បាលរបស់ខ្ញុំ ខ្ញុំវាយក្បាលមនុស្ស និង ធ្វើឱ្យគេឈឺច្បាប់រហូតគេហូរឈាម។ នៅពេល ដែលភាពឆ្កួតចេញពីក្បាលរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍ថាខ្ញុំមានកំហុស។ ប្រសិនបើខ្ញុំចាំមនុស្សនោះ ខ្ញុំបានទៅរកពួកគាត់ និង បានសុំទោស។ ប្រសិនបើពួកគាត់មិនបានទទួលនូវការសុំទោសរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍មិនល្អទេ"។

ការធ្វើការដើម្បីបញ្ចប់តម្រូវការលើជនរងគ្រោះនៃការជួញដូរផ្លូវភេទ

រដ្ឋាភិបាលសហរដ្ឋអាមេរិកប្រឆាំងនឹងអំពើពេស្យាចារ និង សកម្មភាពដែលទាក់ទងទាំងឡាយ រួមបញ្ចូលទាំង ការនាំស្រីបន, ការធ្វើមេអណ្តើក និង ការរក្សាផ្ទះបន គឺជាការរួមចំនែកចំពោះបាតុភូតនៃការជួញដូរមនុស្ស។ សកម្មភាព ទាំងនេះ គឺមានផលប៉ះពាល់យ៉ាងខ្លាំង និង ជាអំពើអមនុស្សជាតិ។ ជំហរនេះគឺត្រូវបានចងជាច្បាប់នៅក្នុង សេចក្តីបង្គាប់ របស់ប្រធានាធិបតីលើសុវត្ថិភាពជាតិ (NSPD-22) ហើយត្រូវបានបញ្ជាក់បន្ថែមទៀតនៅក្នុងការគាំទ្ររបស់រដ្ឋបាល សម្រាប់ច្បាប់ផ្តល់អំណាចឡើងវិញលើការការពារជនរងគ្រោះនៃការជួញដូរ (TVPRA) ឆ្នាំ ២០០៥ ដែល "នាំការយក ចិត្តទុកដាក់យ៉ាងសំខាន់ចំពោះការបន្ថយតម្រូវការលើសកម្មភាពអាជីវកម្មផ្លូវភេទដែលបណ្តុះនូវការជួញដូរផ្លូវភេទ"។

នៅខែមករា ឆ្នាំ ២០០៦ លោកប្រធានាធិបតី George W. Bush បានចុះហត្ថលេខាលើ TVPRA ឱ្យទៅជាច្បាប់ ដែលថ្លែងថា "យើងមិនអាចដាក់ឧក្រិដ្ឋជនឱ្យនៅក្រៅធុរៈកិច្ចបានទេ រហូតទាល់តែយើងបង្ករភាពលំបាកដល់បញ្ហានៃ តម្រូវការនោះ។ អ្នកដែលបានចំណាយដើម្បីទទួលឱកាសរំលោភបំពានផ្លូវភេទលើកុមារ និង ក្មេងស្រីជំទង់ត្រូវតែទទួល ខុសត្រូវ។ ដូច្នេះយើងនឹងស៊ើបអង្កេត និង ផ្តន្ទាទោសអតិថិជន, មនុស្សពេញវ័យអសីលធម៌ដែលបានធ្វើឱ្យរងគ្រោះដល់

ក្មេង និង ជនស្លូតត្រង់"។ ច្បាប់ថ្មីមានបញ្ញត្តិក្នុងស្រុកដែលមានគោលបំណងបន្ថយតម្រូវការចំពោះជនរងគ្រោះនៃការជួញដូរផ្លូវភេទ។ វាបានផ្តល់ប្រាក់ឱ្យរដ្ឋាភិបាលក្នុងតំបន់ចំនួន ២៥ លាន ដុល្លា ដោយ អគ្គមេធាវី ទៅឱ្យរដ្ឋនានា និង ស្ថាប័នពង្រឹងច្បាប់ក្នុងតំបន់ដើម្បី : ស៊ើបអង្កេត និង ផ្តន្ទាទោសអ្នកទិញជំនួញផ្លូវភេទ, អប់រំបុគ្គលដែលបានចោទប្រកាន់ ឬ បុគ្គលដែលមានគោលបំណងទិញជំនួញផ្លូវភេទ និង សហប្រតិបត្តិការជាមួយ NGOs ក្នុងតំបន់ដែលមានជំនាញក្នុងការផ្តល់សេវាកម្មដល់ជនរងគ្រោះ។ ច្បាប់ថ្មីក៏បានផ្តល់ប្រាក់ ១០ លាន ដុល្លា ឱ្យរដ្ឋាភិបាល និង NGOs ក្នុងតំបន់ តាមរយៈក្រសួងសុខភាព និង សេវាកម្មមនុស្ស ដើម្បីជួយអ្នករួចផុតពីការជួញដូរមនុស្ស និង ការកេងប្រវ័ញ្ចនៃជំនួញផ្លូវភេទ។

យុទ្ធសាស្ត្រដ៏មានប្រសិទ្ធិភាពក្នុងការប្រយុទ្ធប្រឆាំងការជួញដូរ

ដើម្បីទទួលបានប្រសិទ្ធិភាព យុទ្ធសាស្ត្រប្រឆាំងការជួញដូរត្រូវតែផ្តោតទាំងខាងផ្គត់ផ្គង់ (អ្នកជួញដូរ) និង ខាងតម្រូវការ (ម្ចាស់, អតិថិជន ឬ ក្នុងករណីនៃការជួញដូរផ្លូវភេទ គឺអ្នកទិញផ្លូវភេទ)។ ខាងផ្នែកផ្គត់ផ្គង់ លក្ខខ័ណ្ឌដែលនាំឱ្យមានការជួញដូរត្រូវតែដោះស្រាយតាមរយៈកិច្ចខំប្រឹងប្រែង : រំលឹកសហគមន៍នានាអំពីគ្រោះថ្នាក់នៃការជួញដូរ, បង្កើន និង ពង្រីកឱកាសអប់រំ និង សេដ្ឋកិច្ចសម្រាប់ក្រុមទន់ខ្សោយ, លើកតម្កើនឱ្យមានការអប់រំស្មើភាពគ្នា, អប់រំមនុស្សទាក់ទងនឹងសិទ្ធិស្របច្បាប់របស់ពួកគេ និង បង្កើនឱកាសជីវិតដ៏ប្រសើរ និង ទូលំទូលាយ។ ទាក់ទងនឹងអ្នកជួញដូរ ស្ថាប័នពង្រឹងច្បាប់ត្រូវតែ : ផ្តន្ទាទោសយ៉ាងខ្លាំងក្លាដល់អ្នកជួញដូរ និង អ្នកបានជួយ និង ផ្សំគំនិតជាមួយពួកគេ, ប្រឆាំងអំពើពុករលួយសាធារណៈដែលសម្រួល និង ទទួលផលចំណេញពីការជួញដូរ, កំណត់អត្តសញ្ញាណ និង ហាមផ្លូវជួញដូរតាមរយៈការប្រមូលផ្តុំ និង សម្របសម្រួលដោយសម្ងាត់ដ៏ល្អ, ធ្វើឱ្យមានតល្លាភាពលើនិយមន័យច្បាប់នៃការជួញដូរ និង សម្របសម្រួលការទទួលខុសត្រូវរបស់ស្ថាប័នពង្រឹងច្បាប់ ព្រមទាំងហ្វឹកហ្វឺនបុគ្គលិកឱ្យស្គាល់អត្តសញ្ញាណ និង គ្រប់គ្រងជនរងគ្រោះនៃការជួញដូរឱ្យមានការថែទាំសមស្រប។ នៅខាងផ្នែកតម្រូវការ អ្នកដែលបានកេងប្រវ័ញ្ចលើមនុស្សដែលបានជួញដូរ ត្រូវតែបានកត់សម្គាល់ និង ផ្តន្ទាទោស។ និយោជកនៃពលកម្មបង្ខំ និង អ្នកកេងប្រវ័ញ្ចជនរងគ្រោះនៃការជួញដូរផ្លូវភេទ ត្រូវតែបង្ហាញឈ្មោះ និង ទទួលទណ្ឌកម្មដ៏សមស្រប។ ទាក់ទងនឹងទាសភាពផ្លូវភេទ យុទ្ធនាការយល់ដឹងជាសាធារណៈត្រូវតែធ្វើឡើង នៅប្រទេសគោលដៅដើម្បីធ្វើឱ្យកាន់តែលំបាកចំពោះការលាក់បាំង និង មិនអើពើលើការជួញដូរ។ ជនរងគ្រោះត្រូវតែទទួលការសង្គ្រោះ, ផ្តល់និតិសម្បទាឡើងវិញ, ឱ្យគេទៅរួមរស់ជាមួយគ្រួសាររបស់ពួកគេ ឬ ទទួលនូវជម្រើសផ្សេងៗ ប្រសិនបើមិនអាចត្រឡប់ទៅសហគមន៍ដើមរបស់ពួកគេ។ កិច្ចខំប្រឹងប្រែងក្នុងស្រុក, រដ្ឋ, ប្រទេស និង តំបន់ក្នុងការប្រយុទ្ធនឹងការជួញដូរត្រូវតែទទួលការសម្របសម្រួល។ ដោយការទាញការយកចិត្តទុកដាក់របស់សាធារណៈចំពោះបញ្ហានេះ រដ្ឋាភិបាលនានាអាចបញ្ចូលការគាំទ្ររបស់សាធារណៈ។ យុទ្ធសាស្ត្រ និង កម្មវិធីប្រឆាំងការជួញដូរ ដែលបង្កើតឡើងជាមួយនឹងការចូលរួមពីអ្នកទាក់ទងនានា (សង្គមស៊ីវិល និង NGOs) គឺមានប្រសិទ្ធិភាពបំផុត និង ទំនងជាទទួលជោគជ័យច្រើន នៅពេលដែលពួកគេនាំមកនូវទស្សនៈដ៏ទូលំទូលាយចំពោះបញ្ហា។

ប្រទេសនានាគួរសហការឱ្យកាន់តែជិតស្និទ្ធក្នុងការបដិសេធអ្នកជួញដូរតាមផ្លូវច្បាប់ និង ជួយសម្រួលបត្យាប័ននៃពួកគេចំពោះការផ្តន្ទាទោស។ ការសហការដូចនោះគួរតែមានគោលបំណងជួយសម្រួលដោយស្ម័គ្រចិត្ត និង មេត្តាផងដែរ ដល់ការមាតុភូមិនិវត្តរបស់ជនរងគ្រោះ។ កម្មវិធីដែលការពារសាក្សីគួរតែបានជម្រុញឡើង។ ចំណេះដឹងអំពីការជួញដូរត្រូវតែយល់ដឹងឱ្យកាន់តែខ្លាំងជាបន្តបន្ទាប់ និង ប្រព័ន្ធនៃការរៀបចំ និង កិច្ចខំប្រឹងប្រែងប្រឆាំងការជួញដូរគួរតែពង្រឹងឡើង។ ស្ថាប័នសាសនា, NGOs, សាលា, សមាគមសហគមន៍ និង អ្នកដឹកនាំបែបបុរាណត្រូវការបង្កើតឱ្យមានចលនា និង នាំឱ្យមានការពុះពារតស៊ូ។ ជនរងគ្រោះ និង គ្រួសាររបស់ពួកគេគឺជាអ្នកទាក់ទងដ៏សំខាន់នៅក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ។ រដ្ឋាភិបាលនានាត្រូវតែវាយតម្លៃឡើងវិញតាមពេលចំពោះយុទ្ធសាស្ត្រ និង បញ្ហាប្រឆាំងការជួញដូររបស់ពួកគេ ដើម្បីធានាថាវានៅតែមានប្រសិទ្ធិភាព ដើម្បីតបតនឹងវិធីសាស្ត្រ និង របៀបថ្មីៗរបស់អ្នកជួញដូរ។

ជាទីបញ្ចប់ មន្ត្រីរដ្ឋាភិបាលត្រូវតែទទួលការហ្វឹកហ្វឺននូវបច្ចេកទេស និង វិធីសាស្ត្រប្រឆាំងការជួញដូរ ហើយ លំនាំ និង និន្នាការនៃការជួញដូរត្រូវតែត្រួតពិនិត្យឱ្យបានល្អិតល្អន់ដើម្បីឱ្យយល់កាន់តែច្បាស់ពីធម្មជាតិ និង ទំហំរបស់បញ្ហា ដូច្នេះគោលការណ៍សមស្របដែលតបត អាចធ្វើឡើងយ៉ាងប៉ិនប្រសព្វ និង ត្រូវបានចាប់ផ្តើមឡើង។

សិង្ហបុរី : ជនជាតិឥណ្ឌូនេស៊ីអាយុ ២០ ឆ្នាំម្នាក់ ដែលពីមុនជាស្រីបម្រើនៅប្រទេសសិង្ហបុរី ចងចាំនូវអ្វីដែលបានទទួលការរំលោភបំពាន : "និយោជកនឹងខឹង.... ប្រសិនបើនាងខឹងខ្លាំង នាងនឹងទះខ្ញុំជាច្រើនដង។ ខ្ញុំមិនទាន់បញ្ចប់កិច្ចសន្យារបស់ខ្ញុំនៅឡើយ។ នាងបាននិយាយថាខ្ញុំមិនអាចទៅផ្ទះបានទេ។ ខ្ញុំមិនអាចទ្រាំបាន។ នៅពេលដែលខ្ញុំបានប្រាប់ទីភ្នាក់ងារថានិយោជកបានទះខ្ញុំ នាងគ្រាន់តែបាននិយាយថា 'អ្នកត្រូវតែរងទុក្ខ។ អ្នកគួរតែគ្រប់គ្រងអារម្មណ៍របស់អ្នក'។ ប្រសិនបើស្រីបម្រើមិនទាន់បានបញ្ចប់ការកាត់ប្រាក់ខែរបស់នាង (ការបង់ប្រាក់មុនដែលឱ្យដោយទីភ្នាក់ងារ/និយោជក) ហើយនាងហៅទូរស័ព្ទទៅទីភ្នាក់ងារ ទីភ្នាក់ងារនោះខឹង។ ទីភ្នាក់ងារនោះក៏បានទះខ្ញុំ។ ពួកគេមិនចង់ឱ្យខ្ញុំចាកចេញដោយមិនទាន់បញ្ចប់កិច្ចសន្យា និង ការកាត់ប្រាក់ខែ"។

ការការពារជនរងគ្រោះ

TVPA ផ្តល់ឱ្យយើងនូវវិធីសាស្ត្រផ្តោតលើជនរងគ្រោះដើម្បីបង្ក្រាបពីការជួញដូរ ជាគោលបំណងរួមផ្សំនៃការប្រឆាំងនឹងឧក្រិដ្ឋកម្ម និង សិទ្ធិមនុស្ស។ ដោយគ្មានការការពារគ្រប់គ្រាន់ដល់ជនរងគ្រោះ កិច្ចខំប្រឹងប្រែងក្នុងការបង្ក្រាបពីឧក្រិដ្ឋកម្មមិនទំនងជាមានប្រសិទ្ធិភាព។ លក្ខណៈវិនិច្ឆ័យរបស់ TVPA សម្រាប់ការវាយតម្លៃកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការការពារជនរងគ្រោះនៃការជួញដូរ រួមបញ្ចូលបទដ្ឋានវិនិច្ឆ័យលើការការពារជនរងគ្រោះ : *"មិនថារដ្ឋាភិបាលនៃប្រទេសមួយការពារជនរងគ្រោះនៃទម្រង់ជួញដូរមនុស្សធ្ងន់ធ្ងរបែបណាមួយ និង លើកទឹកចិត្តដោយផ្តល់ជំនួយក្នុងការស៊ើបអង្កេត និង ផ្តន្ទាទោសលើការជួញដូរនោះ រួមបញ្ចូលទាំងបញ្ញតិសម្រាប់ជម្រើសផ្លូវច្បាប់ចំពោះការបណ្តេញទៅប្រទេសដែលពួកគេនឹងប្រឈមការដាក់ទោស ឬ ភាពលំបាក ព្រមទាំងធានាថាជនរងគ្រោះនោះមិនត្រូវបានឃុំ*

ខ្លួន, ពិន័យដោយមិនសមស្រប ឬបើមិនដូច្នោះទេ ទទួលការដាក់ទណ្ឌកម្មចំពោះសកម្មភាពខុសច្បាប់តែមួយ ដែលជាលទ្ធផលផ្ទាល់នៃការដែលត្រូវបានជួញដូរ"។

ការប្រតិបត្តិល្អបំផុតក្នុងការអនុវត្តនីបទដ្ឋានវិនិច្ឆ័យ TVPA រួមបញ្ចូល :

ទី១ រដ្ឋាភិបាលមួយគួរតែកំណត់អត្តសញ្ញាណជនរងគ្រោះនៃការជួញដូរជាមុន។ ដោយគ្មានអត្តសញ្ញាណរបស់ជនរងគ្រោះ ការការពារគ្រប់គ្រាន់គឺមិនអាចមាន។ ទីភ្នាក់ងាររដ្ឋាភិបាលគួរតែបង្កើតការត្រួតពិនិត្យផ្លូវការ និង នីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះដើម្បីពិនិត្យមើលជនដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ដូចជាមនុស្សដែលក្រែងចំពោះការប្រព្រឹត្តិល្មើសលើច្បាប់អន្តោប្រវេសន៍, ច្បាប់ពេស្យាចារ និង ច្បាប់សុំទាន ឬ ពលកម្ម។ ជនរងគ្រោះនៃការជួញដូរមិនបានសង្ឃឹមថាអាចកំណត់អត្តសញ្ញាណដោយខ្លួនគេផ្ទាល់ទេ។ បច្ចេកទេសស៊ើបអង្កេតជាមុន តាមរយៈការសម្ភាសន៍នៅក្នុងបរិដ្ឋានដែលមានសុវត្ថិភាព និង គ្មានការគម្រាមកំហែង ជាមួយនឹងអ្នកប្រឹក្សាដែលបានទទួលការហ្វឹកហ្វឺន និង សេវាកម្មភាសាសមស្រប គួរតែត្រូវបានប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណលើការបញ្ជាក់ណែនាំអំពីការជួញដូរ។

ទី២ នៅពេលដែលបានកំណត់អត្តសញ្ញាណរួច ជនសង្ស័យថាជាជនរងគ្រោះនៃការជួញដូរ គួរតែទទួលនូវការថែទាំជាបណ្តោះអាសន្នជាជនរងគ្រោះនៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរ។ នេះអាចរួមបញ្ចូលទាំងទីជម្រក និង ការប្រឹក្សាដែលអាចឱ្យជនរងគ្រោះសក្តានុពលរ៉ាយរ៉ាប់បទពិសោធន៍របស់គាត់ចំពោះមុខអ្នកប្រឹក្សាសង្គមដែលទទួលការហ្វឹកហ្វឺន និង មន្ត្រីពង្រឹងច្បាប់នៅទីកន្លែងដែលមានសម្ពាធទាបបំផុត។

ទី៣ ជនរងគ្រោះនៃការជួញដូរដែលបានបញ្ជាក់មិនគួរទទួលទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មដែលជាលទ្ធផលផ្ទាល់នៃការដែលត្រូវបានជួញដូរ ដូចជាមិនមានឯកសារអន្តោប្រវេសន៍ស្របច្បាប់ ឬ ការប្រព្រឹត្តិល្មើសលើខបញ្ញត្តិនៃពេស្យាចារ, ពលកម្ម ឬ ការសុំទាន។ ជនរងគ្រោះនៃការជួញដូរមិនគួរទទួលការឃុំឃាំងបែបឧក្រិដ្ឋកម្ម បន្ទាប់ពីពួកគេត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះ នៅកន្លែងឃុំឃាំង លើកលែងតែមានកាលៈទេសៈហួសហេតុ។ ពួកគេគួរតែទទួលការគោរពជាជនរងគ្រោះ។

ទី៤ ជនរងគ្រោះនៃការជួញដូរដែលបានបញ្ជាក់គួរតែទទួលការលើកទឹកចិត្តឱ្យសហការជាមួយអាជ្ញាធរពង្រឹងច្បាប់នៅក្នុងការស៊ើបអង្កេតឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិមកលើពួកគេ។ លើសពីនេះទៀត ប្រសិនបើអាច ពួកគេគួរតែទទួលការលើកទឹកចិត្តឱ្យជួយនៅក្នុងការផ្តន្ទាទោសមនុស្សដែលបានជួញដូរ ឬ កេងប្រវ័ញ្ចលើពួកគេ។

ចុងបញ្ចប់ ជនរងគ្រោះនៃការជួញដូរដែលមិនចង់ ឬ មិនអាចសហការនៅក្នុងការផ្តន្ទាទោសពីការជួញដូរអាចត្រឡប់ទៅសហគមន៍ដើមរបស់គេ ដោយផ្តល់ឱ្យថាការវិលត្រឡប់នេះគឺសម្រេចបាននៅក្នុងលក្ខណៈមួយទទួលខុសត្រូវជាមួយនឹងការរៀបចំជាមុនសម្រាប់ការវិលត្រឡប់ និង ការចូលទៅវិញរបស់ជនរងគ្រោះដោយសុវត្ថិភាព។ ទោះជាយ៉ាង

នេះក្ដី ជនរងគ្រោះគួរតែទទួលនូវជម្រើសផ្លូវច្បាប់ចំពោះការបណ្ដេញទៅប្រទេសដែលនាងនឹងប្រឈមភាពលំបាក ឬ ការដាក់ទោស។ ជនរងគ្រោះនៃការជួញដូរមិនគួរប្រឈមនឹងការនិរទេស ឬ ត្រឡប់ទៅវិញដោយបង្ខំ និងដោយគ្មានការការពារ ឬ សកម្មភាពផ្សេងទៀតក្នុងការបន្ថយគ្រោះថ្នាក់នៃភាពលំបាក, ការដាក់ទោស ឬ ការជួញដូរម្ដងទៀត។

តើអ្វីជាទេសចរណ៍ផ្លូវភេទលើកុមារ?

រាល់ឆ្នាំ កុមារជាងមួយលាននាក់ត្រូវបានកេងប្រវ័ញ្ចនៅក្នុងការជួញដូរអាជីវកម្មផ្លូវភេទពិភពលោក។ ទេសចរណ៍ផ្លូវភេទលើកុមារ (CST) ទាក់ទងនឹងមនុស្សដែលធ្វើដំណើរពីប្រទេសផ្ទាល់ខ្លួនរបស់ពួកគេទៅប្រទេសផ្សេងទៀត និងទាក់ទងនឹងសកម្មភាពអាជីវកម្មផ្លូវភេទជាមួយកុមារ។ CST គឺជាការរំលោភបំពានដ៏គួរឱ្យខ្មាសលើសេចក្ដីថ្លៃថ្នូររបស់កុមារ និង ទម្រង់នៃការរំលោភបំពានលើកុមារដោយហឹង្សា។ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារមានផលវិបាកដ៏អាក្រក់។ ភ្ញៀវទេសចរដែលទាក់ទងនៅក្នុង CST ជាញឹកញាប់ធ្វើដំណើរទៅប្រទេសកំពុងអភិវឌ្ឍន៍ស្វែងរកភាពអនាមិក និង ភាពអាចរកកុមារនៅក្នុងផ្លូវពេស្យាចារបាន។ ជាទូទៅ ឧក្រិដ្ឋកម្មនេះទទួលការជម្រុញពីស្ថាប័នពង្រឹងច្បាប់ទន់ខ្សោយ, អំពើពុករលួយ, អ៊ិនធឺណិត, ភាពងាយស្រួលនៃការធ្វើដំណើរ និង ភាពក្រីក្រ។ អ្នកប្រមាថលើផ្លូវភេទទាំងនេះមានមកពីសាវតាសង្គមសេដ្ឋកិច្ចទាំងអស់ និង អាចកាន់តួនាទីដែលមានការទុកចិត្ត។

ការតបតរបស់ពិភពលោក

រយៈពេល ៥ ឆ្នាំកន្លងមក មានការកើនឡើងលើការផ្ដន្ទាទោសដល់ជនល្មើសនៃទេសចរណ៍ផ្លូវភេទលើកុមារ។ យ៉ាងហោចណាស់មាន ៣២ ប្រទេសមានច្បាប់ក្រៅដែនដីដែលអនុញ្ញាតឱ្យមានការផ្ដន្ទាទោសដល់ពលរដ្ឋរបស់ពួកគេចំពោះឧក្រិដ្ឋកម្ម CST ដែលបានប្រព្រឹត្តិនៅក្រៅប្រទេស។ តបតទៅនឹងបាតុភូតដ៏អាក្រក់នេះ NGOs, ឧស្សាហកម្មទេសចរណ៍ និង រដ្ឋាភិបាលនានាបានចាប់ផ្ដើមបង្ហាញពីបញ្ហា។ អង្គការទេសចរណ៍អន្តរជាតិ (WTO) បានបង្កើតកម្លាំងការងារដើម្បីប្រឆាំងនឹង CST។ WTO, NGO *បញ្ចប់ពេស្យាចារលើកុមារ, រូបអាសអាភាសរបស់កុមារ និង ការជួញដូរកុមារក្នុងគោលបំណងផ្លូវភេទ* (ECPAT) ហើយ អ្នកចាត់ការដំណើរទេសចរណ៍ណ័រឌិកបានបង្កើត *ក្រមសីលធម៌សម្រាប់ការការពារកុមារពីការកេងប្រវ័ញ្ចអាជីវកម្មផ្លូវភេទនៅក្នុងការធ្វើដំណើរ និង ទេសចរណ៍* ពិភពលោក ក្នុងឆ្នាំ ១៩៩៩។ នៅខែមិនា ២០០៥ ក្រុមហ៊ុនទេសចរណ៍ ១០០ ដែលមកពីប្រទេស ១៨ បានចុះហត្ថលេខាលើក្រមនេះ។ (សូមចូលទៅ www.thecode.org)

តើសហរដ្ឋអាមេរិកកំពុងធ្វើអ្វី

នៅឆ្នាំ ២០០៣ សហរដ្ឋអាមេរិកបានពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងនឹងទេសចរណ៍ផ្លូវភេទលើកុមារដោយការឆ្លងកំណែច្បាប់កាត់ទោស និង មធ្យោបាយផ្សេងទៀតដើម្បីបញ្ចប់ការកេងប្រវ័ញ្ចអាជីវកម្មលើកុមារ (PROTECT) និង ច្បាប់ផ្តល់អំណាចឡើងវិញលើការការពារជនរងគ្រោះនៃការជួញដូរ។ ច្បាប់ទាំងនេះរួមគ្នា បង្កើនការពិន័យដាប់ពន្ធធនាគារអតិបរមាដល់៣០ ឆ្នាំ ចំពោះការទាក់ទងនៅក្នុង CST ។ ចាប់តាំងពីការឆ្លងនៃច្បាប់ PROTECT មានការចោទប្រកាន់របស់តុលាការជាង ២០ ករណី និង មានការកាត់ទោសជាង ១២ ករណីលើភ្ញៀវទេសចរផ្លូវភេទលើកុមារ។ ក្រសួងសុវត្ថិភាពក្នុងប្រទេសបានបង្កើតអង្គប្រឆាំងជនប្រតិបត្តិការ ជាដំបូងដើម្បីប្រយុទ្ធនឹងការកេងប្រវ័ញ្ចលើកុមារ, រូបអាសអាភាសរបស់កុមារ និង ទេសចរណ៍ផ្លូវភេទលើកុមារ។ សហរដ្ឋអាមេរិកក៏កំពុងផ្តល់មូលនិធិដល់ NGO *ទស្សនៈពិភពលោក (World Vision)* ដើម្បីបង្កើនការយល់ដឹងសាធារណៈជាចំបង, ការធ្វើឱ្យញញើត និង គម្រោងបង្ការឧក្រិដ្ឋកម្មនៅបរទេស។

រដ្ឋាភិបាលនានាគួរដែលដាក់អាទិភាពលើបញ្ហានេះ, ព្រៀងផែនការសកម្មភាពដោយផ្អែកលើការស្រាវជ្រាវយ៉ាងទូលំទូលាយ និង ចាត់តាំងអ្នកសម្របសម្រួលឱ្យទាក់ទងនឹង NGOs, អង្គការអន្តររដ្ឋាភិបាល និង ឧស្សាហកម្មទេសចរណ៍។ ច្បាប់ក្រៅដែនដីត្រូវតែហាមឃាត់ទម្រង់នៃទេសចរណ៍ផ្លូវភេទលើកុមារគ្រប់ប្រភេទ និង ត្រូវពង្រឹងជាមួយនឹងការកាត់ទោសដែលឆ្លុះបញ្ចាំងពីធម្មជាតិដ៏សាហាវនៃឧក្រិដ្ឋកម្ម។ រដ្ឋាភិបាលនានាគួរតែហ្វឹកហ្វឺនមន្ត្រីពង្រឹងច្បាប់, ផ្តល់មូលនិធិដល់យុទ្ធនាការយល់ដឹងសាធារណៈ និង រៀបចំទីជម្រក និង ជំនួយដល់ជនរងគ្រោះ។

ផ្នែកធ្វើដំណើរ និង ទេសចរណ៍កំពុងទទួលស្គាល់ថាពួកគេមានតួនាទីយ៉ាងសំខាន់ក្នុងការដើរតួរហ្វឹកហ្វឺនបុគ្គលិករបស់ពួកគេឱ្យរាយការណ៍អកប្បកិរិយាសង្ស័យ និង រំលឹកដល់អ្នកធ្វើដំណើរនូវច្បាប់ដែលទាក់ទង។ ផ្នែកឯកជនក៏គួរតែបង្កើត និង ពង្រឹងគោលការណ៍រួបរួមដ៏មាំមួន ដែលបដិសេធការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និង ទទូចឱ្យក្រុមហ៊ុនជាប់កិច្ចសន្យា និង អ្នកផ្គត់ផ្គង់របស់ពួកគេធ្វើដូចគ្នា។ បុគ្គលម្នាក់ៗត្រូវតែធានាថាពួកគេមិនស្ថិតនៅក្នុងផ្នែកនៃបញ្ហា ដែលជាតម្រូវការ ប៉ុន្តែជាផ្នែកនៃដំណោះស្រាយ ដោយការរាយការណ៍ឧប្បត្តិហេតុទៅឱ្យនគរបាលក្នុងស្រុក, ស្ថានទូតសហរដ្ឋអាមេរិក ឬ តាមទូរស័ព្ទបន្ទាន់របស់អន្តោប្រវេសន៍ និង គយសហរដ្ឋអាមេរិក តាមលេខ 1-866-DHS-2ICE ។

ការកំណត់អត្ថន័យ "ការជួញដូរមនុស្ស"

ច្បាប់ការពារជនរងគ្រោះនៃការជួញដូរកំណត់អត្ថន័យ "ទម្រង់នៃការជួញដូរមនុស្សធ្ងន់ធ្ងរ" ជា ៖

(ក) **ការជួញដូរផ្លូវភេទ** ដែលក្នុងនោះ **សកម្មភាពអាជីវកម្មផ្លូវភេទ** កើតឡើងដោយការបង្ខំ, ការបោកបញ្ឆោត ឬ **ការបង្ខិតបង្ខំ** ឬ ដែលក្នុងនោះ មនុស្សដែលត្រូវបាននាំឱ្យទៅធ្វើសកម្មភាពដូចនោះមិនទាន់មានអាយុ ១៨ ឆ្នាំ ឬ

(ខ) ការជ្រើសរើស, ការផ្តល់កន្លែងស្នាក់នៅ, ការធ្វើដំណើរ, ការផ្តល់ឱ្យ ឬ ការទទួលមនុស្សម្នាក់ ដើម្បីពលកម្ម ឬ សេវាកម្ម តាមរយៈការបង្ខំ, ការបោកបញ្ឆោត ឬ ការបង្ខិតបង្ខំ ក្នុងគោលបំណងនៃ**សេវកតិភាពបង្ខិតបង្ខំ**, ភាពជាកម្មករ, **សេវភាពបំណុល** ឬ ទាសភាព ។

និយមន័យពាក្យ

"ការជួញដូរផ្លូវភេទ" មានន័យថា ការជ្រើសរើស, ផ្តល់កន្លែងស្នាក់នៅ, ការធ្វើដំណើរ, ការផ្តល់ឱ្យ ឬ ការទទួលមនុស្សម្នាក់ ក្នុងគោលបំណងនៃសកម្មភាពអាជីវកម្មផ្លូវភេទ ។

"សកម្មភាពអាជីវកម្មផ្លូវភេទ" មានន័យថា សកម្មភាពផ្លូវភេទទាំងឡាយណាកើតឡើងដោយសារតម្លៃនានាត្រូវបានផ្តល់ទៅឱ្យ ឬ បានទទួលដោយមនុស្សណាម្នាក់ ។

"ការបង្ខិតបង្ខំ" មានន័យថា (ក) ការគម្រាមកំហែងដែលផ្តល់ទុក្ខទោសដ៏ធ្ងន់ធ្ងរចំពោះនណាម្នាក់ ឬ ការបង្ខាំងរាងកាយនណាម្នាក់, (ខ) គ្រោងការណ៍, ផែនការ ឬ លំនាំណាមួយដែលមានបំណងធ្វើឱ្យមនុស្សម្នាក់ជឿជាក់ថា ការខកខានក្នុងការធ្វើសកម្មភាពនោះនឹងមានលទ្ធផលជាទុក្ខទោសដ៏ធ្ងន់ធ្ងរចំពោះនណាម្នាក់ ឬ ការបង្ខាំងរាងកាយនណាម្នាក់ ឬ (គ) ការរំលោភបំពាន ឬ ការរំលោភបំពានដោយគម្រាមកំហែងលើនីតិវិធីច្បាប់ ។

"សេវកតិភាពបង្ខិតបង្ខំ" រួមបញ្ចូលទាំងលក្ខខ័ណ្ឌនៃសេវកតិភាពដែលកើតឡើងដោយមធ្យោបាយនៃ (ក) គ្រោងការណ៍, ផែនការ ឬ លំនាំណាមួយដែលមានបំណងធ្វើឱ្យមនុស្សម្នាក់ជឿជាក់ថា ប្រសិនបើគេមិនចូលទៅក្នុង ឬ បន្តនៅក្នុងស្ថានភាពដូចនោះ គេ ឬ មនុស្សដទៃទៀតនឹងទទួលរងទុក្ខទោសធ្ងន់ធ្ងរ ឬ ការបង្ខាំងរាយកាយ ឬ (ខ) ការរំលោភបំពាន ឬ ការរំលោភបំពានដោយគម្រាមកំហែងលើនីតិវិធីច្បាប់ ។

"សេវភាពបំណុល" មានន័យថាស្ថានភាព ឬ លក្ខខ័ណ្ឌរបស់កូនបំណុល កើតឡើងពីការសន្យាដែលធ្វើឡើងដោយកូនបំណុលនោះចំពោះសេវាកម្មផ្ទាល់ខ្លួនរបស់គាត់ ឬ របស់មនុស្សទាំងឡាយដែលនៅក្រោមការគ្រប់គ្រងរបស់គាត់ ជាការធានាលើបំណុល ហើយតម្លៃនៃសេវាកម្មទាំងនោះ ដូចដែលបានវាយតម្លៃសមហេតុផល មិនអនុវត្តចំពោះការជម្រះបញ្ជីនៃបំណុល ឬ រយៈពេល និង ធម្មជាតិនៃសេវាកម្មទាំងនោះមិនមានដែនកំណត់ និង មិនត្រូវបានកំណត់ច្បាស់លាស់ ។

អ្វីៗជាច្រើនទៀតអំពីរបាយការណ៍ TIP 2006

របាយការណ៍ TIP គឺជារបាយការណ៍ពិភពលោកដ៏ទូលំទូលាយបំផុតលើកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងទម្រង់នៃការជួញដូរមនុស្សធ្ងន់ធ្ងរ។ របាយការណ៍ TIP គ្របដណ្តប់រយៈពេលពី ខែ មេសា ២០០៥ ដល់ ខែ មិនា ២០០៦។

តើរបាយការណ៍នេះមានអ្វី និង គ្មានអ្វី

របាយការណ៍នៃការជួញដូរមនុស្ស (TIP) ប្រចាំឆ្នាំ រួមបញ្ចូលប្រទេសទាំងឡាយដែលកំណត់ជាប្រទេសដើម, ឆ្លងកាត់ ឬ គោលដៅ សម្រាប់ជនរងគ្រោះមួយចំនួនធំនៃទម្រង់ជួញដូរធ្ងន់ធ្ងរ។ ដោយសារការជួញដូរទំនងជារាលដាលដល់គ្រប់ប្រទេសទាំងអស់នៅលើពិភពលោក ការភ្លេចប្រទេសណាមួយលើរបាយការណ៍នេះអាចគ្រាន់តែបញ្ជាក់ពីកង្វះខាតនៃព័ត៌មានគ្រប់គ្រាន់។ ការរៀបរាប់ពីប្រទេស ពិពណ៌នាពីទំហំ និង ធម្មជាតិនៃបញ្ហាជួញដូរ, មូលហេតុចំពោះការរួមបញ្ចូលប្រទេសនោះ និង កិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ។

ការរៀបរាប់នោះក៏មានផងដែរនូវការវាយតម្លៃលើការអនុលោមតាមរបស់រដ្ឋាភិបាល ជាមួយនឹងបទដ្ឋានអប្បបរមាសម្រាប់ការលុបបំបាត់ការជួញដូរ ដូចដែលមានថ្លែងនៅក្នុងច្បាប់ការពារជនរងគ្រោះនៃការជួញដូរ (TVPA) ឆ្នាំ ២០០០ ដែលបានកែប្រែ ហើយរួមបញ្ចូលសំណូមពរអំពីសកម្មភាពប្រឆាំងនឹងការជួញដូរ។ ផ្នែកនៅសល់នៃការរៀបរាប់ពីប្រទេស ពិពណ៌នាពីកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលនីមួយៗក្នុងការពង្រឹងច្បាប់ប្រឆាំងការជួញដូរ, ការការពារជនរងគ្រោះ និង ការបង្ការការជួញដូរ។ ការរៀបរាប់នីមួយៗពន្យល់ពីមូលដ្ឋានសម្រាប់ការដាក់អត្រាប្រទេសជាថ្នាក់ទី ១, ថ្នាក់ទី ២, បញ្ជីឃ្លាំមើលថ្នាក់ទី ២ ឬ ថ្នាក់ទី ៣។ ប្រសិនបើប្រទេសមួយត្រូវបានដាក់នៅក្នុងបញ្ជីឃ្លាំមើលថ្នាក់ទី ២ ការរៀបរាប់នោះនឹងមានរបាយការណ៍ដែលពន្យល់មូលហេតុ ដោយប្រើប្រាស់លក្ខខ័ណ្ឌដែលមាននៅក្នុង TVPA ដូចដែលបានកែប្រែ។

តាមសេចក្តីណែនាំរបស់ TVPA មានកត្តាដែលត្រូវពិចារណាក្នុងការកំណត់ថាតើប្រទេសមួយគួរតែស្ថិតនៅក្នុងថ្នាក់ទី ២ (ឬ បញ្ជីឃ្លាំមើលថ្នាក់ទី ២) ឬ នៅក្នុងថ្នាក់ទី ៣ : ១) ទំហំដែលប្រទេសនោះគឺជាប្រទេសដើម, ឆ្លងកាត់ ឬ គោលដៅ សម្រាប់ទម្រង់ជួញដូរធ្ងន់ធ្ងរ, ២) ទំហំដែលរដ្ឋាភិបាលរបស់ប្រទេសមួយមិនអនុវត្តតាមបទដ្ឋានអប្បបរមារបស់ TVPA ហើយ ជាពិសេស ទំហំនៃអំពើពុករលួយរបស់រដ្ឋាភិបាលដែលទាក់ទងនឹងការជួញដូរ, និង ៣) ធនធាន និង សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការបង្ហាញ និង លុបបំបាត់ទម្រង់នៃការជួញដូរមនុស្សធ្ងន់ធ្ងរ។

រដ្ឋាភិបាលមួយចំនួនបានចេញសេចក្តីថ្លែងការ, ធ្វើសន្និសីទ និង បង្កើតកម្លាំងការងារ ឬ ផែនការសកម្មភាពជាតិក្នុងការបង្កើតគោលដៅសម្រាប់កិច្ចខំប្រឹងប្រែងប្រឆាំងការជួញដូរ។ ទោះជាយ៉ាងនេះក្តី សេចក្តីថ្លែងការណ៍, សន្និសីទ, ផែនការ និង កម្លាំងការងារតែឯងមិនមានទម្ងន់ធ្ងន់ក្នុងការវាយតម្លៃកិច្ចខំប្រឹងប្រែងរបស់ប្រទេសនោះឡើយ។ ប៉ុន្តែ

របាយការណ៍នេះបានផ្តោតលើសកម្មភាពដ៏រឹងមាំដែលរដ្ឋាភិបាលបានធ្វើក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ ពិសេសការផ្តន្ទាទោស, ការកាត់ទោស និង ការកាត់ទោសជាប់ពន្ធនាគារចំពោះអ្នកជួញដូរ, ការការពារជនរងគ្រោះ និង កិច្ចខំប្រឹងប្រែងលើការបង្ការ។ របាយការណ៍នេះមិនផ្តល់ទម្ងន់ធំចំពោះច្បាប់ដែលមានទម្រង់ជាសេចក្តីព្រៀង ឬ ច្បាប់ដែលមិនទាន់បានអនុម័តនៅឡើយ។ ចុងបញ្ចប់ របាយការណ៍នេះមិនបានផ្តោតលើកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលដែលរួមចំណែកមិនផ្ទាល់ចំពោះការកាត់បន្ថយការជួញដូរ ដូចជាកម្មវិធីអប់រំ, ការគាំទ្រចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ច ឬ កម្មវិធីដែលមានបំណងធ្វើឱ្យមានសមភាពភេទប្រសើរឡើង ទោះបីជាអ្វីៗទាំងនេះគឺសេចក្តីព្យាយាមដ៏មានប្រយោជន៍។

ហេតុអ្វីរបាយការណ៍ TIP 2006 មានការវាយតម្លៃប្រទេសច្រើន

របាយការណ៍ ២០០៦ រួមបញ្ចូលការវិភាគលើការជួញដូរ និង កិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងវា នៅក្នុងប្រទេស ១៤៩ ដែលបានកើនឡើង ៧ លើសពីឆ្នាំមុន។ នៅឆ្នាំកន្លងៗទៅ ប្រទេសមួយចំនួនមិនត្រូវបានរាប់បញ្ចូល ពីព្រោះមានភាពលំបាកក្នុងការប្រមូលព័ត៌មានដែលគួរឱ្យទុកចិត្ត និង សំខាន់ ដោយសារ : ធម្មជាតិនៃការជួញដូរខុសច្បាប់ និង លួចលាក់, អវត្តមាន ឬ ភាពទើបកកើតនៃកិច្ចខំប្រឹងប្រែងប្រឆាំង TIP របស់រដ្ឋាភិបាល, ភាពលំបាកក្នុងការសម្គាល់ឱ្យច្បាស់រវាងការជួញដូរ និង លួចឆ្លងដែន, ភាពភ័យខ្លាច និង ភាពស្ងប់ស្ងាត់របស់ជនរងគ្រោះនៃការជួញដូរដែលជាញឹកញាប់ឆ្លងកាត់ប្រទេសដោយខុសច្បាប់ ឬ ត្រូវបានរំលោភបំពាន ឬ បង្ខិតបង្ខំលើរាងកាយ, កង្វះខាតទូទៅនៃសេរីភាពព័ត៌មាននៅក្នុងប្រទេសមួយ ឬ កង្វះខាតនៃ NGOs ឯករាជ្យ ដែលអាចផ្គត់ផ្គង់ព័ត៌មានបាន។ ចំពោះប្រទេសមួយចំនួន ព័ត៌មានគឺមាន ប៉ុន្តែទិន្នន័យមិនអាចគាំទ្រការរកឃើញថាចំនួនដ៏សំខាន់នៃមនុស្សបីនាក់ត្រូវបានជួញដូរទៅ, ពី ឬ នៅក្នុងប្រទេសមួយនោះ ដែលជាកម្រិតទូទៅសម្រាប់ការរួមបញ្ចូលនៅក្នុងរបាយការណ៍ TIP។ តាមឆ្នាំកន្លងទៅ យើងបានឃើញនូវការតបតដ៏ខ្លាំងក្លាពីរដ្ឋាភិបាលជាច្រើន, យុទ្ធនាការយល់ដឹងសាធារណៈជាច្រើនដែលរំលឹកដល់ជនរងគ្រោះចំពោះសេវាកម្មការពារ និង តម្លាភាពកាន់តែធំលើកិច្ចខំប្រឹងប្រែងប្រឆាំងការជួញដូរ។ ជាលទ្ធផលនៃសកម្មភាពវិជ្ជមានទាំងនេះ និង ការបូជាធនធានរបស់ក្រសួងការបរទេសដ៏ច្រើន ព័ត៌មានត្រូវបានប្រមូលពីប្រទេសបន្ថែមទៀតនៅក្នុងឆ្នាំនេះ។ ក្រសួងមានគោលបំណងរួមបញ្ចូលប្រទេសទាំងអស់ជាមួយនឹងចំនួនដ៏សំខាន់នៃជនរងគ្រោះនៃការជួញដូរ នៅក្នុងរបាយការណ៍នាពេលអនាគត ដូចដែលយើងមានព័ត៌មានកាន់តែច្រើន និង កាន់តែប្រសើរ។

ការជួញដូរ និង ចម្បាំង : ទាហានកុមារនៅប្រទេសភូមា

ព័ត៌មានដ៏គួរឱ្យស្អប់ខ្ពើមអំពីកុមារដែលបានជួញដូរ ហើយត្រូវបានបង្ខំឱ្យបម្រើជាទាហានកុមារ ជាញឹកញាប់ឃើញមាននៅប្រទេសអាហ្វ្រិកដូចជា អ៊ូហ្គាន់ដា និង សេរ៉ាលីអូន។ ទោះជាយ៉ាងនេះក្តី ជម្លោះដែលអូសបន្លាយជាយូរនៅភូមាជាមួយនឹងកងកម្លាំងជនភាគតិច និង ស្ថានភាពនយោបាយ និង សេដ្ឋកិច្ចដែលកាន់តែអាក្រក់ខ្លាំង បានធ្វើឱ្យប្រជាជនរបស់

ប្រទេសនេះងាយនឹងទទួលរងការកេងប្រវ័ញ្ច ដោយបានបង្កើតបរិដ្ឋានមួយដែលកុមារវ័យក្មេងត្រឹមអាយុ ១១ ក៏ត្រូវបានបង្ខំឱ្យចូលទៅក្នុងយោធាដែរ។ ទាំងក្រុមយោធា និង ក្រុមប្រដាប់អាវុធជនភាគតិចជ្រើសរើសទាហានកុមារ។

ទាំងរដ្ឋាភិបាលសហរដ្ឋអាមេរិក និង អង្គការសហប្រជាជាតិបានអំពាវនាវឱ្យរដ្ឋាភិបាលភូមាបញ្ឈប់ការជ្រើសរើស និង ការក្មេងប្រវ័ញ្ចលើកុមារទាំងអស់នៅក្នុងយោធា។ ក្រៅពីសម្ពាធទាំងនេះ រដ្ឋាភិបាលភូមាបដិសេធក្នុងការបង្ហាញនូវការអនុវត្តន៍លើក្មេងដែលបានចាប់ ក្នុងគោលបំណងនៃការកេងប្រវ័ញ្ចខាងយោធា។

របៀបប្រើប្រាស់របាយការណ៍នេះ

របាយការណ៍នេះគឺជាឧបករណ៍ការទូតសម្រាប់រដ្ឋាភិបាលសហរដ្ឋអាមេរិក ប្រើប្រាស់ជាមធ្យោបាយសម្រាប់ការសន្ទនា និង ការជម្រុញជាបន្តបន្ទាប់ ហើយជាសេចក្ដីណែនាំដើម្បីជួយផ្ដោតការយកចិត្តទុកដាក់លើធនធាននៃកម្មវិធី និង គោលការណ៍ផ្ដន្ទាទោស, ការពារ និង បង្ការ។ ក្រសួងការបរទេសនឹងបន្តជម្រុញរដ្ឋាភិបាលនានានូវមាតិកានៃរបាយការណ៍នេះ ដើម្បីពង្រឹងកិច្ចខំប្រឹងប្រែងសហប្រតិបត្តិការក្នុងការកំចាត់ការជួញដូរ។ នៅឆ្នាំក្រោយ ហើយជាពិសេស នៅប៉ុន្មានខែមុនការធ្វើសេចក្ដីកំណត់លើការដាក់ទណ្ឌកម្មសម្រាប់ប្រទេសថ្នាក់ទី ៣ ក្រសួងនឹងប្រើប្រាស់ព័ត៌មានដែលប្រមូលបាននៅទីនេះដើម្បីផ្ដោតគោលដៅកម្មវិធីជំនួយឱ្យកាន់តែមានប្រសិទ្ធិភាព និង ធ្វើការជាមួយប្រទេសដែលត្រូវការជំនួយក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ។ ក្រសួងសង្ឃឹមថារបាយការណ៍នេះនឹងជាឯកសារដាស់អារម្មណ៍សម្រាប់កិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាល និង មិនមែនរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សជុំវិញពិភពលោក។

ថ្នាក់នានា

ថ្នាក់ទី ១ : ប្រទេសដែលរដ្ឋាភិបាលរបស់ខ្លួនប្រព្រឹត្តិបានទាំងស្រុង តាមបទដ្ឋានអប្បបរមារបស់ច្បាប់។ (ព័ត៌មានលម្អិតនៅទំព័រ ២៨៨)

ថ្នាក់ទី ២ : ប្រទេសដែលរដ្ឋាភិបាលរបស់គេមិនប្រព្រឹត្តិបានទាំងស្រុង តាមបទដ្ឋានអប្បបរមារបស់ច្បាប់ ប៉ុន្តែធ្វើកិច្ចខំប្រឹងប្រែងសំខាន់ៗ ដើម្បីនាំឱ្យពួកគេឱ្យប្រព្រឹត្តិបានតាមបទដ្ឋានទាំងនេះ។

បញ្ជីឃ្លាំមើលពិសេសថ្នាក់ទី ២ : ប្រទេសដែលរដ្ឋាភិបាលរបស់គេមិនប្រព្រឹត្តិបានទាំងស្រុង តាមបទដ្ឋានអប្បបរមារបស់ច្បាប់ ប៉ុន្តែធ្វើកិច្ចខំប្រឹងប្រែងសំខាន់ៗ ដើម្បីនាំឱ្យពួកគេឱ្យប្រព្រឹត្តិតាមបទដ្ឋានទាំងនេះ និង :

ក) ចំនួនដាច់លាក់នៃជនរងគ្រោះនៃទម្រង់ជួញដូរធ្ងន់ធ្ងរគឺមានសារៈសំខាន់ណាស់ ឬ មានការកើនឡើងយ៉ាងសំខាន់ ឬ

ខ) មានការបរាជ័យក្នុងការផ្ដល់ភស្តុតាងនៃការបន្ថែមកិច្ចខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងទម្រង់ជួញដូរមនុស្សធ្ងន់ធ្ងរពីឆ្នាំកន្លងទៅ ឬ

គ) ការកំណត់ដែលថាប្រទេសមួយកំពុងធ្វើកិច្ចខំប្រឹងប្រែងដ៏សំខាន់ដើម្បីនាំឱ្យពួកគេឱ្យប្រព្រឹត្តិតាមបទដ្ឋានអប្បបរមាទាំងនេះ គឺផ្អែកលើការប្តេជ្ញារបស់ប្រទេសនោះក្នុងការធ្វើជំហានបន្ថែមទៀតនាពេលអនាគត នៅប៉ុន្មានឆ្នាំ ខាងមុខ ។

ថ្នាក់ ៣ : ប្រទេសដែលរដ្ឋាភិបាលរបស់គេមិនប្រព្រឹត្តិបានទាំងស្រុងតាមបទដ្ឋានអប្បបរមារបស់ច្បាប់ ហើយមិនធ្វើកិច្ចខំប្រឹងប្រែងសំខាន់ៗ ដើម្បីប្រព្រឹត្តិតាម ។

វិធីសាស្រ្ត

ក្រសួងការបរទេសបានរៀបចំរបាយការណ៍នេះដោយប្រើប្រាស់ព័តិមានពីស្ថានទូតសហរដ្ឋអាមេរិក, មន្ត្រីរដ្ឋាភិបាលបរទេស, NGOs និង អង្គការអន្តរជាតិ, របាយការណ៍ដែលបានបោះពុម្ពផ្សព្វផ្សាយ, ដំណើរស្រាវជ្រាវទៅតំបន់នីមួយៗ និង ព័តិមានដែលបានប្រគល់ទៅ tipreport@state.gov ដែលបានបង្កើតសម្រាប់ NGOs និង បុគ្គលនានា ឱ្យចែករំលែកព័តិមានលើការរីកចម្រើនរបស់រដ្ឋាភិបាលក្នុងការបង្ក្រាបការជួញដូរ ។ បុស្តិ៍ការទូតរបស់សហរដ្ឋអាមេរិកបានរាយការណ៍ពីស្ថានភាពជួញដូរ និង សកម្មភាពរដ្ឋាភិបាលដោយផ្អែកលើការស្រាវជ្រាវលម្អិត រួមបញ្ចូលទាំងការប្រជុំជាមួយនឹងមន្ត្រីរដ្ឋាភិបាលផ្សេងៗ, អ្នកតំណាង NGO ក្នុងតំបន់ និង អន្តរជាតិ, អង្គការអន្តរជាតិ, មន្ត្រី, អ្នកសារព័តិមាន, អ្នកសិក្សា និង ជនរួចពីការរងគ្រោះ ។ ដើម្បីចងក្រងរបាយការណ៍ឆ្នាំនេះ ក្រសួងបានមើលលើប្រភពព័តិមានថ្មីៗសម្រាប់ប្រទេសនីមួយៗ ដើម្បីធ្វើការវាយតម្លៃរបស់ខ្លួន ។ ការវាយតម្លៃកិច្ចខំប្រឹងប្រែងប្រឆាំងការជួញដូររបស់រដ្ឋាភិបាលនីមួយៗ ទាក់ទងទៅនឹងដំណើរការពីរជំហាន :

ជំហាន ១ : ចំនួនដាក់លាក់នៃជនរងគ្រោះ

ដំបូង ក្រសួងបានកំណត់ថាតើប្រទេសមួយគឺជា "ប្រទេសដើម, ឆ្លងកាត់ ឬ គោលដៅសម្រាប់ចំនួនជាក់លាក់នៃជនរងគ្រោះនៃទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរ" ជាទូទៅលើលំដាប់នៃជនរងគ្រោះ ១០០ នាក់ ឬ ច្រើនជាងនេះ ដែលជាកម្រិតដូចគ្នា អនុវត្តនៅក្នុងរបាយការណ៍ពីមុន ។ ប្រទេសមួយចំនួនដែលព័តិមានដូច្នោះមិនមាន មិនទទួលការកំណត់អត្រាជាថ្នាក់ទេ ប៉ុន្តែបានរួមបញ្ចូលនៅក្នុងផ្នែកករណីពិសេស នៅពេលពួកគេបានបង្ហាញនូវការជួញដូរ ។

ជំហាន ២ : ការដាក់ថ្នាក់

ក្រសួងដាក់ប្រទេសនីមួយដែលរួមបញ្ចូលនៅលើរបាយការណ៍ TIP 2006 ទៅជាបញ្ជីបួន ដែលពិពណ៌នានៅទីនេះជាថ្នាក់ តាមការអនុញ្ញាតនៃ TVPA ។ ការដាក់នេះគឺផ្អែកយ៉ាងច្រើនលើទំហំនៃសកម្មភាពរដ្ឋាភិបាលក្នុងការប្រយុទ្ធនឹងការជួញដូរ ជាជាងទំហំនៃបញ្ហាសារៈសំខាន់ដែលវាមាន ។ ដំបូង ក្រសួងវាយតម្លៃថាតើរដ្ឋាភិបាលនោះប្រព្រឹត្តិតាមបទដ្ឋាន

អប្បបរមារបស់ TVPA ទាំងស្រុង សម្រាប់ការលុបបំបាត់ការជួញដូរ (លម្អិតនៅទំព័រ ២៨៨)។ រដ្ឋាភិបាលដែលធ្វើដូច្នេះ ត្រូវបានដាក់នៅថ្នាក់ទី ១។ សម្រាប់រដ្ឋាភិបាលផ្សេងទៀត ក្រសួងពិចារណាថាតើពួកគេបានធ្វើកិច្ចខំប្រឹងប្រែងដ៏សំខាន់ ដើម្បីឱ្យពួកគេអនុលោមតាម។ រដ្ឋាភិបាលដែលធ្វើកិច្ចខំប្រឹងប្រែងដ៏សំខាន់ដើម្បីបំពេញតាមបទដ្ឋានអប្បបរមាត្រូវបាន ដាក់នៅក្នុងថ្នាក់ទី ២។ រដ្ឋាភិបាលដែលមិនប្រព្រឹត្តិតាមទាំងស្រុងជាមួយនឹងបទដ្ឋានអប្បបរមា និង មិនធ្វើកិច្ចខំប្រឹងប្រែង ដ៏សំខាន់ដើម្បីបំពេញតាម ត្រូវបានដាក់នៅថ្នាក់ទី ៣។ ចុងក្រោយ លក្ខណៈវិនិច្ឆ័យនៃបញ្ជីឃ្លាំមើលពិសេស ត្រូវបាន ពិចារណា ហើយប្រសិនបើអាច ប្រទេសថ្នាក់ទី ២ ត្រូវបានដាក់នៅលើបញ្ជីឃ្លាំមើលថ្នាក់ទី ២។

បញ្ជីឃ្លាំមើលពិសេស - បញ្ជីឃ្លាំមើលថ្នាក់ទី ២

ការផ្តល់អំណាចឡើងវិញឆ្នាំ ២០០៣ នៃ TVPA បានបង្កើត "បញ្ជីឃ្លាំមើលពិសេស" នៃប្រទេសនានានៅលើ របាយការណ៍ TIP ដែលគួរទទួលការពិនិត្យពិច័យពិសេស។ បញ្ជីនេះរួមផ្សំ ១) ប្រទេសនានាដែលបានរាយនៅថ្នាក់ទី ១ នៅលើរបាយការណ៍បច្ចុប្បន្ន ដែលត្រូវបានរាយនៅថ្នាក់ទី ២ នៅលើរបាយការណ៍ ២០០៥, ២) ប្រទេសនានាដែលបាន រាយនៅថ្នាក់ទី ២ នៅលើរបាយការណ៍បច្ចុប្បន្ន ដែលត្រូវបានរាយនៅថ្នាក់ទី ៣ នៅលើរបាយការណ៍ ២០០៥ និង ៣) ប្រទេសនានាដែលបានរាយនៅថ្នាក់ទី ២ នៅលើរបាយការណ៍បច្ចុប្បន្ន ដែល :

ក) ចំនួនជាក់លាក់នៃជនរងគ្រោះនៃទម្រង់ជួញដូរធ្ងន់ធ្ងរគឺមានសារៈសំខាន់ណាស់ ឬ មានការកើនឡើងយ៉ាង សំខាន់ ឬ

ខ) មានការបរាជ័យក្នុងការផ្តល់ភស្តុតាងនៃការបន្ថែមកិច្ចខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងទម្រង់ជួញដូរ មនុស្សធ្ងន់ធ្ងរពីឆ្នាំកន្លងទៅ រួមបញ្ចូលទាំងការបង្កើនការស៊ើបអង្កេត, ការផ្តន្ទាទោស និង ការកាត់ទោសលើ ឧក្រិដ្ឋកម្មជួញដូរ, ការបង្កើនជំនួយដល់ជនរងគ្រោះ ព្រមទាំង ការបន្ថយភស្តុតាងនៃការចូលដៃពីមន្ត្រីរដ្ឋាភិបាល នៅក្នុងទម្រង់នៃការជួញដូរធ្ងន់ធ្ងរ ឬ

គ) ការកំណត់ដែលថាប្រទេសមួយកំពុងធ្វើកិច្ចខំប្រឹងប្រែងដ៏សំខាន់ដើម្បីនាំឱ្យពួកគេឱ្យប្រព្រឹត្តិតាមបទដ្ឋាន អប្បបរមាទាំងនេះ គឺផ្អែកលើការប្តេជ្ញារបស់ប្រទេសនោះក្នុងការធ្វើជំហានបន្ថែមទៀតនាពេលអនាគត នៅប៉ុន្មាន ឆ្នាំខាងមុខ។

ប្រភេទនេះ (រួមបញ្ចូលទាំង ក, ខ និង គ) ត្រូវបានដាក់លក្ខខ័ណ្ឌដោយក្រសួងការបរទេស "បញ្ជីឃ្លាំមើលថ្នាក់ទី ២"។ មានប្រទេស ២៧ ដែលបានដាក់នៅលើបញ្ជីឃ្លាំមើលថ្នាក់ ២ នៅលើរបាយការណ៍ ខែមិថុនា ២០០៥។ ជាមួយនឹង ប្រទេស ៦ ដែលត្រូវបានវាយតម្លៃឡើងវិញថាជាប្រទេសនៅលើបញ្ជីឃ្លាំមើលថ្នាក់ទី ២ នៅខែកញ្ញា ២០០៥ និង ប្រទេស ៣ ដែលបានបំពេញតាមប្រភេទពីរដំបូងខាងលើ (ផ្លាស់ទីទៅថ្នាក់លើនោះពីរបាយការណ៍ TIP 2005) ប្រទេសទាំង ២៧ នេះត្រូវបានរួមបញ្ចូលនៅក្នុង "ការវាយតម្លៃចន្លោះពេល" ដែលចេញដោយក្រសួងការបរទេសនៅថ្ងៃទី ១ កុម្ភៈ ២០០៦។

ក្នុងចំណោមប្រទេស ៣៣ លើបញ្ជីឃ្លាំមើលថ្នាក់ទី ២ នៅពេលនៃការវាយតម្លៃចន្លោះពេល ប្រទេស ១៦ បាន ផ្លាស់ទីទៅថ្នាក់ទី ២ លើរបាយការណ៍នេះ នៅពេលដែលប្រទេស ៤ បានធ្លាក់ទៅថ្នាក់ទី ៣ និង ប្រទេស ១២ នៅតែស្ថិត នៅលើបញ្ជីឃ្លាំមើលថ្នាក់ទី ២ ក្នុងរយៈពេលបីឆ្នាំជាប់ៗគ្នា។ ហាយទី ត្រូវបានដាក់នៅក្នុងប្រភេទ "ករណីពិសេស" នៅ ឆ្នាំនេះ។ ប្រទេសដែលបានដាក់នៅលើបញ្ជីឃ្លាំមើលពិសេសនៅលើរបាយការណ៍នេះនឹងត្រូវបានពិនិត្យឡើងវិញនៅក្នុង ការវាយតម្លៃចន្លោះពេល ដែលនឹងត្រូវប្រគល់ទៅឱ្យសភាសហរដ្ឋអាមេរិកនៅថ្ងៃ ១ កុម្ភៈ ២០០៧។

ការពិន័យដែលអាចមានសម្រាប់ប្រទេសថ្នាក់ទី ៣

រដ្ឋាភិបាលនៃប្រទេសនៅក្នុងថ្នាក់ទី ៣ អាចនឹងប្រឈមនឹងទណ្ឌកម្មជាក់លាក់មួយចំនួន។ រដ្ឋាភិបាលសហរដ្ឋ អាមេរិកអាចព្យួរជំនួយមិនមនុស្សធម៌ ដែលមិនទាក់ទងនឹងជំនួញ។ ប្រទេសដែលទទួលជំនួយដូច្នោះនឹងប្រឈមចំពោះ ការព្យួរការផ្តល់មូលនិធិសម្រាប់ការចូលរួមនៅក្នុងកម្មវិធីផ្លាស់ប្តូរការអប់រំ និង វប្បធម៌។

ស្របទៅតាម TVPA រដ្ឋាភិបាលទាំងនេះក៏នឹងប្រឈមការប្រឆាំងរបស់សហរដ្ឋអាមេរិកចំពោះជំនួយ (លើកលែង សម្រាប់មនុស្សធម៌, ទាក់ទងជំនួញ និង ជំនួយទាក់ទងការអភិវឌ្ឍន៍ជាក់លាក់មួយចំនួន) ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក។ ផលវិបាកដែលអាចមានទាំងនេះនឹងមានប្រសិទ្ធិភាពនៅដើម ឆ្នាំសារពើពន្ធបន្ទាប់ នៅថ្ងៃ ១ តុលា ២០០៦។ ទណ្ឌកម្មរបស់ TVPA ទាំងអស់ ឬ មួយផ្នែកអាចត្រូវបានលុបចោល ទៅ តាមការកំណត់របស់ប្រធានាធិបតីដែលថា ការផ្តល់នូវជំនួយដូចនោះទៅឱ្យរដ្ឋាភិបាល នឹងលើកតម្កើនគោលបំណងច្បាប់ ឬ បើមិនដូច្នោះទេគឺស្ថិតនៅក្នុងផលប្រយោជន៍ជាតិរបស់សហរដ្ឋអាមេរិក។ TVPA ក៏បានផ្តល់ឱ្យដែរថា ការដាក់ទណ្ឌកម្ម អាចត្រូវបានលុបចោល ប្រសិនបើចាំបាច់ដើម្បីចៀសវាងផលប៉ះពាល់មិនល្អដ៏សំខាន់លើប្រជាជនទទន់ខ្សោយ រួមបញ្ចូលទាំង ស្ត្រី និង កុមារ។ ការដាក់ទណ្ឌកម្មនឹងមិនអនុវត្ត ប្រសិនបើប្រធានាធិបតីរកឃើញថា បន្ទាប់ពីរបាយការណ៍នេះបានចេញ ប៉ុន្តែ មុនការដាក់ទណ្ឌកម្ម រដ្ឋាភិបាលបានអនុលោមតាមបទដ្ឋានអប្បបរមា ឬ កំពុងធ្វើកិច្ចខំប្រឹងប្រែងដ៏សំខាន់ក្នុងការ នាំពួកគេឱ្យអនុលោមតាម។

ដោយមិនគិតពីការដាក់ថ្នាក់ ប្រទេសនីមួយៗអាចធ្វើបានច្រើនជាងនេះ រួមបញ្ចូលទាំងសហរដ្ឋអាមេរិក។ គ្មានការ ដាក់ប្រទេសណាមួយជារៀងរហូតនោះទេ។ ប្រទេសទាំងអស់ត្រូវតែរក្សា និង បង្កើនកិច្ចខំប្រឹងប្រែងដើម្បីប្រយុទ្ធប្រឆាំង នឹងការជួញដូរ។

កម្ពុជា (បញ្ជីឃ្លាំមើលថ្នាក់ទី ២)

កម្ពុជាគឺជាប្រទេសដើម, គោលដៅ និង ឆ្លងកាត់សម្រាប់បុរស, ស្ត្រី និង កុមារដែលបានជួញដូរក្នុងគោលបំណងអាជីវកម្មផ្លូវភេទ និង ពលកម្មបង្ខំ។ ស្ត្រី និង កុមារកម្ពុជាមួយចំនួនជាក់លាក់ ត្រូវបានជួញដូរទៅប្រទេសថៃ និង ម៉ាឡេស៊ីសម្រាប់ការកេងប្រវ័ញ្ចលើអាជីវកម្មផ្លូវភេទ និង ពលកម្មបង្ខិតបង្ខំ។ បុរសកម្ពុជាត្រូវបានជួញដូរជាចំបង ទៅប្រទេសថៃសម្រាប់ពលកម្មបង្ខិតបង្ខំនៅក្នុងផ្នែកសំណង់ និង កសិកម្ម ជាពិសេសឧស្សាហកម្មនេសាទ នៅពេលដែលស្ត្រី និង ក្មេងស្រីកម្ពុជាត្រូវបានជួញដូរសម្រាប់ការងារតាមរោងចក្រ និង គ្រួសារ។ កុមារកម្ពុជាមួយចំនួនជាក់លាក់ត្រូវបានជួញដូរទៅប្រទេសវៀតណាម និង ថៃ ក្នុងគោលបំណងឱ្យសុំទានដោយបង្ខិតបង្ខំ។ កម្ពុជាគឺជាចំណុចឆ្លងកាត់ និង គោលដៅសម្រាប់ស្ត្រីមកពីវៀតណាមដែលត្រូវបានជួញដូរសម្រាប់អាជីវកម្មផ្លូវភេទ។ ការជួញដូរសម្រាប់អាជីវកម្មផ្លូវភេទក៏កើតឡើងនៅក្នុងព្រំដែនរបស់កម្ពុជា ពីតំបន់ជនបទទៅកាន់ភ្នំពេញ ដែលជារាជធានីរបស់ប្រទេសនេះ និង ទីក្រុងតូចៗផ្សេងទៀតនៅក្នុងប្រទេស។

រដ្ឋាភិបាលកម្ពុជាមិនបានប្រព្រឹត្តិតាមទាំងស្រុងជាមួយនឹងបទដ្ឋានអប្បបរមា សម្រាប់ការលុបបំបាត់ការជួញដូរទេប៉ុន្តែ កំពុងធ្វើកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់ដើម្បីលុបបំបាត់។ កម្ពុជាត្រូវបានដាក់នៅលើបញ្ជីឃ្លាំមើលថ្នាក់ទី ២ ពីព្រោះការកំណត់ដែលថាខ្លួនកំពុងធ្វើកិច្ចខំប្រឹងប្រែងដ៏សំខាន់ គឺផ្អែកមួយផ្នែកលើការប្តេជ្ញាក្នុងការទ្រទ្រង់ភាពរីកចម្រើននៅឆ្នាំខាងមុខ។ ក្នុងអំឡុងឆ្នាំកន្លងទៅ រដ្ឋាភិបាលកម្ពុជាបានលើកតម្កើនកិច្ចខំប្រឹងប្រែងក្នុងការចាប់ខ្លួន, ផ្តន្ទាទោស និង កាត់ទោសអ្នកជួញដូរ។ សកម្មភាពរបស់នគរបាលបានកើនឡើងនៅឆ្នាំមុន ដែលមានលទ្ធផលជាការវាយឆ្មក់ និង ក្រោយមកបិទទ្វាសណ្ឋាគារ/ផ្ទះបនជាក់ស្តែងមួយដែលជាកន្លែងរកឃើញជនរងគ្រោះនៃការជួញដូរ។ ម្ចាស់ផ្ទះបន ក្រោយមកត្រូវបានផ្តន្ទាទោស និង កាត់ទោស។ ទោះបីជាកិច្ចខំប្រឹងប្រែងប្រឆាំងការជួញដូររបស់កម្ពុជានៅទទួលការរំខានពីអំពើពុករលួយនៅគ្រប់កម្រិតទាំងអស់នៃរដ្ឋាភិបាល និង ប្រព័ន្ធតុលាការដែលគ្មានប្រសិទ្ធិភាព រដ្ឋាភិបាលកម្ពុជាបានធ្វើកិច្ចខំប្រឹងប្រែងដើម្បីបង្ហាញពីអំពើពុករលួយរបស់មន្ត្រីដែលទាក់ទងនឹងការជួញដូរ ដោយបានចាប់ខ្លួន និង នាំឱ្យមានការផ្តន្ទាទោសដល់មន្ត្រីនគរបាលផ្នែកប្រឆាំងការជួញដូរ និង មន្ត្រីនគរបាលខេត្តពីររូបទៀត។ ក្រសួងមហាផ្ទៃ (MOI) ក៏បានបង្កើតផែនការសកម្មភាពជាតិដើម្បីបំបាត់ការជួញដូរមនុស្ស និង កំពុងស្ថិតនៅក្នុងដំណើរការនៃការបង្កើតអនុស្សរណៈយោគយល់ជាមួយ NGOs ដើម្បីគ្រប់គ្រងលើការដោះស្រាយជនរងគ្រោះនៃការជួញដូរ។ រដ្ឋាភិបាលកម្ពុជាគួរតែធ្វើកិច្ចខំប្រឹងប្រែងឱ្យធំជាងនេះក្នុងការផ្តន្ទាទោស និង កាត់ទោសមន្ត្រីសាធារណៈដែលទទួលផលចំណេញពី ឬ ទាក់ទងនៅក្នុងការជួញដូរ និង ក៏គួរតែឆ្លង និង អនុម័តច្បាប់ប្រឆាំងការជួញដូរឱ្យទូលំទូលាយ។

ការផ្តន្ទាទោស

ក្នុងអំឡុងពេលនៃការរាយការណ៍ រដ្ឋាភិបាលកម្ពុជាមានភាពរីកចម្រើនយ៉ាងច្បាស់នៅក្នុងកិច្ចខំប្រឹងប្រែងរបស់ស្ថាប័នពង្រឹងច្បាប់ប្រឆាំងការជួញដូររបស់ខ្លួន។ កម្ពុជាមិនមានច្បាប់ប្រឆាំងការជួញដូរទូលំទូលាយទេ ប៉ុន្តែខ្លួនបានប្រើប្រាស់បញ្ញត្តិដែលមានស្រាប់ដើម្បីផ្តន្ទាទោសអ្នកជួញដូរ។ កម្រងច្បាប់ប្រឆាំងការជួញដូរទូលំទូលាយដែលផ្តល់ឱ្យមន្ត្រីពង្រឹងច្បាប់ និង តុលាការ ជាមួយនឹងអំណាយបន្ថែមដើម្បីចាប់ខ្លួន និង ផ្តន្ទាទោសអ្នកជួញដូរគឺជិតនឹងទទួលការយល់ព្រមចុងក្រោយពីរដ្ឋាភិបាលនៅឆ្នាំ ២០០៦។ ការពិន័យសម្រាប់ការជួញដូរមនុស្សលើសពីអាយុ ១៥ ឆ្នាំសម្រាប់អាជីវកម្មផ្លូវភេទទទួលការកាត់ទោសជាប់ពន្ធធនាគារដល់ទៅ ១៥ ឆ្នាំ នៅពេលដែលការពិន័យសម្រាប់ការជួញដូរមនុស្សអាយុក្រោម ១៥ ឆ្នាំ សម្រាប់អាជីវកម្មផ្លូវភេទទទួលការកាត់ទោសជាប់ពន្ធធនាគារដល់ទៅ ២០ ឆ្នាំ។ នៅឆ្នាំ ២០០៥ នគរបាលកម្ពុជាបានរាយការណ៍ពីការធ្វើប្រតិបត្តិការ ៦៧ ករណី ដែលមានលទ្ធផលជាការចាប់ខ្លួនឧក្រិដ្ឋជន ១១១ នាក់ និង ជួយសង្គ្រោះជនរងគ្រោះ ១៦៤ នាក់។ ក្រសួងយុត្តិធមិបានរាយការណ៍ការផ្តន្ទាទោស និង ការកាត់ទោសអ្នកជួញដូរ យ៉ាងហោចណាស់ ១៥ នាក់ក្នុងអំឡុងឆ្នាំនេះ ដែលជាចំនួនទ្វេដងនៃឆ្នាំ ២០០៤។ ភាគច្រើន ករណីនានាត្រូវបានបង្កើតឡើងដោយកិច្ចខំប្រឹងប្រែងរបស់ NGOs។ អំពើពុករលួយ, កង្វះខាតការហ្វឹកហ្វឺន និង មូលនិធិសម្រាប់ស្ថាប័នពង្រឹងច្បាប់ និង តុលាការទន់ខ្សោយ នៅតែជាឧបសគ្គដ៏ធ្ងន់ធ្ងរបំផុតចំពោះការផ្តន្ទាទោសអ្នកជួញដូរប្រកបដោយប្រសិទ្ធិភាព។ មានរបាយការណ៍ដែលថាមន្ត្រីនគរបាលពុករលួយបន្តផ្សាយព័ត៌មានទៅដល់អ្នកចាត់ការផ្ទះបន/ខារ៉ាអូខេ អំពីការវាយឆ្មក់របស់នគរបាល នៅពេលខាងមុខ។ តបតទៅនឹងរបាយការណ៍នៃការចូលដៃរបស់មន្ត្រីសាធារណៈនៅក្នុងការជួញដូរ រដ្ឋាភិបាលបានចាប់ផ្តើមសកម្មភាពប្រឆាំងនឹងមន្ត្រីបួនរូបនៅពាក់កណ្តាលឆ្នាំ ២០០៥ សម្រាប់អំពើពុករលួយដែលទាក់ទងនឹងការជួញដូរ។ ដោយមានការសហការជាមួយអង្គការអន្តរជាតិ និង NGOs រដ្ឋាភិបាលបានធ្វើការហ្វឹកហ្វឺនដល់មន្ត្រីនគរបាលលើបច្ចេកទេសស៊ើបអង្កេត, ការឈ្លបមើល និង ការរៀបចំ ព្រមទាំងគ្រប់គ្រងករណីនៃការជួញដូរ។ ក្រៅពីការផ្តល់មូលនិធិរបស់សហរដ្ឋអាមេរិកពីមុនសម្រាប់ការហ្វឹកហ្វឺនដល់នគរបាលនាយកដ្ឋានប្រឆាំងការជួញដូរ រដ្ឋាភិបាលបានត្រឹមតែធ្វើការស៊ើបអង្កេតជាមុនមួយចំនួនកំណត់ប៉ុណ្ណោះ នៅឆ្នាំមុន។

ការការពារ

នៅក្នុងឆ្នាំ ២០០៥ រដ្ឋាភិបាលកម្ពុជាបានបន្តផ្តល់ជំនួយមានកំណត់ដល់ជនរងគ្រោះ។ រដ្ឋាភិបាលបានយោងជនរងគ្រោះទៅឱ្យ NGOs និង អង្គការអន្តរជាតិ និង បានដំណើរការទីជម្រកបណ្តោះអាសន្នពីរសម្រាប់ជនរងគ្រោះតាមរយៈក្រសួងសង្គមកិច្ច, អតីតយុទ្ធជន និង យុវនីតិសម្បទា (MOSAVY)។ រដ្ឋាភិបាលកម្ពុជាបានពឹងផ្អែកជាចំបងលើ NGOs បរទេស និង ក្នុងស្រុក ដើម្បីផ្តល់សេវាកម្មការពារដល់ជនរងគ្រោះ ទោះបីជាតាមកាលៈទេសៈ ខ្លួនបានផ្តល់ការគាំទ្រជាសម្ភារៈ និង សេវាកម្មដល់ NGOs ដូចជា ដី, កន្លែងការិយាល័យ និង បុគ្គលិក។ រដ្ឋាភិបាលបានបន្តឧបត្ថម្ភដល់ NGO ដែលមានការទទួលខុសត្រូវជាចំបងលើការដាក់ជនរងគ្រោះនៃការជួញដូរនៅក្នុងទីជម្រករយៈពេលវែង។

ការបង្ការ

រដ្ឋាភិបាលកម្ពុជាបានធ្វើកិច្ចខំប្រឹងប្រែងដ៏សមរម្យ ដើម្បីលើកតម្កើនការយល់ដឹងពីការជួញដូរក្នុងអំឡុងពេលនៃការរាយការណ៍។ ដោយធ្វើការជាមួយ NGOs និង អង្គការអន្តរជាតិ រដ្ឋាភិបាលកម្ពុជាបានប្រតិបត្តិយុទ្ធនាការមួយនៅផ្នែកជាច្រើននៃប្រទេសដើម្បីលើកតម្កើនការយល់ដឹងរបស់សាធារណៈ ទាក់ទងនឹងគ្រោះថ្នាក់នៃការជួញដូរតាមរយៈការប្រជុំជាសាធារណៈ, ប័ណ្ណប្រកាស, យុទ្ធនាការតាមទូរទស្សន៍ និង វិទ្យុ និង ការប្រើប្រាស់ខ្លោនខ្មែរបុរាណ។ ក្រសួងកិច្ចការនារីបានសហការជាមួយ IOM ដើម្បីផ្សព្វផ្សាយឱ្យបានពេញប្រទេសនូវព័ត៌មាននៃការប្រឆាំងការជួញដូរ និង យុទ្ធនាការទ្រទ្រង់ដែលបានរួមបញ្ចូលទាំងការប្រជុំនៅកម្រិតឃុំ-សង្កាត់ជាមួយមន្ត្រីរដ្ឋាភិបាល និង ការចែករំលែកឯកសារ និងវីដេអូអប់រំ។ ផ្នែកនគរបាលប្រឆាំងការជួញដូររបស់ MOI ក៏បានធ្វើកម្មវិធីអន្តរាគមដើម្បីបង្រៀនសិស្សអំពីគ្រោះថ្នាក់នៃការជួញដូរ និង សិទ្ធិរបស់ពួកគេក្រោមផ្លូវច្បាប់។